សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៥២

# ទស្សនាវដ្តី គ្រូបង្រៀន




សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនជាអធិបតីក្នុងទិវាគ្រូបង្រៀន
ខួបលើកទី២០ ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧

ត្រីមាសទី៤ ឆ្នាំ ២០១៧

ផ្សាយចេញរាល់ត្រីមាសពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤-០១២ ៦៣៨ ៨៨៩
អ៊ីម៉ែល : kta.amcek@gmail.com
Facebook: kta amcek

# មាតិកា


## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង ម៉ូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោក ជន ឈាងលី
- លោក ព្រុំ សាមិត
- លោកស្រី ម៉ក់ ណាង
- លោក ឆៀ សុផន
- លោកស្រី ថាច់ ធីសារ៉ែន
- លោក អ៊ុម ជា
- សមាជិកសមាជិកា ស. ប. ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកស្រី ទន់ សារ៉ឹម
- លោកស្រី ប្រាក់ សូលីដា
- លោក រត្ន ហួត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ីម
- លោក លី ហាក់សេង

## ការីកុំព្យូទ័រ

លោក ទេព្វឃិន សុធីរៈ

## គ្របខាងក្រៅ

- **ពីមុខ** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាអធិបតីក្នុងទិវាគ្រូបង្រៀនខួបលើកទី២០ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧
- **ពីក្រោយ** : ប្រាសាទសម្បូរព្រៃគុកចូលជាបេតិកភណ្ឌពិភពលោក (ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧)



| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **វប្បធម៌ទូទៅ** | |
| ២ | ប្រទេសកម្ពុជាក្នុងសមាហរណកម្មសហគមន៍អាស៊ានឆ្នាំ២០១៥ (ត) | ៣ |
| ៣ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៦ |
| ៤ | វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ (ត) | ១០ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៥ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុកតែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា(ត) | ១៣ |
| ៦ | ចលករសិក្សា (តចប់) | ១៦ |
| ៧ | តួនាទីបុត្រប្រុសស្រីក្នុងការតបស្នងសងគុណចំពោះមាតាបិតា ឬអាណាព្យាបាល | ១៨ |
| ៨ | ដំណាក់រងទាំង២ នៃដំណាក់បុរេប្រតិបត្តិការស្តីអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិរបស់លោក ព្យ៉ាសេ | ២០ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៩ | អ្នកអប់រំជាច្រើនត្រូវជួយជំរុញឲ្យមានការទទួលយកនូវមនសិការជាមូលដ្ឋាននៃការអប់រំដើម្បីជួយលើកស្ទួយប្រឌិតញាណជាតិការពារបទឧក្រិដ្ឋ និងអំពើហិង្សានានា(ត) | ២៣ |
| ១០ | អំពីនិបាតស័ព្ទ និងអាយតនិបាត(ត) | ២៦ |
| ១១ | ទស្សនៈយល់ដឹងពីភាពឆ្លាតខាងអារម្មណ៍របស់អ្នកធ្វើការងារអប់រំ | ២៨ |
| ១២ | សិស្សរៀនខ្សោយ និងសិស្សមានចរិតទុយមុយនឹងអាចប្រសើរឡើងបើគ្រូចេះរកវិធីជួយពួកគេ | ៣១ |
| | **វិទ្យាសាស្ត្រព័ត៌មាន បច្ចេកវិទ្យា** | |
| ១៣ | ការអានសារអ៊ីម៉ែល និងឆ្លើយតបអ៊ីម៉ែល | ៣២ |
| | **កំណាព្យ និងកំសាន្ត** | |
| ១៤ | ទំនួញមេស្វាត្រូវព្រានប្រមាញ់ (បទពាក្យ៧) | ៣៤ |
| ១៥ | សេដ្ឋីទិញដូង (បទពាក្យ៧) | ៣៦ |
| | **វេទិកាស្វែរិន** | |
| ១៦ | ពុទ្ធសាសនានៅប្រទេសកម្ពុជា(ត) (ពុទ្ធសាសនាសម័យមហានគរពស១៣៤៥-១៩៧៥ គស៨០២-១៤៣២) | ៣៨ |
| | **ព័ត៌មាន** | |
| ១៧ | សេចក្តីសង្កេតចំពោះច្បាប់ផ្សេងៗ | ៤១ |
| ១៨ | បច្ចុប្បន្នភាពស្ថិតិសមាជិក សមាជិកា ស.ប.ស.ខ. តាមរាជធានី-ខេត្តប្រចាំឆ្នាំ២០១៥ | ៤៣ |
| ១៩ | ស្ថិតិសពខែតុលា ឆ្នាំ២០១៦ដល់ខែមករា ឆ្នាំ២០១៧ | ៤៤ |



**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

| | | | |
|---|---|---|---|
| **ភ្នំពេញ** | : ០៨៩ ៦៨៤ ០៨១ | **កែប** | : ០៩៧ ៨ ៧២១៨៨០ |
| **ព្រះសីហនុ** | : ០១២ ៦៥៩ ៥៦០ | **តាកែវ** | : ០៩៧ ៩៧៦១ ៥៨៨ |
| **សៀមរាប** | : ០១២ ៦៧៥ ៦៤០ | **រតនគិរី** | : ០៩៧ ៩០៤២ ៥៨៤ |
| **កំពង់ចាម** | : ០១១ ៧៤២ ២២៤ | **ព្រះវិហារ** | : ០១២ ២១៨២៨១ |
| **ស្វាយរៀង** | : ០៩៧ ២៦៥៥ ៩៨៧ | **បាត់ដំបង** | : ០១២ ៦៧៣ ៦៦២ |
| **ព្រៃវែង** | : ០១២ ៦៧១ ៦៤០ | **ស្ទឹងត្រែង** | : ០១២ ៩៦៤ ៤៩៦ |
| **កំពត** | : ០១២ ៨៥៦ ៧២២ | **មណ្ឌលគិរី** | : ០១១ ៨០៤ ៣៤៧ |
| **ប៉ៃលិន** | : ០៨១ ២៥០ ៩១៦ | | |

# វិចារណកថា

អង្គការសហប្រជាជាតិបានកំណត់ក្នុងខែកញ្ញា ឆ្នាំ២០១៥ ជ្រើសរើសគោលដៅអភិវឌ្ឍដោយចីរភាព (គ.អ.ច) ដែលបង្កើតបានជាកម្មវិធីសកល (ទិនានុលេខន៍សម្រាប់ទាំងអស់គ្នា) សំដៅកែលំអជីវភាពរបស់ប្រជាជននៃភពផែនដី ចាប់ពីពេលនេះ រហូតដល់ឆ្នាំ២០៣០។

គោលដៅអភិវឌ្ឍដោយចីរភាព (គ.អ.ច)[១] ប្រកបដោយមហិច្ឆតា និងចំណុះគ្នាទៅវិញទៅមកមានចំនួន១៧ដែលរួមមាន ៖ សកម្មភាពទាក់ទងនឹងបរិយាបន្ន (ការរាប់បញ្ចូលអ្វីមួយផ្សេងទៀត) សមាហរណកម្ម និងសាកលភាព។ សកម្មភាពទាំងនេះ ជាវិធាននាំផ្លូវមិនត្រឹមតែសម្រាប់រដ្ឋាភិបាលទេ ប៉ុន្តែក៏សម្រាប់ផ្នែកឯកជន សង្គមស៊ីវិល និងបុគ្គលម្នាក់ៗផងដែរ ដើម្បីរួមគ្នាជ្រោមជ្រែងចំពោះគម្រោងនេះ សំដៅបំបាត់ភាពក្រីក្រ ការពារភពផែនដី និងធានាវិបុលភាពទូទៅ។

ក្នុងឋានៈជាសមាជិកសកម្មនៃប្រព័ន្ធប្រមូលផ្តុំសាកល UNESCO ផ្តល់វិភាគទានជាពិសេសសម្រាប់គោលដៅអភិវឌ្ឍដោយចីរភាព (គ.អ.ច) មួយចំនួនតាមរយៈការងារស្រាវជ្រាវរបាយការណ៍ប្រកបដោយគំនិតសំខាន់ៗរបស់អ្នកជំនាញ និងថ្នាក់ដឹកនាំរបស់អង្គការដែលជាទូទៅគេទទួលស្គាល់នូវតម្លៃដ៏ខ្ពង់ខ្ពស់នេះ។ សូមកត់សម្គាល់ថា តួនាទីរបស់វប្បធម៌ជាកត្តាគន្លឹះនៃការប្រតិបត្តិកម្មវិធីនេះ។

ផ្អែកលើទំនាក់ទំនងប្រទាក់ក្រឡានៃ គ.អ.ច.១ គឺការបំបាត់ភាពក្រក្រី និង គ.អ.ច.១០ គឺការកាត់បន្ថយវិសមភាព ព្រមទាំងផ្អែកលើភាពជាដៃគូដើម្បីសម្រេច គ.អ.ច១៧ UNESCO ដែលជាអ្នកសម្របសម្រួលកម្មវិធីអប់រំឆ្នាំ២០៣០ ពោលគឺជានាការអប់រំជាបរិយាបន្ន និងធានាសមធម៌នៃគុណភាពព្រមទាំងលើកកម្ពស់ លទ្ធភាពនៃការហាត់រៀនពេញមួយជីវិតសម្រាប់ គ.អ.ច.៤។

UNESCO បង្កើនការខិតខំជាគុណប្រយោជន៍ចំពោះសមភាពភេទ និងស្វ័យភាពយេនឌ័រ គ.អ.ច.៥ ក្នុងគ្រប់កម្មវិធីរបស់ខ្លួន ដែលមានជាអាទិ៍ ការចូលរៀន

[១]គ.អ.ប. = គោកាលអភិវឌ្ឍដោយចិរភាពមាន ១៧ចំណុចដែលកំណត់ដោយអង្គការសហប្រជាជាតិ (ខែកញ្ញា ឆ្នាំ២០១៥)

របស់កុមារី ការចូលរួមធ្វើការងារសម្រេចចិត្តរបស់ស្ត្រី ជាពិសេសលើផ្នែកវិទ្យាសាស្ត្រ និងការលើកទឹកចិត្តស្ត្រីក្នុងឋានៈជាភ្នាក់ងារកែប្រែសង្គមដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សាមកលើស្ត្រីភេទ។

ដោយសារកម្មវិធីស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក និងលើសមត្ថភាពវិទ្យាសាស្ត្របច្ចេកវិទ្យា UNESCO ឈានទៅកែលំអការផ្គត់ផ្គង់ទឹកស្អាត (គ.អ.ច.៦) និងចូលរួមទទួលស្គាល់វិទ្យាសាស្ត្របច្ចេកវិទ្យា និងការកែប្រែថ្មី ព្រោះបើគ្មានផ្នែកទាំងនេះទេ វាក៏គ្មានការអភិវឌ្ឍឋិតថេរ (គ.អ.ច.៩) ដែរ។

UNESCO បង្កើនចំណេះដឹងអំពីភាពសមហេតុផលនៃសាគរសាស្ត្រ និងចូលរួមពង្រឹងសមត្ថភាពគ្រប់គ្រងដោយចីរភាពចំពោះបញ្ហាសមុទ្រ និងឆ្នេរ (គ.អ.ច.១៤)។ UNESCO គាំទ្រការការពារនិងការប្រើប្រាស់ជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិជាពិសេសរមណីយដ្ឋានបេតិកភណ្ឌពិភពលោក (គ.អ.ច.១៥) និងគាំទ្រការខិតខំកាត់បន្ថយ និងសម្របសម្រួលការប្រែប្រួលធាតុអាកាស (គ.អ.ច.១៣)។

UNESCO ចូលរួមយ៉ាងសកម្មក្នុងការបង្កើតទីក្រុងជាបរិយាបន្នមានភាពច្បាស់លាស់ និងភាពធន់នឹងការប៉ះទង្គិចសំដៅការពារបិតិភ័ណ្ឌវប្បធម៌ធម្មជាតិរបស់មនុស្សលោក (គ.អ.ច.១១) UNESCO ប្រកាន់ខ្ជាប់ជំហរជាគុណប្រយោជន៍ដល់ការទទួលជាសាធារណៈនូវព័ត៌មាន និងសន្តិសុខរបស់អ្នកសារព័ត៌មានក៏ដូចជាការលើកតម្កើង អភិបាលកិច្ចល្អនិងនីតិរដ្ឋ (គ.អ.ច.១៦) ដែរ។

គ្រប់គោលដៅខាងលើ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងអនុវត្តប្រកបដោយផ្លែផ្កាព្រមទាំងគ្រោងបន្តនូវគោលដៅអភិវឌ្ឍឋិតថេរដទៃទៀត ដោយជំហរទទួលខុសត្រូវ ដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាជនម៉្យាង និងម៉្យាងទៀតដើម្បីរួមចំណែកក្នុងកម្មវិធីនៃ គ.អ.ច សាកលឆ្នាំ២០៣០ របស់ពិភពលោក៕

*គណៈកម្មាធិការកណ្តាលស.ប.ស.ខ.*

# វប្បធម៌ខ្មែរ



## ប្រទេសកម្ពុជាក្នុងសមាហរណកម្មសហគមន៍អាស៊ានឆ្នាំ២០១៥ (ត)

### ខ-ការរៀបចំខ្លួននៃធនធានមនុស្សរបស់កម្ពុជា

ជាការពិតគោលនយោបាយសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន គឺឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើចំណេះដឹង (economy based on the knowledge)។ ប្រទេសមួយក្នុងចំណោមប្រទេសទាំង១០ គឺប្រទេសសិង្ហបុរី បានរៀបចំខ្លួនក្រោមការដឹកនាំពីលោក លី គាន់យូ (Lee Kuan Yew) ដែលជាបិតានៃអភិវឌ្ឍនភាពសិង្ហបុរី និងជានាយករដ្ឋមន្ត្រីពីឆ្នាំ១៩៥៩ ដល់ឆ្នាំ១៩៩០ អ្វីដែលសំខាន់គឺការអភិវឌ្ឍសេដ្ឋកិច្ច និងសណ្ដាប់ធ្នាប់សាធារណៈ។ សេដ្ឋកិច្ចនៅប្រទេសនេះ គេចាត់ទុកថា នាគសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន ហើយអ្វីដែលប្រទេសនេះខិតខំប្រឹងប្រែងបំផុតនោះគឺ កត្តាធនធានមនុស្សជាកត្តាចម្បងព្រោះគ្មានជម្រើសណាល្អជាងនេះ។ ប្រទេសសិង្ហបុរីគ្មានធនធានធម្មជាតិដូចប្រទេសកម្ពុជាទេ ប៉ុន្តែជម្រើសនៃការបណ្ដុះបណ្ដាលធនធានមនុស្សកម្រិតខ្ពស់បានប្រែក្លាយបញ្ញាញាណ និងក្រមសីលធម៌មនុស្សទៅជាប្រភពចំណូលសេដ្ឋកិច្ចរួមផ្សំជាមួយការគ្រប់គ្រងមានតម្លាភាព គណនេយ្យភាព។

សហគមន៍សេដ្ឋកិច្ចអាស៊ាន គឺជាសហគមន៍ដែលមានទីផ្សារតែមួយ និងមូលដ្ឋានផលិតកម្មតែមួយ និងជាសហគមន៍មួយដែលមានឧត្ដមភាពប្រកួតប្រជែងសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធ្វើសមាហរណកម្មពេញលេញចូលក្នុងសេដ្ឋកិច្ចពិភពលោក។ ដើម្បីសម្រេចបានទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ គេត្រូវសម្រេចឲ្យបាននូវគោលដៅចំនួន៥គឺ លំហូរទំនិញ លំហូរសេវាកម្ម លំហូរវិនិយោគ លំហូរមូលធន និងលំហូរពលកម្មជំនាញ។ ដើម្បីសម្រេចបាននូវតំបន់សេដ្ឋកិច្ចមួយដែលមានឧត្ដមភាពប្រកួតប្រជែងខ្ពស់អាស៊ានត្រូវរៀបចំ និងអនុវត្តប្រកួតប្រជែងគោលនយោបាយការពារអ្នកប្រើប្រាស់កម្មសិទ្ធិបញ្ញា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាំងទន់ និងរឹង និងការរៀបចំនីតិវិធីពន្ធដារ។ លោក Robert v.Longo ជានាយកវិទ្យាស្ថានអន្តរជាតិកម្ពុជាបានបញ្ជាក់ថា អាស៊ានមានប្រជាជនសរុបជាង ៦០០លាននាក់ និងផលិតផលសរុបប្រមាណ៣លានលានដុល្លារ ដែលជាសេដ្ឋកិច្ចធំជាងគេទី៥នៅលើពិភពលោក អាស៊ានជាដៃគូពាណិជ្ជកម្មដ៏ធំ និងជាទីទាក់ទាញវិនិយោគក្នុងពិភពលោក។ ការព្យាករថា ក្រោយ

ពីការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ានត្រឹមឆ្នាំ២០១៧ សហគមន៍នេះនឹងបង្កើតការងារថ្មីប្រមាណ ១៧០លានការងារ ដែលចូលរួមចំណែកយ៉ាងខ្លាំងលើការជំរុញផលិតភាពសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាព និងគុណភាពរស់នៅរបស់ប្រជាជន។ សហគមន៍នេះមិនត្រឹមតែដើរតួនាទីខាងសេដ្ឋកិច្ច និងពាណិជ្ជកម្មប៉ុណ្ណោះទេ តែក៏ដើរតួនាទីស្នូលដើម្បីធានាស្ថិរភាព សន្តិសុខ តុល្យភាពតំបន់ និងពិភពលោកផងដែរដើម្បីឲ្យយុវជនក៏ដូចជាប្រជាជនកម្ពុជាទទួលបានប្រយោជន៍ពីសមាហរណកម្មសហគមន៍អាស៊ាននេះគឺៈ

ក- យុវជនកម្ពុជាគួរសិក្សាភាសាអង់គ្លេសឲ្យបានស្ទាត់ទាំងការនិយាយ អាន ស្ដាប់ និងសរសេរព្រមទាំងភាសារបស់ប្រទេសអាស៊ានមួយទៀតកាន់តែប្រសើរ។ ទោះបីប្រទេសកម្ពុជាធ្លាប់ទទួលបាននូវអាណានិគមនិយមផ្នែកភាសាបារាំងពី(១៨៦៣-១៩៥៣) ហើយមរតកនេះបានដក់ជាប់ជាមួយធនធានមនុស្សជំនាន់មុនសង្គ្រាមក៏ដោយក៏មនុស្សបច្ចុប្បន្នបានចាប់អារម្មណ៍សិក្សាភាសាអង់គ្លេសវិញថ្មីត្បិតតែយើងបានដាក់ភាសានេះក្នុងកម្មវិធីសិក្សាចាប់ពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ននេះក៏ធនធានមនុស្សខាងភាសាអង់គ្លេសនេះនៅមានកម្រិតនៅឡើយដោយសារ កត្តាប្រព័ន្ធអប់រំ កម្មវិធីសិក្សា និងធនធានគ្រូ។ ឆ្នាំសិក្សា២០១៤-២០១៥ កម្មវិធីសិក្សាភាសាអង់គ្លេសត្រូវបានដាក់ឲ្យសិស្សសិក្សាចាប់ពីថ្នាក់ទី៤នៃកម្រិតបឋមសិក្សារហូតដល់ថ្នាក់ឧត្ដមសិក្សា ប៉ុន្តែបញ្ហាក៏នៅចោទឡើងដោយកង្វះខាតនូវធនធានគ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា ខ្វះវិធីសាស្ត្រ និង សម្ភារៈក្នុងការបង្រៀនឲ្យសិស្សអាន ស្ដាប់ និយាយ និងទម្លាប់សរសេរឲ្យបានល្អនោះ ។ គ្រូភាសាអង់គ្លេសដែលមានជំនាញ និងទទួលការបណ្ដុះបណ្ដាលពីជនជាតិម្ចាស់ភាសាច្រើនតែប្រមូលផ្ដុំនៅតែទីក្រុងភ្នំពេញ ទីប្រជុំជន ឬសាលាឯកជន ឬអាចទៅបម្រើការឲ្យក្រុមហ៊ុន អង្គការនានា ព្រោះបានប្រាក់កម្រៃខ្ពស់ជាងសាលារដ្ឋ។ ចំណេះដឹងភាសាអង់គ្លេស គឺតម្រូវឲ្យយុវជនសិស្ស និស្សិតចេះទាំងភាសាអង់គ្លេសទូទៅ និងជំនាញដើម្បីដណ្ដើមទីផ្សារការងារព្រោះសមាជិកអាស៊ានដទៃទៀតហាក់បីកំណត់យកភាសាអង់គ្លេសជាភាសាផ្លូវការទៅហើយ។ ឯកឧត្ដមបណ្ឌិតសភាចារ្យ ស៊ន សំណាង អតីតប្រធានរាជបណ្ឌិត្យសភាកម្ពុជាមានប្រសាសន៍ថា យុវជនកម្ពុជាចាំបាច់ត្រូវតែមានចំណេះដឹងឲ្យបានច្បាស់លាស់បំផុតលើភាសាអង់គ្លេសដើម្បីពន្យល់ឲ្យគេស្គាល់ពីសមត្ថភាពខ្លួនឯង និងពន្យល់ប្រាប់ពីតម្លៃសេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រដល់អ្នកដទៃឲ្យគេមានជំនឿជាក់ផ្ដល់ការងារបង្កើនប្រាក់ចំណូលនិងអាចប្រកួតប្រជែងស្មើមុខស្មើមាត់ជាមួយបុគ្គលិកមកពីបណ្ដាប្រទេសផ្សេងៗក្នុងតំបន់។ ដូច្នេះភាសាអង់គ្លេសគឺជាមូលដ្ឋានគ្រឹះរបស់យុវជនកម្ពុជាដើម្បីត្រៀមខ្លួនសមាហរណកម្មសេដ្ឋកិច្ចក្នុងសហគមន៍អាស៊ាន។ក្រៅពីភាសាអង់គ្លេសយុវជនមិនគួរបោះបង់ចោលនូវភាសាចិនបានទេ ព្រោះថាបើតាមទំហំសេដ្ឋកិច្ច និងតួនាទីចិន និងអាស៊ាន អ្នកវិនិយោគជនជាតិចិនទំនាក់ទំនងខាងប្រវត្តិសាស្ត្រ វប្បធម៌ចិន ក្នុងចំណោមប្រជាជាតិអាស៊ាន នោះភាសាចិននឹងក្លាយជាភាសាទី២ បន្ទាប់ពីភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងពាណិជ្ជកម្មក្នុងតំបន់។

ខ-យុវជនត្រូវសម្រួចមុខជំនាញឯកទេសរបស់ខ្លួនឲ្យបានពិតប្រាកដក្នុងន័យនេះពួកគេត្រូវខិតខំសិក្សាបន្ថែម និងសង្កេតស្វែងយល់ពីតម្រូវការការងារ និងការវិវត្តក្នុងបរិបទធុរកិច្ចជាទូទៅ។

លើសពីនេះទៀត យុវជនកម្ពុជាត្រូវរៀបបើកចិត្តឲ្យទូលាយរៀនពីមនុស្សនៅជុំវិញខ្លួនជាពិសេស ការគិតប្រកបដោយគំនិតច្នៃប្រឌិតដើម្បីប្រមូលបាននូវជំនាញនិងចំណេះដឹងពិតប្រាកដ។ អ្វីដែលជាចំណុចល្អមិនអាចបដិសេធបាននោះគឺយុវជនកម្ពុជាជារួមមាន អត្តចរិតល្អ រួសរាយរាក់ទាក់ និងសង្វាតព្យាយាម។ កម្មវិធីសិក្សាទាំងក្នុងសាលារដ្ឋ និងឯកជនត្រូវតែមានការផ្លាស់ប្តូរទៅតាមស្ថានភាពតម្រូវការទីផ្សារពលកម្មក្នុងតំបន់ ជាពិសេសតាមកម្មវិធីសិក្សារបស់ប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ដូចជាប្រទេសសិង្ហបុរី ប្រទេសថៃជាដើម ដើម្បីឲ្យយុវជនយើងដណ្ដើមបានការងារខ្លះពីបណ្ដាប្រទេសទាំងនោះទាំងផ្នែកកម្រិតជំនាញ និងពលកម្ម។ជំនាញដែលត្រូវបណ្ដុះបណ្ដាលដូចជា ទំនាក់ទំនងអន្តរវប្បធម៌ ជំនាញសរសេរភាសាអង់គ្លេសផ្លូវការ ជំនាញចរចា និងលក់ ជំនាញនិយាយជាសាធារណៈ ជំនាញគ្រប់គ្រង ជំនាញផែនការ ជំនាញICT...។ល។ ជំនាញទាំងអស់នេះសុទ្ធតែប្រទេសមហាអំណាចសេដ្ឋកិច្ចកំពុងអនុវត្តជាពិសេសប្រព័ន្ធព័ត៌មាន បច្ចេក-វិទ្យានេះ ដែលពេញនិយមណាស់ក្នុងយុគសម័យសាកលភាវូបនីយកម្មជាពិសេសកំណើនសេដ្ឋ-កិច្ចជាតិតាមរយៈសកម្មភាពប្រព័ន្ធព័ត៌មានវិទ្យាហើយបានក្លាយជាចំណេះដឹងមួយជំរុញឲ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែល្អប្រសើរ។ ជាមួយគ្នានេះក្រសួងអប់រំនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវសាលាធនធាននៅតាមបណ្ដាខេត្តចាប់ពីឆ្នាំ២០០៥មក។ តាមខេត្តនីមួយៗយ៉ាងហោចណាស់ក៏មានអគារធនធាន១ ឬ២ដែរ។ គោលបំណងនៃការកសាងអគារធនធានតាមវិទ្យា-ល័យគឺតម្រូវឲ្យសិស្សអនុវត្តក្នុងបន្ទប់ពិសោធន៍ **អានឯកសារនៅបណ្ណាល័យនិងបន្ទប់កុំព្យូទ័រ ដែលជាកត្តាចម្បងនៃការ ពង្រឹងសមត្ថភាពជំនាញ។ អគារធនធានចំនួន២៦បាននិងកំពុងដំណើរការរៀន និងបង្រៀនកុំព្យូទ័រ ពិសោធន៍ផ្នែកវិទ្យាសាស្ត្រ និងបណ្ណាល័យនៅអគារធនធាន។ សំដៅឆ្ពោះទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិដោយផ្អែកលើចំណេះដឹង មានន័យថាធនធានមនុស្សដែលមានជំនាញបច្ចេកទេសវិជ្ជាជីវៈ សីលធម៌រស់នៅល្អ ការស្រាវជ្រាវបែបវិទ្យាសាស្ត្រសម្រាប់បម្រើឲ្យសកម្មភាពចម្បងផ្នែកឧស្សាហកម្ម សហគ្រាសខ្នាតតូច និងបច្ចេកវិទ្យាទំនើប កម្មករជំនាញដែលលើកកម្ពស់ជីវភាពរស់នៅកាន់តែល្អប្រសើរ។ គោលនយោបាយអគារធនធាន គឺជាគំនិតផ្ដួចផ្ដើមថ្មីមួយក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមរបស់សាលាក្នុងការផ្ដល់ឱកាសដល់សិស្សានុសិស្ស និងត្រូវបានអភិវឌ្ឍសមត្ថភាពលើការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ប៉ុន្តែលទ្ធផលមិនទាន់បានឆ្លើយតបនឹងគោលដៅឡើយ។ ក្រៅពីមុខវិជ្ជាជំនាញទាំងអស់នេះ យុវជនកម្ពុជាត្រូវចេះដឹង និងស្វែងយល់នូវបណ្ដាមុខវិជ្ជាផ្សេងៗជាច្រើនទៀតដូចជា បញ្ហាសន្តិសុខស្បៀង ប្រព័ន្ធកសិកម្ម និងទីផ្សារ យល់ដឹងពីការអភិវឌ្ឍមហាតំបន់ទន្លេមេគង្គប្រកបដោយនិរន្តរភាព ធនធានមនុស្សក្នុងការអភិវឌ្ឍបរិស្ថានតាមបណ្ដាប្រទេសក្នុងតំបន់ ឥទ្ធិពលវប្បធម៌និងបញ្ហាហានិភ័យ ភូមិមួយផលិតផលមួយ....។ល។ ហើយក៏ត្រូវធ្វើសមា-ហរណកម្មគ្រឹះស្ថានឧត្ដមសិក្សាកម្ពុជាទាំងកម្មវិធីសិក្សា ធនធានគ្រូ និងសិស្ស និស្សិតជាមួយបណ្ដាសាកលវិទ្យាល័យនានាក្នុងអាស៊ានផងដែរ។**

*(នៅមានត)* *ដោយលោក* **គួយ សូគាន**

# ប្រភពនៃការអប់រំក្នុងពិភពលោក (ត)

## ៧.២ ការរួមចំណែកពីមជ្ឈិមសម័យ ចំពោះការអប់រំលោកខាងលិច

### ក.ចំណេះដឹងដែលបានរក្សាទុក និងការរក្សាទុកជាទម្លាប់ដ៏យូរ

អ្នកអប់រំមជ្ឈិមសម័យ បានរួមចំណែកដល់ការអប់រំមជ្ឈិមសម័យ ជាបឋមគឺតាមការរក្សាទុក និងរក្សាជាទម្លាប់នូវចំណេះដឹង នោះគឺថាតាមការបង្ហាញវាជាមួយក្របខ័ណ្ឌដែលបានរៀបចំត្រឹមត្រូវ។ សាលារៀន ព្រះវិហារ វត្ត និងជើងវត្ត ទាំងអស់បានផ្ទេរចំណេះដឹង។ តួយ៉ាងនៃនិទ្នាការនេះ គឺជាសាកលវិទ្យាល័យមជ្ឈិមសម័យ ដែលជាមូលដ្ឋានគ្រឹះសម្រាប់សាកលវិទ្យាល័យទំនើប។ ជាមួយកំពែងទាំងនេះ អ្នកអប់រំមជ្ឈិមសម័យ មិនគ្រាន់តែបានបង្រៀនទេ ប៉ុន្តែថែមទាំងបានរក្សាទុកចំណេះដឹង តាមការកត់ត្រា និងប្រមូលចងក្រងជាក្រមទៀតផងដែរ។

## ៨.មនុស្សនិយមក្លាសុីក(តន្តី)នៅបុនសម័យ

### ក.ការនិយមឡើងវិញទិដ្ឋភាពនៃក្លាសុីក

បុនសម័យ ដែលបានចាប់ផ្តើមក្នុងសតវត្សទី១៤ហើយឈានដល់ចំណុចកំពូលក្នុងសតវត្សទី១៥ ដោយកត់សម្គាល់ទៅលើការនិយមឡើងវិញនូវទិដ្ឋភាពមនុស្សនិយមនៃអក្សរសាស្ត្រឡាតាំង និងក្រិក។ វាត្រូវបានគេចាត់ទុកជា រយៈពេលអន្តរកាលរវាងមជ្ឈិមសម័យ និងសម័យទំនើប។ អ្នកប្រាជ្ញបុនសម័យ នៃមនុស្សនិយមក្លាសុីក ដូចជាការអប់រំនិងសាលារៀនមជ្ឈិមសម័យ បានបង្កើតប្រភពជំនាញរបស់គេក្នុងអតីតកាល និងសង្កត់ធ្ងន់លើអក្សរសិល្ប៍ក្លាសុីក។ ទោះជាយ៉ាងនេះក្តី មិនដូចទស្សនវិជ្ជាមជ្ឈិមសម័យទេ ពួកមនុស្សនិយមក្លាសុីក យកចិត្តទុកដាក់តែទៅលើអក្សសិល្ប៍ជាងសាសនវិទ្យា[៣៦]។

### ខ.មនុស្សនិយមបែបក្លាសុីកក្នុងប្រទេសអុីតាលី

បុនសម័យ ត្រូវបានគេកត់សម្គាល់ជាពិសេសក្នុងប្រទេសអុីតាលី ជាកន្លែងដែលការរស់ឡើងវិញខាងពាណិជ្ជកម្ម ផ្តល់មូលនិធិដ៏ច្រើនពីសិល្បៈ និងអក្សរសាស្ត្រ។ មនុស្សនិយមក្លាសុីកអុីតាលី ដោយចាត់ទុកខ្លួនឯងជាវរជនអក្សរសាស្ត្រនោះ គឺត្រូវបានស្វ័យប្រកាសថា **ឆ្មាំចំណេះដឹង** (custodians of knowledge)។ នៅអុីតាលី ស្នាដៃ Dante, Petrarch, និងBoccaccio បានឆ្លុះបញ្ចាំងការនិយមឡើងវិញផ្នែកអក្សរសាស្ត្រមនុស្សនិយម។ ពួកអភិជនអុីតាលី បានបង្កើតសាលារៀនមនុស្សនិយម ដើម្បីរៀបចំកុមារក្នុងការសិក្សាបែបក្លាសុីកដែលត្រូវនិយមឡើងវិញ។

### គ.គំរូនៃក្រុមមន្ត្រីវាំង

ដោយជំទាស់ទៅនឹងប្រព័ន្ធទស្សនវិជ្ជាសុទ្ធានសាសនា អ្នកអប់រំមនុស្សនិយមក្លាសុីក បានត្រឡប់សាជាថ្មីទៅរក Isocrates និង Quintillian ។ ក្នុងអក្សរសិល្ប៍ក្រិក និងឡាតាំង គេបានរកឃើញគំរូនៃឧត្តមភាពអក្សរសាស្ត្រ និង រចនាបទ ឧត្តមគតិនៃមនុស្សដែលមានការអប់រំ និងទស្សនៈគតិបណ្ឌិតបុរាណកាលដែលគួរឲ្យស្រឡាញ់ជាទីបំផុត។ សម្រាប់អ្នកអប់រំមនុស្សនិយម

[៣៦] J.R. Hale, Renaissance Europe (New York: Basli Blackwell, 2000).

ពួកក្រុមមន្ត្រីវាំង បានក្លាយជាមនុស្សគម្រូដែលមានការអប់រំ។ មនុស្សម្នាក់ដែលមានបែបបទ និងភាពថ្លៃថ្នូរ ត្រូវអប់រំដោយសេរីក្នុងអក្សរសាស្ត្រក្លាស៊ីក ក្រុមមន្ត្រីវាំង គឺជាអ្នកការទូតដ៏ប៉ិនប្រសប់ដែលអាចធ្វើជាអ្នកគ្រប់គ្រងដ៏ល្អក្នុងកិច្ចការរបស់រដ្ឋ។ Baldesar Castigliore (1478-1529) បានពិពណ៌នាក្រុមមន្ត្រីវាំង និងការអប់រំដែលមានសារៈសំខាន់ដល់អក្សរសាស្ត្រក្រិក និងឡាតាំង ព្រមទាំងសេចក្តីគួរសមតាមរបៀបក្រុមមន្ត្រីវាំងក្នុងសៀវភៅរបស់គាត់ The Book of the Courtiers[៣៧]។

**ឃ.ការគិតដ៏ល្អិតល្អន់**

អ្នកអប់រំមនុស្សនិយមបុនសម័យ ជាមនុស្សដែលមានការចេះដឹងខាងអក្សរសាស្ត្រ ដូចជាអ្នកនិពន្ធ កវី អ្នកបកប្រែនិងអ្នករិះគន់។ គ្រូបង្រៀនដែលជាសិល្បករ អ្នករិះគន់សង្គមនិងការនិយមពួកគេនាំមកនូវការប៉ិនប្រសប់កំប្លែង សម្រស់និងការនិពន្ធដៀលត្មះ ព្រមទាំងពហុសូតភាពចំពោះការងាររបស់ពួកគេ។ ដោយប្រមើលមើលការបញ្ជាក់អះអាងនាពេលសព្វថ្ងៃនេះ ទៅលើការគិតល្អិតល្អន់នោះ ពួកគេស្វែងរកអប់រំមនុស្សដែលមានចិត្តគិតបានល្អិតល្អន់ ដែលអាចប្រឆាំងនឹងទំនៀមទម្លាប់ដែលមានរួចហើយ បង្ហាញនិងកែភាពសមរម្យក្នុងអក្សរសាស្ត្រនិងជីវិត។ នៅក្នុងអឺរ៉ុបប៉ែកខាងជើងពួកអ្នកប្រាជ្ញមនុស្សនិយមបានពិនិត្យយ៉ាងល្អិតល្អន់នូវស្នាដៃសាសនវិទ្យា-មជ្ឈិមសម័យ។

ប៉ុន្តែពួកមនុស្សនិយមបុនសម័យ ជាញឹកញាប់ បានចៀសវាងរវាងខ្លួនឯង និងចំនួនមនុស្សដ៏ច្រើនដោយដកយកបញ្ញត្តិដ៏សំខាន់នៃធម្មជាតិពីអក្សរសាស្ត្រដែលមានវ័យចំណាស់ដោយប្រុងប្រយ័ត្ន។ ស្រាទំពាំងបាយជូរដែលបានផលិតដ៏ល្អ ត្រូវបានគេប្រើប្រាស់ដើម្បីលំអអាហារល្ងាចដ៏ថ្លៃថ្នូរនោះ។ ការអប់រំមនុស្សនិយម គឺជាមនុស្សដែលស្គាល់ពីស្ថានភាពពិតប្រាកដ។ វាមិនត្រូវបានគេផ្តល់ឲ្យជនគ្រប់គ្នានោះទេ តែរក្សាទុកសម្រាប់វរជន។

**ខ.ការចូលរៀនដែលមានកំណត់**

បុនសម័យ មិនបានពង្រីកការយកចិត្តទុកដាក់ដល់សាលារៀនខ្លាំងពេកទេ។ ពួកមនុស្សនិយមដែលបានត្រៀមរៀបចំទុក និងសាលាមធ្យមសិក្សាបានអប់រំកុមារអភិជន និងវណ្ណៈខ្ពស់។ សាលាបឋមសិក្សាបានបម្រើវណ្ណៈពាណិជ្ជកម្មកណ្តាល។ កុមារដែលមានវណ្ណៈសេដ្ឋកិច្ចសង្គមទាប បានទទួលការអប់រំក្នុងប្រព័ន្ធតិចតួច។

**៨.១.Erasmus: អ្នករិះគន់ និងមនុស្សនិយមវិទូ**

**ក.Erasmus អំពីការអប់រំ**

**Desiderius Erasmus (1465-1536)** ជាមនុស្សនិយមវិទូក្លាស៊ីកដែលនាំមុខគេនៃបុនសម័យដែលត្រូវបានពណ៌នាថាជាគ្រូគំរូក្នុងនាមជាមនុស្សនិយមសកល[៣៨]។ តវិយាបថរបស់គ្រូនិយមវិទូសកលគួរតែផ្តល់នូវវិធានបឋមក្នុងសិល្បៈសេរី ជាពិសេសក្នុងមុខវិជ្ជាដូចជាអក្សរសាស្ត្រ ភាសា ប្រវត្តិវិទ្យា និងសាសនាដែលមានប្រយោជន៍ក្នុងការបកប្រែស្នាដៃក្លាស៊ីក។ ដូចជាQuintillian ដែរ

[៣៧] Baldesar Castigliore, The Book of the Courtier, trans. C.S. Singleton (New York: Doubleday, 1959). ACommentary is Peter Burke, The Fortunes of Courtiers: The European Reception of Castigliore's Cortigiano (University Park: Pennsylvania State Univiersity Press, 1996)

[៣៨] For Biographies of Erasmus, see Leon E. Halkin, Erasmus: A Critical Biography (Oxford, U.K., and Cambridge, Mass: Basil Blackwell, 1993); and James McConics, Eramus (New York: Oxford University Press, 1991)

Erasmus មានទស្សនៈទូលំទូលាយពីការអប់រំ ការផ្ដល់ដំបូន្មានដល់មាតាបិតា ដែលការអប់រំនៅសម័យដើម មានភាពចាំបាច់ក្នុងការបង្កើតឥរិយាបថ និងអាកប្បកិរិយាកុមារ សម្រាប់ការអប់រំសម័យក្រោយ។ កុមារត្រូវបានគេផ្ដល់សិទ្ធិឲ្យមាតាបិតា និងគ្រូ ដែលជាគម្រូនៃសេចក្ដីគួរសម (Civility) និងវប្បធម៌។

### ខ.ការលើកកម្ពស់សៀវភៅ និងអក្សរសិល្ប៍

ក្នុងនាមជាមនុស្ស Erasmus មានការព្រួយបារម្ភបំផុតជាមួយការបង្រៀនអក្សរសិល្ប៍។ គាត់បានផ្ដល់យោបល់ថា ការជំរុញសិស្សឲ្យអានសៀវភៅល្អៗ តាមការឲ្យពួកគេស្រាវជ្រាវអត្ថន័យរបស់អ្នកនិពន្ធ នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ គាត់បានលើកទឹកចិត្តគ្រូបង្រៀនឲ្យប្រើប្រាស់ការសន្ទនា ល្បែង និងសកម្មភាពទាំងឡាយ ដើម្បីពន្យល់អត្ថន័យនៃសៀវភៅ។ Erasmus បានអភិវឌ្ឍវិធីដូចតទៅ ដើម្បីបង្រៀនអក្សរសិល្ប៍៖

១. បង្ហាញជីវប្រវត្តិរបស់អ្នកនិពន្ធ។
២. កំណត់អត្តសញ្ញាណប្រភេទនៃសៀវភៅ។
៣. ពិភាក្សាដំណើរសាច់រឿង។
៤. ឆ្លុះបញ្ចាំងទៅលើការអនុវត្តផ្នែកទស្សនវិជ្ជា និងសីលធម៌របស់សៀវភៅ។
៥. វិភាគរចនាបទនិពន្ធរបស់អ្នកនិពន្ធ[៣៩]។

### គ.ការប្រឆាំងជំទាស់នឹងអំពើហិង្សា

ការជំទាស់របស់ Erasmus ចំពោះសង្គ្រាម និងហិង្សា ត្រូវបានបង្ហាញឲ្យឃើញក្នុងសៀវភៅរបស់គាត់មានឈ្មោះថា ការអប់រំព្រះអង្គម្ចាស់ដែលកាន់សាសនាគ្រិស្ត (១៥១៦) (The Education of the Christian Prince)[៤០]។ គាត់បានផ្ដល់ដំបូន្មានដល់អ្នកទាំងឡាយ ដែលនឹងធ្វើជាគ្រូបង្រៀនទោលដល់ព្រះអង្គម្ចាស់ ដើម្បីឲ្យជឿជាក់ថា ព្រះអង្គបានសិក្សាបានច្រើនអំពីប្រជាជននៃព្រះរាជាណាចក្ររបស់ព្រះអង្គ ដូចជាប្រពៃណី ទំនៀមទម្លាប់ ស្នាដៃ និងបញ្ហាទាំងឡាយ។ មិនដូចនោះ Machiavelli ដែលបានអះអាងថា ព្រះរាជាគួរតែគ្រប់គ្រងដោយសេចក្ដីកោតក្រែងនិងភាពប៉ិនប្រសប់ ឬសម្របសម្រួលនោះ Erasmus បានផ្ដល់ដំបូន្មានដល់ព្រះអង្គម្ចាស់ ឲ្យទទួលបានសេចក្ដីស្រឡាញ់ពីមុខវិជ្ជារបស់ខ្លួន ហើយនឹងសិក្សាសិល្បៈនៃសន្តិភាព ជាពិសេសការទូត និងចៀសវាងសង្គ្រាម។

## ៨.២.ចុងសម័យនៃការអប់រំលោកខាងលិច

### ក. ការបញ្ជាក់ន័យអក្សរសិល្ប៍ និងភាសាក្លាស៊ិក

ពួកមនុស្សនិយមវិទូចុងសម័យ បានសង្កត់ធ្ងន់ទៅលើចំណេះដឹងភាសាក្រិក និងឡាតាំងថាជាសញ្ញាសម្គាល់ពិតនៃមនុស្សដែលមានការអប់រំ។ អស់រយៈពេលជាច្រើនសតវត្សចំណូលចិត្តមនុស្សនិយមវិទូក្លាស៊ិក បានបង្កើតការអប់រំមធ្យមសិក្សា និងឧត្តមសិក្សាលោកខាងលិច។ នៅទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិក សាលាវិជ្ជាជីវៈ មហាវិទ្យាល័យ និងសកលវិទ្យាល័យជាច្រើន

[៣៩] William H. Woodward, Desiderius Erasmus: Concerning the Aim and Method of Education (New York: Teachers College Press, 1994).

[៤០] Robert D. Sider and john B.Payne, eds. Collected Works of Erasmus (Toronto: University of Toronto Press, 1990).

តម្រូវឲ្យមានចំណេះដឹងខាងភាសាឡាតាំង សម្រាប់ការចូលរៀនរហូតដល់ចុងសតវត្សទី១៩។

**ខ. ចំណេះដឹងខាងមនុស្សនិយម (មិនមែនខាងវិទ្យាសាស្ត្រ)**

វាជារឿងសំខាន់ផងដែរ ដើម្បីកត់សម្គាល់ថា Erasmus និងអ្នកអប់រំមុនសម័យផ្សេងទៀត កំពុងជំរុញដល់បញ្ញត្តិនៃចំណេះដឹងខាងមនុស្សនិយម ឬមជ្ឈមណ្ឌលមនុស្ស។ ជាជាងការឈានទៅដល់ប្រធានបទមនុស្សនិយមរបស់គេ តាមរយៈការសង្កេតបែបវិទ្យាសាស្ត្រនោះ អ្នកអប់រំមនុស្សនិយម បានស្រាវជ្រាវការយកចិត្តទុកដាក់របស់គេ តាមរយៈអក្សរសិល្ប៍។ ក្រោយមកគោលវិធីនេះអាចទប់ទល់បាននឹងកំណែទម្រង់របស់ Rousseau, Comenius, Pestalozzi, និង Dewey (បកស្រាយពេលក្រោយ) ដែលអ្នកទាំងអស់គ្នាបានពោលអះអាងប្រឆាំងនឹងការបង្រៀន ដែលបានសង្កត់ធ្ងន់ទៅលើអក្សរសិល្ប៍ នៅពេលដែលមិនបានយកចិត្តទុកដាក់ទៅលើបទពិសោធន៍។

**គ. រោងពុម្ព**

ការច្នៃប្រឌិតរោងពុម្ពក្នុងឆ្នាំ១៤២៣ ក្នុងទ្វីបអឺរ៉ុប បានធ្វើឲ្យជឿនលឿនដល់អក្ខរកម្ម និងការសិក្សាអប់រំគួរឲ្យចាប់ចិត្ត។មុនពេលមានរោងពុម្ព សិស្សបានចម្លងដោយផ្ចិតផ្ចង់នូវការសរសេរតាមអានពីគ្រូ។ ការបង្រៀននៅសកលវិទ្យាល័យគឺជាបទពិសោធន៍ពិសេសចាំបាច់ដែលក្នុងនោះសិស្ស ឬនិស្សិត កត់ត្រាពាក្យសម្ដីរបស់សាស្ត្រាចារ្យរបស់ពួកគេ។

ត្រឹមពាក់កណ្ដាលសតវត្សទី១៥ ពួកអឺរ៉ុបបានឆ្លងកាត់នូវបទពិសោធន៍ ជាមួយនឹងប្រភេទលោហធាតុដែលអាចធ្វើចលនាបាន។ Johannes Gutenberg ជាងទងជាតិអាល្លឺម៉ង់ម្នាក់ បានច្នៃប្រឌិតលោហធាតុដ៏រឹងមាំ ដើម្បីបង្កើតអក្សរសម្រាប់រោងពុម្ព។ គម្ពីររបស់គាត់ក្នុងឆ្នាំ១៤៥៥ គឺជាសៀវភៅលើកដំបូង ដែលបានបោះពុម្ពបែបនោះ។ ការបោះពុម្ព បានរាលដាលពាសពេញទ្វីបអឺរ៉ុប ដោយផលិតផលកើនឡើងច្រើនជាងមុន ហើយនិងកាត់បន្ថយចំណាយទៅលើសៀវភៅ។ វាបង្កើតព័ត៌មាន ដែលអាចឈានទៅដល់ការអានដែលមានភាពទូលំទូលាយជាងមុន[៩១]។ វាជានវកម្មបច្ចេកទេសដ៏សំខាន់ដែលផលរបស់វា នាំមកដល់ការសាយភាយព័ត៌មានកុំព្យូទ័រ។

*(នៅមានត)* *អនុបណ្ឌិត* **សូ សុធីរ**

"ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិ
ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណប់បង្ហាញចោរ។"

**បុរាណភាសិត**

[៩១] Lucien Febvre and Henri-Jean Martin, The Coming of the Book: The Impact of Printing, 1450-1800 (London: Verso, 1990

# វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ(ត)

**៣- តើអ្នកណាជាអ្នកកសាងវត្តអារាម?**

ដូចបានបញ្ជាក់ស្រាប់រួចមកហើយថា ប្រជាជនខ្មែរបានផ្សារភ្ជាប់ខ្លួនទៅនឹងវត្តអារាមតាំងពីកំណើត។ ទំនាក់ទំនងរវាងវត្តអារាមនឹងជីវភាពរស់នៅរបស់ប្រជាជនខ្មែរ មានភាពរឹងមាំណាស់ មិនអាចកាត់ផ្ដាច់បានឡើយ។

វត្តជារបស់ឧបាសកឧបាសិកាពុទ្ធបរិស័ទ ពោលគឺប្រជាជនក្នុងភូមិ ស្រុកនៅជុំវិញវត្តនោះ។ ប្រជាជនជាអ្នកកសាងវត្ត គេចាត់ទុកវត្តជាសម្បត្តិរួមរបស់គេ។ ព្រះសង្ឃជាអ្នកទ្រទ្រង់ថែរក្សាវត្តអារាម។

នៅសម័យបុរាណ ពេលដែលដីធ្លីនៅទូលាយ គេនាំគ្នាជ្រើសរើសរកដីខ្ពស់ មានព្រៃឈើ មានទឹកនៅជិតធ្វើជាវត្ត ឬគេតាំងវត្តនៅកន្លែងដែលប្រជាជនជឿថាមានខ្មោច ព្រាយ បិសាចដែលតែងតែមកយាយីដល់ជីវភាពរស់នៅរបស់ប្រជាជន។

ប៉ុន្តែក្រោយមក ពេលដែលដីធ្លីកាន់តែចង្អៀត ប្រជាជនកាន់តែច្រើន វត្តអារាមក៏បំបែកខ្លួនទៅតាមកំណើនរបស់ប្រជាជនដែរ គឺប្រជាជនដែលចង់បានវត្តសម្រាប់គោរពប្រតិបត្តិនៅជិតផ្ទះខ្លួនក៏នាំគ្នាកសាងវត្តថ្មីទៀត។

គេអាចកសាងវត្ត ដោយសារមានសប្បុរសជនធ្វើអំណោយ ដីធ្លី ឬប្រាក់កាស ឬក៏ទ្រព្យសម្បត្តិដើម្បីទិញដីធ្លី ទិញសម្ភារៈសំណង់ផ្សេងៗ។

ជួនកាលអំណោយរបស់សប្បុរសជនម្នាក់ ក៏ល្មមអាចសង់វត្តមួយបាន ជួនកាលគេនាំគ្នាកាត់ដីធ្លីដែលនៅជាប់គ្នា ឬផ្លាស់ប្ដូរដីគ្នា រួមបញ្ចូលគ្នាឲ្យបានធំល្មមនឹងកសាងវត្តបាន។

ចំពោះការសាងសង់កុដិ វិហារ សាលាបុណ្យ សាលាបាលី...និយាយរួម គឺសំណង់ស្ថាបត្យ-កម្មក្នុងវត្តទាំងមូល គឺពុទ្ធបរិស័ទជាអ្នក ជួយឧបត្ថម្ភនិងរ៉ាប់រង។

ពេលសង់បានអគារហើយ គឺប្រជាជនជាអ្នកសម្រេចថា ត្រូវនិមន្តព្រះសង្ឃអង្គណាមកធ្វើជាចៅអធិការ។ គណៈកម្មការ អាចារ្យវត្ត ក៏ត្រូវបង្កើតឡើងដែរដើម្បីបន្តទ្រទ្រង់វត្ត ជួយមើលដំណើរការរបស់វត្ត និងការដឹកនាំវត្តរបស់ចៅអធិការ។ ភារកិច្ចរបស់អាចារ្យ និងគណៈកម្មការវត្តគឺបន្តជួយសាងសង់សំណង់ទាំងឡាយរបស់វត្ត កែលម្អ ជួសជុលសំណង់ចាស់សាងសង់សំណង់ថ្មី។

ភារកិច្ចទីពីរ របស់ឧបាសកឧបាសិកា គឺការឃ្លាំមើលការគោរពប្រតិបត្តិ ធម្មវិន័យរបស់សង្ឃក្នុងវត្ត។

- តើមានភាពបរិសុទ្ធឬទេ?
- តើត្រឹមត្រូវតាមធម្មវិន័យនិងសិក្ខាបទឬទេ?
- តើការដឹកនាំរបស់គណៈសង្ឃ បានត្រឹមត្រូវល្អដែរឬទេ?

- តើវត្តបម្រើផលប្រយោជន៍រួមរបស់ពុទ្ធបរិស័ទបានតាមសេចក្ដីប្រាថ្នាដែរឬទេ?

ប្រសិនបើមានរឿងអាស្រូវណាមួយកើតឡើងនោះមិនអាចកំបាំងនឹងភ្នែករបស់ប្រជាជនបានទេ ព្រោះវត្តជាវត្តរបស់គេ គេមានសិទ្ធិ និងភារកិច្ចរក្សាភាពថ្លៃថ្នូរ និងកិត្យានុភាពរបស់វត្តគេ។

ដើម្បីឲ្យវត្តនៅក្នុងភូមិរបស់គេរស់រានរីកចម្រើនស្ថិតស្ថេរ ប្រជាជនតែងបរិច្ចាគកូនចៅរបស់គេឲ្យបួសជាសង្ឃ ដើម្បីបន្តដឹកនាំវត្តពីជំនាន់មួយទៅជំនាន់មួយទៀត។

**៤- តើវត្តអារាមផ្ដល់អ្វីខ្លះឲ្យប្រជាជនវិញ?**

**ក- វត្តអារាមជាទីតាំងនៃព្រះពុទ្ធសាសនា ដែលជាទីពឹងពំនាក់របស់ប្រជាជនគ្រប់ៗរូប**

- ព្រះសង្ឃជួយប្រជាជន ឲ្យរំដោះផុតពីការភ័យខ្លាច តាមរយៈការសូត្រមន្តផ្សេងៗ។
- ព្រះធម៌ធ្វើឲ្យពុទ្ធបរិស័ទស្ងប់រំងាប់ រំដោះខ្លួនពីសេចក្ដីទុក្ខសោកទាំងឡាយ។
- ព្រះធម៌នាំពុទ្ធបរិស័ទឲ្យដើរតាមផ្លូវត្រូវ មជ្ឈិមប្បដិបទា មានសីល(មានទាន)បញ្ញា សមាធិ មានអដ្ឋង្គិកមគ្គជាអាទិ៍។
- វត្តអារាម ជាកន្លែងស្ងប់រំងាប់ចិត្តឲ្យផុតកង្វល់ក្នុងជីវិត ដែលពោរពេញទៅដោយអវិជ្ជា តណ្ហា សេចក្ដីលោភ ហិង្សា សេចក្ដីច្រណែនឈ្នានីស អំពើពាល អំពើឃោរឃៅ ការជិះជាន់កេងប្រវ័ញ្ចនិងការកាប់សម្លាប់ ពោលគឺសង្គ្រាមនិងអសន្តិសុខ។មនុស្សយើង ដើម្បីរស់នៅត្រូវតស៊ូក្នុងជីវិតរបស់ខ្លួន។

ការតស៊ូ តែងប៉ះទង្គិច ការប៉ះទង្គិចនាំឲ្យមានទំនាស់មិនចេះចប់។ ទំនាស់នេះនាំឲ្យមានវិបត្តិទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត។ ម៉្យាងទៀតមនុស្សកើតមកមាន «កម្ម» មកជាមួយ ហើយកម្មនេះអាចផ្ដល់សេចក្ដីសុខឬទុក្ខ។ ប៉ុន្តែសេចក្ដីទុក្ខជាមរតក ជាសច្ចធម៌ដែលមនុស្សគ្រប់រូបត្រូវទទួល ពិសេសគឺទុក្ខដែលកើតមកពីសេចក្ដីកើតស្លាប់។ មនុស្សភ័យខ្លាចសេចក្ដីស្លាប់ណាស់ តែមនុស្សមិនខ្លាចប្រព្រឹត្តិអំពើដែលនាំឲ្យទៅរកសេចក្ដីស្លាប់នោះទេ។

អ្នកភ័យខ្លាចនឹងសេចក្ដីស្លាប់ អ្នកស្អប់ខ្ពើមអំពើបាប អ្នកចង់សាងអំពើល្អ តែងតែទៅពឹងវត្ត។

**ខ- វត្តអារាមជាមន្ទីរពេទ្យខាងផ្លូវចិត្តរបស់ពុទ្ធបរិស័ទ**

- ព្រះសង្ឃនិងព្រះធម៌អាចជួយព្យាបាល ជួយពន្យល់ពុទ្ធបរិស័ទអ្នកមានទុក្ខ មានកង្វល់រំលត់ទុក្ខព្រួយបាន។ ពេលមានកើតហេតុមិនល្អនៅតាមគ្រួសារក្ដី នៅភូមិក្ដីគេតែងនិមន្តព្រះសង្ឃទៅជួយដោះស្រាយ។
- គ្រប់ពិធីទាំងអស់នៅក្នុងគ្រួសារតាំងពីកើតរហូតដល់ស្លាប់គេមិនដែលចោលព្រះសង្ឃឡើយ។

**គ- វត្តអារាមជាកន្លែងជ្រកកោនរបស់អ្នកកម្សត់ទុរគត**

គ្រប់វត្តអារាម តែងទទួលចិញ្ចឹមកុមារកំព្រាឥតទីពឹង ព្រមទាំងសិស្សានុសិស្ស ជាកូនចៅរបស់ប្រជាជនដែលនៅទីឆ្ងាយ ខ្វះជម្រក ខ្វះទីសំណាក់ដើម្បីបន្តការសិក្សា។

ជនអនាថា ចាស់ជរា ជនអភ័ព្វឥតសំណាង គ្មានកូនចៅជួយទំនុកបម្រុង តែងទៅជ្រកនៅក្នុងវត្ត ដើម្បីរៀនធម៌អាថ៌ ដែលជាសំណាក់ចុងក្រោយនៃជីវិតរបស់ខ្លួន។

**ឃ- វត្តអារាមជាជម្រកនិរភ័យរបស់សត្វម្រឹគីម្រឹគា បក្សាបក្សី មច្ឆជាតិ និងជាកន្លែងរក្សាការពារពូជឈើព្រៃឲ្យគង់វង្ស វត្តជាសួនច្បារ ជាអារាម ជារមណីយដ្ឋាន អាចលម្ហែអារម្មណ៍បាន**

ការបំផ្លាញព្រៃឈើរបស់វត្តអារាម ធ្វើឲ្យបក្សាបក្សីបាត់ជម្រក ហើយក៏ហើរទៅកន្លែងផ្សេងៗ។ ការបំផ្លាញវត្ត ធ្វើឲ្យមច្ឆជាតិ ព្រៃឈើ និងបក្សាបក្សីដែលជាសម្បត្តិធម្មជាតិមានតម្លៃសម្រាប់ទ្រទ្រង់ជីវិតមនុស្ស វិនាសសាបសូន្យ ឬក៏ផុតពូជតែម្តង។

**ខ-វត្តអារាមជាកន្លែងកប់ចោលនូវទំនាស់ និងបង្កើតភាពស្មើគ្នា**

ពេលចូលទៅដល់វត្ត មនុស្សទាំងអស់គ្នាមានឈ្មោះថាឧបាសក ឧបាសិកា ពេលនោះទោះបីជាមន្ត្រីរាជការមានឋានៈណាក៏ដោយ ក៏ត្រូវថ្វាយបង្គំព្រះពុទ្ធបដិមា ថ្វាយបង្គំព្រះសង្ឃដូចគ្នា។ វត្តអារាមជាកន្លែងដែលឋានៈសង្គមទាំងឡាយត្រូវរលាយចូលគ្នា។ វត្តជាកន្លែងធ្វើឲ្យមនុស្សគ្រប់ស្រទាប់ខិតចូលជិតគ្នា យល់អធ្យាស្រ័យគ្នា អនុគ្រោះឲ្យគ្នាដោយអំណាចនៃព្រះធម៌ នៃធម៌អហិង្សា វីរិយៈ ខន្តី និងភាពទន់ភ្លន់...។

ហេតុនេះ ព្រះសង្ឃប្រកាន់ទសពិធរាជធម៌ និងព្រហ្មវិហារធម៌ឲ្យបានដើម្បីជួយពុទ្ធបរិស័ទឲ្យបានស្មើៗគ្នា ដោយឥតរើសអើង ឥតប្រកាន់បក្សពួក ឥតប្រកាន់និន្នាការនយោបាយ ប្រកាន់ពណ៌សម្បុរ ប្រកាន់វណ្ណភាពឡើយ។

**ច- វត្តអារាមជាចំណុចកណ្តាលនៃផ្លូវសាមគ្គីភាពជាតិនិងប្រជាធិតេយ្យ**

គ្មានកន្លែងណាដែលនាំប្រជាជនខ្មែរទៅរកសាមគ្គីភាព និងប្រជាធិបតេយ្យបានល្អដូចវត្តអារាមនោះទេ។ ព្រះសង្ឃបានធ្វើគំរូមុនគេក្នុងការរក្សាសាមគ្គីភាព និងប្រជាធិបតេយ្យ។ រីឯប្រជាជនក៏រៀនសូត្រធម៌ទាំងពីរនេះពីវត្តអារាមដែរ។

**ឆ- វត្តអារាមជាកន្លែងការពារសិទ្ធិរបស់ប្រជាជន**

នៅសម័យអាណានិគមបារាំង វត្តអារាមបានជួយលាក់បំពួនជនអ្នកស្នេហាជាតិ ដែលបះបោរប្រឆាំងបារាំង និងមនុស្សដែលត្រូវរដ្ឋការបារាំងចោទថាជាអ្នកមានទោស។

ក្រោយមកចៅអធិការវត្ត អាចមានសិទ្ធិបិណ្ឌបាត្រយកអ្នកទោសទៅអប់រំឲ្យកែប្រែអត្តចរិតសីលធម៌អ្នកទោសទាំងនោះបាន។ ដូច្នេះវត្តក្លាយទៅជាមណ្ឌលកែប្រែ និងអប់រំឡើងវិញរបស់ប្រជាជន។

គេតែងយកជនខិលខូច ជនប្រមឹក ជនពាលាអាវ៉ាសែ ទៅប្រគេនព្រះសង្ឃឲ្យជួយអប់រំ៕

*(នៅមានត)*

*អក្សរសាស្ត្រពុទ្ធសាសនា*

*និពន្ធដោយលោក* **ឃី ឆន់**



# ចិត្តវិទ្យាអប់រំ

## មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត)

- គិតគូរ និងរៀបចំសព្វគ្រប់ជានិច្ច ទាំងសម្ភារ ទាំងពេលវេលាសម្រាប់ការសិក្សារបស់កូន
- បង្កឱកាស ឬលើកទឹកចិត្តកូន ដោយស្ដាប់កូននិយាយមុនដំណោះស្រាយបញ្ហានីមួយៗ និងគ្មានការភូតកុហក កុំបង្អាប់ កុំចំអក...កុំបន្ទាបបន្ថោកមាក់ងាយ....ឬសម្ដីអសុរោះ(ក្នុងខ្លឹមសារហិង្សាដែលបានវិភាគខាងដើម) ទាំងនេះក៏ដើម្បីផ្ដល់នូវស្មារតីមុតមាំ ដែលមនុស្សគ្រប់រូបត្រូវការបំផុត។
- ឲ្យកូនស្និទ្ធជិតនៅជិតលោកអ្នកដែលកំពុងធ្វើការងារផ្ទះ ឬមើលសៀវភៅ ឬអានសៀវភៅឲ្យកូនស្ដាប់ ឬក៏ឲ្យកូនជាអ្នកអានឲ្យលោកអ្នកស្ដាប់។ ព្រមជាមួយនេះ បង្កើតបានសេចក្ដីឱហាតធ្វើការ ឱហាតរៀន និងបង្កើនសមត្ថភាពបញ្ញារបស់កូន។

**ឱហាត** កិ.សង្វាតជានិច្ច, សម្ដី: *ឱហាតរៀន ឱហាតធ្វើការ។* គុ.ដែលមានសេចក្ដីសង្វាតជានិច្ច ដែលសម្ដី: *មនុស្សឱហាត(ព.កា) រីមនុស្ស សម្ដីសង្វាត ព្យាយាមមាំមួន កាន់ការអ្វី កាន់យ៉ាងខ្ជាប់ខ្ជួន រមែងញ៉ាំងខ្លួន ឲ្យមានទ្រព្យធន។* ឬមួយបែបទៀតថា: *ហៃបុត្រធីតា រីឯប្រាជ្ញា ពុំមែនកើតឯង លុះតែឱហាត រៀនសូត្រជាក់ស្ដែង ទើបយើងខ្លួនឯង ប្រទះប្រាជ្ញា។ ដូចទុំមានប្រេង ដាក់ចោលលេងៗ ឥតស្លឲ្យវា បញ្ចេញប្រេងឲ្យ បានប្រេងពីណា រីឯប្រាជ្ញា ក៏ដូច្នោះដែរ។*
(វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន-ណាត** បោះពុម្ពចម្លងឆ្នាំ ១៩៨១ ដោយលោកស្រី យ៉ាម៉ា ដាបូផាណា ទំព័រ១៨៩៦។)

- ជាទីប្រឹក្សាផ្ដល់យោបល់ ដោយទាញបង្ហាញហេតុផលនានាតែកុំសម្រេចចិត្តជំនួសកូនឬក៏កំណត់(អត្តនោម័ត) ទុកលទ្ធភាពឲ្យកូនក្នុងការជ្រើសរើសមុខរបរចិញ្ចឹមជីវិត ឬវិជ្ជាជីវៈនៅមហាវិទ្យាល័យបើនៅជាសិស្ស។

ឧទាហរណ៍ កូនលោកអ្នកចង់បន្តការសិក្សានៅមហាវិទ្យាល័យ។ ក្នុងកម្រិតនេះ លោកអ្នកគួរតែធ្វើការប្រឹក្សាជាមួយកូនឲ្យបានល្អិតល្អន់ដោយស្វាបស្ទង់អំពីៈ

ចំណង់ចំណូលចិត្តរបស់កូន និងរបស់យើង សមត្ថភាពរបស់កូន និងមុខវិជ្ជាជីវៈ សាលា ការស្នាក់នៅ ស្ថានភាពថវិកា ស្ថានភាពដំណោះស្រាយ...។ល។ ការគិតរបស់កូន ត្រូវបានយើងដឹង ឯបញ្ហារបស់យើងក៏ត្រូវកូនបានដឹង ទុកលទ្ធភាពឲ្យកូនធ្វើការវិភាគថ្លឹងថ្លែងដោយសេរី ដើម្បីឲ្យកូនមានការសម្រេចចិត្តដោយខ្លួនឯង។ ទោះបីការសម្រេចចិត្តរបស់កូនខុសបំណងរបស់យើងក្ដីយើងត្រូវធ្វើការពិចារណា បើសិនថាមានលទ្ធភាពសមស្របហើយនោះក៏ត្រូវតែគាំទ្រ មិនគួរសំដែងឥរិយាបថមិនពេញចិត្ត ឬពាក្យសម្ដីផ្ទាញ់ផ្ទាល... នាំឲ្យកូនដឹងអំពីការមិនពេញចិត្តឬខុសបំណងរបស់យើង និងសូមកុំអស្មិមានះបង្ខំកូន ។ បើពុំដូច្នោះទេ គេធ្វើអ្វីដោយគ្មានភាពម្ចាស់ការ គ្មានការទទួលខុសត្រូវធ្វើតាមបង្ខំជោគជ័យឬមិនជោគជ័យមិនខ្វីខ្វល់។ ប៉ុន្តែកាលបើកូនបាន សម្រេចចិត្តហើយវិញនោះ និងត្រូវបានយើងគាំទ្រថែមទៀត គេពេញចិត្ត គេស្មុះស្មា គេឱហាត គេពិតជាមានការទទួលខុសត្រូវ។ ភាពហ្មងសៅរវាងយើងនិងកូនអំពីការខ្វែងបំណងគ្នាត្រូវរលាយបាត់ព្រោះពេលនោះភាពជោគជ័យរបស់កូន និងកើតឡើងយ៉ាងប្រាកដ។ យើងនឿយហត់តែរកថវិកាទ្រទ្រង់ និងតាមឃ្លាំគាំពារតែប៉ុណ្ណោះ។ នេះជាផ្នែកមួយសំខាន់ណាស់ ក្នុងការពង្រឹងសមត្ថភាពកូន លើការគ្រប់គ្រងជោគវាសនារបស់ខ្លួន។

- ការលះបង់ធនធានឲ្យអស់លទ្ធភាព ដើម្បីទ្រទ្រង់ការរៀនសូត្ររបស់កូនឲ្យបានដល់គោលដៅ គឺកូនសិក្សាបានចប់ចុងចប់ដើមតាមបំណងប្រាថ្នាបរិសុទ្ធរបស់កូន ។ បង្ហាញពីការគាំទ្រប្ដូរផ្ដាច់ សម្រាប់កូនក្នុងការសិក្សា តែមិនមែនតាមតម្រូវការភ្លើតភ្លើនរបស់កូន ឬក្នុងក្ដីទំយើ។

ឥឡូវនេះកូនបំពេញកាតព្វកិច្ចតាមគន្លងធម៌ ដែលយើងជាមាតាបិតាចង្អុលហើយ តែនៅឡើយយើងឯណោះវិញទេ ដែលពុំគួរគេចវេះការបំពេញកាតព្វកិច្ចរបស់ខ្លួន ជាអ្នកទ្រទ្រង់ និងជាអ្នកសម្របសម្រួលនោះ ។ ឧទាហរណ៍៖ យើងយល់ព្រមគាំទ្រឲ្យកូនរៀនហើយ តែយើងស្មុគស្មាញថវិកាទ្រទ្រង់ តើមានការគិតគូរដូចម្ដេចទៅ ? គប្បីគិតថា ៖

បើមិនងើបដើរពុំដឹងថា យើងដើរកើតឬពុំកើត(កុំចាញ់មុនប្រយុទ្ធ) អ្នកលេងល្បែងអបាយមុខ ជាអំពើលាមក គេហ៊ានលក់ផ្ទះសម្បែង ដីធ្លី ក្រព្រោះល្បែង ។ រីឯយើងវិញ ក្រព្រោះកូនរៀនជាអំពើល្អ ខ្លាចអ្វីនឹងប្រព្រឹត្ត និងមានអ្វីឲ្យត្រូវរារែក ឬដំអក់តទៅទៀត។ កុំអៀន កុំខ្មាស ព្រោះខ្លួនក្រទ្រព្យ គ្មាននរណាសើចយំនៅពេលកូនយើងបរាជ័យរៀនមិនបានចប់នោះទេ ប៉ុន្តែសម្រាប់ជនប្រពៃគេស្ញើចសរសើរអ្នកណាស់ ។ បើទោះបីថាអាចគាំងកណ្ដាលផ្លូវ ដោយគ្មានថវិកាទ្រទ្រង់ក៏ពុំទាន់ប្រាកដថា បរាជ័យឬជាការទាល់ច្រកដែរ ពីព្រោះថានៅពេលនោះ វានឹងលេចឡើងនូវការគិតគូររកដំណោះស្រាយ សមស្របណាមួយដែលមិនអាចដឹងមុនបានឬមានការគាំទ្រពីមជ្ឈដ្ឋានណាមួយក៏ថាបាន ដោយសារតែកើតឡើងអំពីសេចក្ដីប្ដូរផ្ដាច់របស់យើង និងការពេញចិត្តរបស់កូន។ យ៉ាងណាមិញ ក៏នឹងអាចថាយើងបានជូនដំណើរជោគវាសនារបស់កូន ឲ្យបានដល់នូវភ័ព្វសំណាងល្អរបស់គេដែលកំពុងតែរង់ចាំ។

លោកអ្នកក៏ជ្រាបហើយថា អ្នកទិញផ្លែឈើ គេរកមើលផ្លែឈើណាដែលល្មមសមយកមកប្រើការបានឬនៅ?ចំពោះកូនយើងឈានជើងចូលមហាវិទ្យាល័យប្រៀបបីដូចផ្លែឈើល្មមអ្នកដទៃត្រូវការអាចថាជាមនុស្សចាប់ផ្ដើមឈានចូលចំណាត់ថ្នាក់ដែលសង្គមត្រូវការនិងផ្ដល់តម្លៃ...។

បើដូច្នេះ គេនឹងអាចមានអ្នកសម្លឹងឃើញ និងចាត់ទុកកូនអ្នកឆ្ពោះទៅកាន់សមត្ថភាពជាប្រយោជន៍ហើយ ក៏ដូចដើមឈើបញ្ចេញភោគផលហើយដែរ ។

ម៉្យាងទៀត កូនរៀនបានពាក់កណ្ដាលផ្លូវទៅហើយ តែជួបការខ្វះខាតថវិកាទ្រទ្រង់ ប្រៀបបីដូចទូកដល់កណ្ដាលទន្លេស្រាប់តែអត់ច្រវាអុំ តើយើងគួរទុកឲ្យទូកតែលតោលលិចស្លាប់បាត់? ឬដកយកក្ដារក្រោលដែលខ្លួនកំពុងអង្គុយមកប្រើប្រាស់អុំបន្ត ដើម្បីឲ្យទូកបានដល់ត្រើយ? សូមជ្រើសរើសដោយគូសនៅក្នុងប្រអប់ណាមួយ ។ ទ្រព្យសម្បត្តិ គឺយើងជាអ្នករក ហេតុដូចម្ដេចយើងមិនយកមកប្រើសម្រាប់ទ្រទ្រង់សមត្ថភាពដ៏ប្រពៃរបស់កូនឲ្យដល់គោលដៅ ។ ពេលនេះទ្រព្យសម្បត្តិផ្ទះសម្បែង និងកូនមួយណាថ្លៃថ្លាជាងមួយណា? (ទ្រព្យដែលថ្លៃបំផុតក្នុងលោក គឺទ្រព្យកូន ជាខ្លឹមសារប្រយោគ ក្នុងសេចក្ដីប្រមាទដោយអចេតនានៅផ្នែកខាងដើម) ឬមាស ប្រាក់ កែវកង សម្រាប់ពាក់លម្អខ្លួនសំខាន់ជាង ?

ទន្ទឹមនេះ រដ្ឋយើងបានលើកទឹកចិត្ត និងគាំទ្រ ការផ្ដល់បញ្ញាស្មារតីជូនប្រជាពលរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៦ មាត្រា៦៨ ចែងថា៖

រដ្ឋផ្ដល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។

ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។

..............................................................................................

(សៀវភៅរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បោះពុម្ពខែសីហាឆ្នាំ២០០៩ ដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ)

ការផ្ដល់បញ្ញាស្មារតី គឺជាការឲ្យកូនបានទៅដល់ ភ័ព្វសំណាងល្អរបស់កូនដែលកំពុងរង់ចាំ! រាល់ការស្និទ្ធស្នាលក្នុងគ្រួសារ **គឺកូនបានជិតស្និទ្ធ....មានបេះដូងគោរពស្រឡាញ់អ្នក ! ជាគ្រួសារផ្ដល់ក្ដីសង្ឃឹម ! កូនកើតមកមិនអភ័ព្វមិនតូចចិត្ត មានមោទនភាពចំពោះព្រេងវាសនាដ៏ល្អរបស់ខ្លួន !**

ការវិភាគខាងលើ ជាកម្លាំងបំផុសបញ្ញា ឬជាដើមចមបញ្ហា ដើម្បីឆ្ពោះទៅរកការស្វែងយល់បន្ថែមទៀត អំពីតួនាទីមាតាបិតាចំពោះបុត្រធីតាយ៉ាងដូចម្ដេច ?

*(នៅមានត)*

*ដោយលោក **ផេង កែន** ប្រធានការិ.រដ្ឋបាលមន្ទីរអ.យ.ក.ខេត្តកំពង់ឆ្នាំង*

ពាក្យដែលត្រឹមត្រូវ គួរដល់ការងារ សូម្បីជាសំដីកូនក្មេង អ្នកមានប្រាជ្ញា ក៏គួរកាន់យក, បើមិនមានពន្លឺព្រះអាទិត្យទេ ពន្លឺប្រទីប នឹងមិនមានគុណប្រយោជន៍ ឬអ្វី?

ស្រីហិតោបទេស

# ចលករសិក្សា (តចប់)

### ៣.២- វិធីសាស្ត្រក្នុងការពង្រឹងចលករសិក្សាវិជ្ជមាន

ដើម្បីពង្រឹងចលករសិក្សាវិជ្ជមានគ្រូបង្រៀនត្រូវ ៖

- បង្កើនការប្រុងប្រយ័ត្នដល់សិស្ស
- អនុវត្តការត្រួតពិនិត្យ ឬ ការកែប្រែអាកប្បកិរិយាអវិជ្ជមានរបស់សិស្ស និងកសាងអាកប្បកិរិយាវិជ្ជមានរបស់សិស្ស
- ពង្រឹងភាពចុះខ្សោយបន្តិចម្តងៗឲ្យមានភាពរឹងប៉ឹងឡើងវិញ និងសង្កត់ធ្ងន់ទៅលើស្វ័យពង្រឹង និង ស្វ័យគ្រប់គ្រងបទពិសោធន៍ក្នុងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការសិក្សារបស់សិស្សដែលនឹងអាចអភិវឌ្ឍបាន
- ពង្រឹងការអភិវឌ្ឍគំនិតជឿនលឿន និងគំនិតផ្តើមប្រកបដោយភាពម្ចាស់ការ។

*ការសម្ដែងចេញឲ្យឃើញចលករសិក្សារបស់សិស្ស*

- មានបម្រុងប្រយ័ត្នស្តាប់ការណែនាំរបស់លោកគ្រូ-អ្នកគ្រូ
- មានអាកប្បកិរិយាយកចិត្តទុកដាក់ក្នុងការសិក្សា
- មានការកែប្រែអាកប្បកិរិយាកាន់តែប្រសើរឡើង
- ជក់ចិត្តក្នុងការសិក្សាស្រាវជ្រាវ
- ធ្វើការងារប្រកបដោយភាពម្ចាស់ការ
- មានស្មារតីតស៊ូ ពុះពាររាល់ឧបសគ្គ ការលំបាកទាំងឡាយ ដើម្បីសម្រេចការងារ ឬ កិច្ចការដែលលោកគ្រូ អ្នកគ្រូ ប្រគល់ឲ្យធ្វើ។

### ៤. សមាសភាគរបៀបអនុវត្តគោលការណ៍នៃការអនុវត្ត

### ៤.១-សមាសភាគនៃចលករសិក្សា

- *ចលករសិក្សាប្រព្រឹត្តដោយវាចា :* គឺជាការផ្ដល់យោបល់លើកសរសើរដើម្បីធ្វើការលើកទឹកចិត្ត។ នេះគឺជាការផ្ដល់យោបល់ផ្ទាល់ខ្លួនរបស់គ្រូបង្រៀនដែលមានលក្ខណៈជាការវាយតម្លៃ ការគាំទ្រ និងជាព័ត៌មានត្រឡប់ស្តីពីលទ្ធផលការងាររបស់សិស្ស
- *ចលករសិក្សាតាមរយៈឥរិយាបថ :* ឥរិយាបថ និងវាចាត្រូវផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ឥរិយាបថមានការញញឹម ការងក់ក្បាល ការចង្អុលបង្ហាញ ក្នុងន័យដើម្បីជំរុញទឹកចិត្តសិស្សឲ្យចាប់ផ្តើម ឬបន្តធ្វើកិច្ចការអ្វីមួយ ឬខិតខំប្រឹងប្រែងធ្វើការអ្វីមួយឲ្យបានសម្រេចពេញលេញ
- *ចលករសិក្សាតាមរយៈការពេញចិត្ត :* ការពេញចិត្តសកម្មភាព ឬទង្វើណាមួយដោយផ្អែកលើលទ្ធផលការងារដែលសិស្សធ្លាប់បានទទួល
- *ចលករសិក្សាប្រការដែលនៅជិតបំផុត :* ការយកចិត្តទុកដាក់ ការបង្ហាញពីការចាប់អារម្មណ៍អ្វីៗដែលនៅជិតជាប់នឹងអ្វីៗដែលពាក់ព័ន្ធនឹងសិស្សដែលជាប្រការអាចជំរុញលទ្

ផលការងារបាន

- *ចលករសិក្សាតាមរយៈការទាក់ទង* : ការលើកទឹកចិត្តនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងចលករសិក្សាដែលនៅជិតបំផុត។ ការទាក់ទងនេះអាចជាការទះតិចៗលើស្មា ឬ លើក្បាលសិស្ស
- *ចលករសិក្សាតាមរយៈការបង្ហាញភស្តុតាង និមិត្តរូប* ជាសញ្ញាសម្គាល់ ជាវត្ថុតាង ឬការផ្តល់យោបល់វិជ្ជមានដូចជាការលើកសរសើរ រង្វាន់ការផ្តល់ភ័ព្វសំណាងក្នុងការចំណាយពេលវេលាលើសកម្មភាពដែលពេញចិត្តជាដើម ។

### ៤.២- របៀបអនុវត្តចលករសិក្សា

<u>ចលករសិក្សាអាចអនុវត្តៈ</u>

- *ចំពោះក្រុម អង្គភាព ឬ ថ្នាក់ទាំងមូល :* ជាឱកាសយូរៗម្តងដែលគ្រូបង្រៀនអាចធ្វើការលើកទឹកចិត្តចំពោះអង្គភាព ក្រុមថ្នាក់ទាំងមូល ឬ បុគ្គលមួយចំនួន ។
- *ក្នុងលក្ខណៈអូសបន្លាយពេល :* គួរធ្វើចលករឲ្យបានឆាប់រហ័សបើអាចធ្វើទៅបាន ។ ប៉ុន្តែគ្រូបង្រៀន ត្រូវប្រើប្រាស់ចលករក្នុងលក្ខណៈអូសបន្លាយតែនៅពេលណាដែលការអូសបន្លាយអាចបំពេញដោយការពន្យល់ណែនាំ ការប្រាប់បង្ហាញផ្លូវពីអ្វីដែលនឹងកើតមានឡើង ។
- *តាមផ្នែក* : ចលករលើផ្នែកណាដែលត្រឹមត្រូវ ឬអ្វីដែលធ្វើបានហើយតែមិនទាន់ពេញលេញមានន័យថាចលករលើផ្នែកដែលផ្តល់នូវគុណភាពវិជ្ជមាន ។ ចលករនេះសង្កត់ធ្ងន់លើវិធីដោះស្រាយវិជ្ជមាន។ គោលការណ៍នៃចលករ គឺត្រូវចៀសវាងចលករអវិជ្ជមាន និងការរិះគន់ ។
- *ចំពោះបុគ្គល* : ការលើកឈ្មោះបុគ្គលម្នាក់សក្តិសិទ្ធិបំផុតជាងការឆ្លើយតប (ការលើកទឹកចិត្ត)ដោយលាក់មុខចំពោះបុគ្គលនោះ។ នេះចង្អុលបង្ហាញឲ្យឃើញថាគ្រូបង្រៀនស្គាល់បុគ្គលនោះច្បាស់ និងជាអ្នកវាយតម្លៃការងាររបស់គេ ។

### ៤.៣- គោលការណ៍នៃការអនុវត្តចលករសិក្សា

ចលករសិក្សាប្រកបដោយប្រសិទ្ធភាពខ្ពស់ គឺចលករសិក្សាដែលអនុវត្តតាមគោលការណ៍

- ចលករសិក្សាប្រកបដោយភាពកក់ក្តៅ និងភាពរីករាយ ។
- ការចៀសវាងចលករសិក្សាអវិជ្ជមាន ។
- ការប្រើប្រាស់វិធីសាស្ត្រជំរុញទឹកចិត្តខុសៗគ្នា ។
- ចលករសិក្សាប្រកបដោយអត្ថន័យជ្រាលជ្រៅចំពោះសិស្ស ។

## V- សន្និដ្ឋាន

សកម្មភាពរបស់មនុស្សកើតឡើងពីចលករ (ស្មារតី និងសម្ភារ) ។ ចលករប្រកបដោយប្រសិទ្ធភាពចំណុះកត្តាជាច្រើនដូចជា សមត្ថភាពជ្រើសរើសមុខសញ្ញា រូបភាពលើកទឹកចិត្ត វិធីសាស្ត្រ ចលករដោយផ្អែកលើគោលការណ៍ទាំងបួនខាងលើ និងឈរលើជំហរយុត្តិធម៌ និងស្មារតីអភិវឌ្ឍធនធានមនុស្ស។ *(លោក **ជ័យ សយ្យនា** ដកស្រង់ពីឯកសារនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ)*

# តួនាទីបុត្រប្រុសស្រីក្នុងការតបស្នងសងគុណចំពោះ មាតាបិតា ឬ អាណាព្យាបាល

នៅលើពិភពលោកយើងនេះ គ្មាននរណាម្នាក់ដែលកើតមកគ្មានមាតាបិតានោះឡើយ។ ដោយឡែកជនជាតិខ្មែរយើងតាំងពីយូរលង់ណាស់មកហើយតែងចាត់ទុកមាតាបិតាជាព្រះដើម ដែលត្រូវគោរពតបស្នងសងគុណជូនលោកវិញគ្រប់ពេលវេលារហូតដល់លោកអ្នកដ៏មានគុណ ទាំងពីរអស់ព្រះជន្មទៅ ។

នៅក្នុងសង្គមខ្មែរតាំងពីបុរាណកាលក៏ដូចបច្ចុប្បន្នកាលដែរ ស្របគ្នានឹងទ្រឹស្តីព្រះពុទ្ធសាសនា ផង និងស្របច្បាប់រដ្ឋធម្មនុញ្ញផងដែលបានចែងថា នៅពេលមាតាបិតាចាស់ជរា បុត្រាបុត្រីទាំង អស់ត្រូវចិញ្ចឹមបីបាច់ថែរក្សាលោកវិញ ។ បើយើងក្រឡេកមកក្រោយ ឬអតីតកាលវិញកាលយើង ធំដឹងក្តីកាលណា យើងឃើញការតស៊ូដ៏លំបាករបស់លោកទាំងពីរក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន យ៉ាងណា នោះយើងនឹងនឹកដល់ពេលនេះនៅពេលគាត់ចាស់ជរាឈឺថ្កាត់ត្រូវចិញ្ចឹមសងគុណ លោកទាំងពីរវិញយ៉ាងនោះដែរ។

អ្នកខ្លះ នៅពេលដែលខ្លួននៅក្មេង កម្លាំងខ្សោយការរស់នៅពឹងផ្អែកលើឪពុកម្តាយទាំងស្រុង ទោះបីគាត់ហត់នឿយលំបាកយ៉ាងណាក៏មិនត្អូញត្អែរឲ្យតែកូនរស់នៅបានសុខសប្បាយ និងបាន ទៅសិក្សារៀនសូត្រ។ ទោះបីពេញវ័យល្មមមានគូស្រករទៅហើយ ក៏ឪពុកម្តាយនៅតែស្រឡាញ់ កូនតែងឃ្លាំមើល ខ្លាចកូនធ្វើអ្វីខុសដូចជាកូននៅក្មេងដដែល។ នៅពេលកូនប្រុសស្រីចម្រើនវ័យ ល្មមទៅសិក្សាលោកទាំងពីរបានបញ្ជូនកូន ឧបត្ថម្ភសម្ភារថវិកាឲ្យកូនបានរៀនខ្ពង់ខ្ពស់គួរឲ្យកោត សរសើរ វីរភាពលះបង់ខ្ពស់នេះ គ្មាននរណាធ្វើបានដូចមាតាបិតាខ្លួនឡើយ។ ដល់ពេលកូនល្មម ដល់មានគូស្រករលោកទាំងពីរបានជម្នះឧបសគ្គនានា ដើម្បីឲ្យសម្រេចបំណងកូន។ មិនតែ ប៉ុណ្ណោះលោកនៅមាន ទ្រព្យសម្បត្តិកេរមរតកដ៏តិចតួចខ្លះចែករំលែកឲ្យកូនស្មើៗគ្នា តាមទ្រព្យ ធនរបស់ខ្លួនដែលមាន។ ដល់វ័យជរាបន្តិចម្តងៗរបស់លោកទាំងពីរ ផ្សំនឹងរោគាពាធម្តងម្កាលផង លោកទាំងពីរបានចូល វ័យជរាមែនទែន កម្លាំងប្រាជ្ញាស្មារតីចុះខ្សោយ ចំណែកឯមុខរបរចិញ្ចឹម ជីវិតពុំប្រាកដដូចពីនៅកម្លាំងក្មេងឡើយ។

លុះចូលវ័យដូចនេះហើយ បើបុត្រធីតាទាំងឡាយព្រងើយកន្តើយពុំនឹកនាដល់ តើគាត់រស់ នៅកក់ក្តៅដូចកាលគាត់ចិញ្ចឹមយើងឬទេ ?។

លោកទាំងពីរនៅតែសប្បាយនឹងភារកិច្ចរបស់ខ្លួនដែលបានបំពេញដល់កូន ជាមាតាបិតាដ៏ ល្អនឹងស្ងប់អារម្មណ៍ឃើញកូនមានមុខមាត់ មានមុខរបរត្រឹមត្រូវចិញ្ចឹមខ្លួន។ គាត់ពុំដែលទាមទារ អ្វីពីយើងឡើយ។

គួរតែបុត្រធីតាប្រុសស្រី កុំមើលរំលងព្រះមានជីវិតជិតបង្កើយខ្លួនឲ្យសោះ។ ជារៀយៗយើងត្រូវ យកនូវគ្រឿងឧបភោគបរិភោគគ្រឿងបរិក្ខារប្រើប្រាស់ជូនលោកទាំងពីរផ្ទាល់ដៃតាមលទ្ធភាព

យើង នោះលោកនឹងសប្បាយចិត្តពុំខាន ។ ពិសេសការហូបចុកប្រចាំថ្ងៃត្រូវតែយកចិត្តទុកដាក់ ព្រោះចាស់ជរាមានការហេវហត់ខ្លាំងណាស់ ត្រូវជូនលោកពិសាតាមចំណង់ចិត្ត។

ដូចកំណាព្យមួយឃ្លាលើកឡើងថា ៖ **ត្រូវធ្វើបុណ្យខ្មើត ម៉ែឪស៊ីកើត កំពុងស្រេកឃ្លាន កូនចៅទាំងឡាយ ត្រូវធ្វើបុណ្យទាន បំបាត់ក្ដីឃ្លាន បានជាងរនោច។ លុះផុតជីវិត បុណ្យខែងងឹត ថ្ងៃដូចដប់រោច កូនចៅទាំងឡាយ យកបាយឲ្យខ្មោច ម៉ែឥតប្រយោជន៍ ខ្មោចណាចេះស៊ី។** កំណាព្យនេះមានអត្ថន័យណាស់គួរកូនប្រុសស្រីពិចារណា។ ការលំបាកក្នុងការចិញ្ចឹមបីបាច់ថែរក្សាគាត់ក៏ដូចជាកាលដែលគាត់លំបាកក្នុងពេលចិញ្ចឹមយើងដែរ។

មនុស្សតិចតួចណាស់ ពុំសូវគិតគូរដល់លោកទាំងពីរពេលនៅមានជីវិតរស់នៅ ហើយតែងសោកស្ដាយក្រោយ ពេលគាត់បាត់បង់ជីវិតទៅ លែងបានឃើញមុខមាត់ លែងបានឮសំដី លែងបានហៅថា ពុក ម៉ែ ទើបស្រក់ទឹកភ្នែកម្ដងទៀត។ កិច្ចតបស្នងសងគុណនេះមានក្នុងគម្ពីរព្រះពុទ្ធសាសនាដែលព្រះពុទ្ធលើកពីកូនកតញ្ញូមកសំដែងផងដែរ។ លុះពេលលោកទាំងពីរអស់ជីវិតកូនប្រុសស្រីចាត់ចែងធ្វើបុណ្យសព ឧទ្ទិសកុសលជាចុងក្រោយដោយលោកលែងដឹងអ្វីទាំងអស់។

តួនាទីរបស់កូនប្រុសស្រីក្នុងការចិញ្ចឹមបីបាច់ថែរក្សាមាតាបិតា ជាកាតព្វកិច្ចរបស់បុត្រប្រុសស្រី គួរប្រណិប័តន៍ដើម្បីឱ្យសមជាកូនកតញ្ញូនិងជាគំរូប្រពៃតៗគ្នាសម្រាប់សង្គមខ្មែរដែលមានជំនឿលើបុណ្យបាបផង និងស្របតាមច្បាប់សង្គមផង។

*លោក* ***ធីវ សុផល***

*នាយកសាលាបឋមសិក្សា ដំរីយកទឹក ស្រុកសំរោង ខេត្តតាកែវ*

## ភាសិតោវាទ

(ពាក្យប្រាំបី)

| | |
|---|---|
| អ្នកដែលខ្មាសគ្រូនឹងគ្មានវិជ្ជា | អ្នកដែលខ្មាសភរិយាគ្មានកូនប្រើ |
| អ្នកដែលខ្មាសស្ដេចគ្មានយសប្រសើរ | អ្នកដែលខ្មាសធ្វើទាននឹងគ្មានបុណ្យ។ |
| អ្នកខ្មាសការងារសោបសូន្យធនគុណ | អ្នកខ្មាសហៅមុនគ្មានភ្ញៀវឡើងផ្ទះ |
| អ្នកខ្មាសអាហារនឹងស្វិតក្រពះ | អ្នកខ្មាសមានះនឹងខូចអាជ្ញា។ |
| អ្នកខ្មាសយសស័ក្តិមិនថ្កើងអាត្មា | អ្នកខ្មាសសមណានឹងខានធ្វើបុណ្យ |
| អ្នកខ្មាសភាសាលក់ដូរខាតទុន | អ្នកដែលខ្មាសគុណនឹងខានធ្វើកាច។ |
| អ្នកដែលខ្មាសរាស្ត្រនឹងគ្មានអំណាច | អ្នកខ្មាសសិស្សខ្លាចមិនហ៊ានរកហៅ |
| អ្នកដែលខ្មាសកូននឹងខានប្រដៅ | អ្នកដែលខ្មាសខ្លៅនឹងទៅជាប្រាជ្ញ។ |

ព្រះប្រសើរបញ្ញាង់ ម៉ុកទួន (១៩៥២)

# ដំណាក់រងទាំងពីរនៃដំណាក់បុរេប្រតិបត្តិការស្តីអំពីទ្រឹស្តី អត្តវឌ្ឍពុទ្ធិ របស់លោកព្យ៉ាសេ

ដំណាក់បុរេប្រតិបត្តិការរបស់លោកព្យ៉ាសេ ស្ថិតនៅអាយុចន្លោះពី២ទៅ៧ឆ្នាំ។ គឺជាដំណាក់អាយុដែលបញ្ញត្តិថេរបានកកើតឡើង ការគិតរកហេតុផលផុសចេញ មជ្ឈត្តៈនិយម (ការគិតថាខ្លួនឯងអស្ចារ្យ egocentrism) ចាប់ផ្តើមកកើតយ៉ាងខ្លាំង ហើយបន្ទាប់មកបានធ្លាក់ចុះខ្សោយវិញ ព្រមទាំងមានជំនឿផ្តេសផ្តាសទៀតផង។ពាក្យថាបុរេប្រតិបត្តិការបញ្ជាក់ថាកុមារដែលស្ថិតក្នុងដំណាក់នេះពុំទាន់ចេះគិតតាមរបៀបប្រតិបត្តិការនៅឡើយទេ។

តើបុរេប្រតិបត្តិការមានន័យដូចម្តេច?

តើប្រតិបត្តិការ (operations) ជាអ្វី?

ប្រតិបត្តិការជាលំនាំសកម្មភាពទាំងឡាយដែលបានធ្វើឲ្យទៅជាផ្ទៃក្នុងរួចហើយ ដែលជួយកុមារឲ្យចេះប្រើគំនិត(ការគិត) អំពីអ្វីដែលបានធ្វើដោយកាយក្នុងរយៈពេលកន្លងមក។

ប្រតិបត្តិការមានការរៀបចំចាត់តាំងកំរិតខ្ពស់ ហើយអនុលោមតាមវិធាន និងគោលការណ៍តក្កវិទ្យាមួយចំនួនទៀតផង។ គេបានកត់សំគាល់ឃើញថា រវាងការធ្វើផែនការ(ស្តីម)ឥន្ទ្រីយ៍ចលករ និងប្រតិបត្តិការរូបីមានភាពខុសគ្នាយ៉ាងច្រើន ដោយហេតុថា ប្រតិបត្តិការរូបីជាប់ទាក់ទងទៅនឹងសកម្មភាពខាងក្នុង។ ចំណែកឯការធ្វើផែនការឥន្ទ្រីយ៍ចលករវិញទាក់ទងទៅនឹងសកម្មភាពខាងក្រៅ ដូចជាការលូកយកវត្ថុ ឬចាប់កាន់វត្ថុជាដើម។

ឧទាហរណ៍មួយ ស្តីពីកង្វះគំនិតប្រតិបត្តិការចំពោះកុមារតូចៗដែលទាក់ទង នឹងការគិតព្រមពេលគ្នា អំពីផ្នែក(part) របស់សរុប (ឬរួម=whole) និងសរុប(រួម)។ គេបានសាកល្បងយកស្កររគ្រាប់ពណ៌បៃតង ៦គ្រាប់ និងស្កររគ្រាប់ពណ៌ក្រហម ៣គ្រាប់ដាក់ចូលគ្នា រួចហើយគេយកទៅដាក់នៅមុខកុមារអាយុ ៥ឆ្នាំ ជាច្រើននាក់។ បន្ទាប់មក គេសួរថា : តើស្កររគ្រាប់ពណ៌បៃតងច្រើនជាង? ឬស្កររគ្រាប់សរុបច្រើនជាង? ពួកគេឆ្លើយថា : ស្កររគ្រាប់ពណ៌បៃតងច្រើនជាង? លោក ព្យ៉ាសេ ជឿថាចម្លើយនេះបញ្ជាក់ថាកុមារតូចៗទាំងនោះមិនអាចបញ្ចូលព្រមពេលជាមួយគ្នានូវផ្នែក និងសរុប (រួម) ទៅក្នុងប្រតិបត្តិការគំនិតរកហេតុផលបានឡើយ។

គំនិតនៅក្នុងដំណាក់បុរេប្រតិបត្តិការមានគុណវិបត្តិខ្លះៗ និងពុំបានរៀបចំចាត់តាំងល្អទេ។ គំនិតបុរេប្រតិបត្តិការជាប់ទាក់ទងនឹងបំលាស់ប្តូរពីការប្រើនិមិត្តសញ្ញាងាយៗដំបូង ទៅជាការប្រើនិមិត្តសញ្ញាជឿនលឿន និងស្មុគស្មាញជាង។ គំនិតបុរេប្រតិបត្តិការអាចចែកជាដំណាក់រងពីរគឺ : **ដំណាក់រងមុខងារនិមិត្តសញ្ញា និងដំណាក់រងគំនិតអព្ភន្តរញាណ។**

**<u>១. ដំណាក់រងមុខងារនិមិត្តសញ្ញា</u>**

គឺជាដំណាក់វងទី១ នៃគំនិតបុរេប្រតិបត្តិការដែលកើតមាននៅអាយុចន្លោះ២ និង៤ឆ្នាំ។ ក្នុងដំណាក់វងនេះ កុមារតូចៗមានបំណិនដើម្បីបង្កើតនូវរូបតំណាងរបស់កម្មវត្ថុដែលពុំមាននៅក្នុងគំនិត។ បំណិនបង្កើតគំនិតនិមិត្តសញ្ញារបៀបនេះហៅថា **មុខងារនិមិត្តសញ្ញា**។ កុមារប្រើ គំនូរគូរវាសដើម្បីតាងមនុស្ស ផ្ទះ រថយន្ត ពពក និងអ្វីៗទៀតជាបន្តបន្ទាប់។

ឧទាហរណ៍ផ្សេងទៀតអំពីនិមិត្តសញ្ញានិយម(Symbolism) នៅកុមារភាពដំបូងនេះ គឺ ភាសា និងភាពទូទៅនៃការលេងប្រឌិត។ ជារួម បំណិនដើម្បីយល់និមិត្តសញ្ញា និងដើម្បីតាងពិភពលោកនៅក្នុងគំនិតរបស់កុមារបានគ្របដណ្តប់នៅក្នុងដំណាក់វងនៃគំនិតបុរេប្រតិបត្តិការនេះ។ ទោះបីកុមារបានបង្ហាញឲ្យឃើញនូវការរីកលូតលាស់នៅក្នុងដំណាក់វងនេះក៏ដោយក៏គំនិតរបស់គេនៅមានអសមត្ថភាពនៅឡើយដែលក្នុងនោះគឺ មជ្ឈត្តៈនិយម (egocentrism) និងវិញ្ញាណនិយម (animism)។

**មជ្ឈត្តៈនិយម**ជាចរិតលក្ខណៈសំខាន់មួយនៃគំនិតបុរេប្រតិបត្តិការ។ គឺជាអសមត្ថភាពនៃការកំណត់រវាងទស្សនៈរបស់ខ្លួនឯងនិងទស្សនៈអ្នកផ្សេងទៀត។ មានឧទាហរណ៍មួយដែលបញ្ជាក់អំពីគំនិតរបស់កុមារីម្នាក់តាមការនិយាយទូរស័ព្ទដូចតទៅ:

គឺជាការសន្ទនាតាមទូរស័ព្ទរវាងឪពុកដែលនៅកន្លែងធ្វើការ និងកូនស្រីតូចឈ្មោះ ម៉ារី អាយុ៤ឆ្នាំ ដែលនៅចាំផ្ទះ។ គំនិតមជ្ឈត្តៈនិយមរបស់កុមារី ម៉ារី បានសំដែងចេញយ៉ាងនេះ :

ឪពុក: កូន ម៉ារី ! តើម៉ាក់នៅផ្ទះដែរឬទេ ?

ម៉ារី: (ស្ងាត់ស្ងៀម ,គ្រវីក្បាល)

ឪពុក : កូនម៉ារី! តើប៉ាអាចនិយាយជាមួយម៉ាក់បានឬទេ ?

ម៉ារី : (គ្រវីក្បាលជាថ្មីទៀត ហើយស្ងាត់ស្ងៀម)។

ការឆ្លើយតបរបស់កុមារីម៉ារី តាមកាយវិការរបៀបនេះមានចរិត មជ្ឈត្តៈនិយម ដែលក្នុងនោះនាងមិនបានគិតដល់បំណង(ឬទស្សនវិស័យ)របស់ឪពុកនាងឡើយ នៅមុនពេលមានការឆ្លើយតបទៅរកឪពុករបស់នាង។

វិញ្ញាណនិយម ជាជំនឿដែលជឿថាអ្វីទាំងអស់មានវិញ្ញាណនិងអាចធ្វើសកម្មភាពបាន។ នេះក៏ជាអសមត្ថភាព មួយផ្សេងទៀតនៃគំនិតបុរេប្រតិបត្តិការ។ កុមារតូចម្នាក់អាចសំដែងចេញនូវសញ្ញានៃវិញ្ញាណនិយមរបស់គេដោយនិយាយថា: "ដើមឈើនោះបានជ្រុះស្លឹកអស់ ហើយវារលំ" កុមារណាដែលបានប្រើគំនិតវិញ្ញាណនិយមនេះនឹងទទួលបរាជយ័ក្នុងការដឹងអំពីលក្ខណៈខុសប្លែកគ្នារវាងទស្សនៈមនុស្សជាតិ និងទស្សនៈមិនមែនមនុស្សជាតិ។

**២. ដំណាក់វងគំនិតអព្ភន្តរញាណ.(ការយល់ច្បាស់ដោយមិនបាច់ពិចារណា)**

គឺជាដំណាក់វងទី២នៃគំនិតបុរេប្រតិបត្តិការដែលកើតមាននៅចន្លោះអាយុពី៤ទៅ៧ឆ្នាំ។ ក្នុងដំណាក់នេះ កុមារចាប់ផ្តើមប្រើគំនិតរិះរកហេតុផលងាយៗដំបូង និងចង់ដឹងចម្លើយទាំងឡាយនៃគ្រប់ប្រភេទសំណួរ។ លោកព្យ៉ាសេបានហៅខណៈពេលនេះថា "អព្ភន្តរញាណ" ដោយហេតុថា គឺម៉្យាងមកពីកុមារតូចៗហាក់បីដូចជាប្រាកដចំពោះចំណេះដឹង និងចំពោះការយល់ដឹងរបស់គេណាស់។ ប៉ុន្តែផ្ទុយទៅវិញ ពួកគេមិនបានយល់អំពីហេតុផលដែលពួកគេត្រូវដឹង និងអំពីដែលគេ

ត្រូវដឹងនោះទេ។ ពួកគេនិយាយថា ពួកគេដឹងអ្វីៗមួយចំនួនមែន ប៉ុន្តែអ្វីដែលបានដឹងនោះពួកគេមិនបានប្រើគំនិតរកហេតុផលឡើយ។

គំនិតបុរេប្រតិបត្តិការមានចរិតលក្ខណៈពីរជាអាទិ៍គឺ : មជ្ឈការ(Centralisation) និងការអភិរក្ស (conservation)។

<u>ការអភិរក្ស</u> គឺជាបញ្ញត្តិដែលយល់ថាលក្ខណៈរូបខ្លះៗនៃអង្គវត្ថុស្ថិតនៅដដែល ថ្វីបើរូបរាងរបស់អង្គវត្ថុនោះត្រូវបានប្រែប្រួលផ្លាស់ប្ដូរក៏ដោយ។

កុមារបុរេប្រតិបត្តិការនៅមានចរិតលក្ខណៈផ្សេងៗទៀត។ពួកគេចូលចិត្តសាកសួរសំណួរយ៉ាងច្រើន។ នៅអាយុ ៣ឆ្នាំ កុមារចាប់ផ្ដើមចេះ សាកសួរសំណួរហើយ។ លុះដល់ពួកគេមានអាយុ៥ឆ្នាំ ពួកគេចូលចិត្តសាកសួរមនុស្សធំដែលនៅជុំវិញពួកគេនូវសំណួរ ដែលមានពាក្យថា : ហេតុអ្វី? ហេតុដូចម្ដេច? ម៉េចបានជាអ៊ីចឹង?

សំណួររបស់កុមារនេះ បញ្ជាក់ថាពួកគេមានការអភិវឌ្ឍគំនិតដែលឆ្លុះបញ្ចាំង អំពីការចង់ចេះចង់ដឹងផ្នែកបញ្ញា។ សំណួរទាំងនេះជាសញ្ញា ឲ្យដឹងថាមានការកកើតនូវការយកចិត្តទុកដាក់របស់កុមារក្នុងការគិត ពិចារណារកហេតុផលថាតើហេតុអ្វីបានជាអ្វីៗវាយ៉ាងដូច្នេះ?

ខាងក្រោមនេះជាគំរូសំណួរខ្លះៗដែលកុមារមានអាយុចន្លោះពី ៤ទៅ ៦ឆ្នាំបានសាកសួរ :

"តើអ្វីទៅដែលធ្វើឲ្យអ្នកលូតលាស់ធំធាត់?"

"ហេតុអ្វីបានជាស្ត្រីត្រូវរៀបការ និងមានកូន?"

"ហេតុអ្វីបានជាស្លឹកឈើជ្រុះធ្លាក់មកដី?"

ដំណាក់រងទាំងពីរនៃគំនិតបុរេប្រតិបត្តិការរបស់ លោក ព្យ៉ាសេ នេះ ត្រូវបានចាត់ទុកជាគ្រឹះមួយយ៉ាងសំខាន់ក្នុងការយល់ដឹងអំពីការគិតរបស់កុមារតូចៗ ថាតើពួកគេគិតយ៉ាងដូចម្ដេច និងតាមរបៀបណា?

*លោក ស៊ឹម ហុង* (និវត្តន៍ជន)

---

| | |
|---|---|
| **មី:ៗ** | មុខគោរាបរម្យទម |
| **កេះ** | កៀវក្រមុំក្នុងទីស្ងាត់ |
| **ផ្អាំងបាយ** | កកាយលួចទៅបាត់ |
| **ផ្ទុះ** | ផ្ដាយប្រយ័ត្នមនុស្សបែបហ្នឹង។ |

ញូង សឿង

ទស្សនាវដ្ដី កម្ពុជសុរិយា




# អ្នកអប់រំជាច្រើនត្រូវជួយជំរុញឲ្យមានការទទួលយកនូវមនសិការ ជាមូលដ្ឋាននៃការអប់រំដើម្បីជួយលើកស្ទួយប្រឌិតញ្ញាណជាត ការពារបទឧក្រិដ្ឋ និងអំពើហិង្សានានា (ត)

## ☛ តើបច្ចេកទេស TM គឺជាអ្វី?






កម្មវិធី TM គឺជាកម្មវិធីដែលមានការអនុវត្ត និងធ្វើការស្រាវជ្រាវយ៉ាងទូលំទូលាយបំផុត សម្រាប់បំបាត់នូវភាពធុញថប់តប់ប្រមល់ និងការអភិវឌ្ឍសក្តានុពល ច្នៃប្រឌិត។ កម្មវិធី TM គឺជាបច្ចេកទេសមួយដ៏សាមញ្ញ គ្មានការប្រឹងប្រែងមានលក្ខណៈជាធម្មជាតិដែលផ្តល់ការសម្រាកយ៉ាងស៊ីប់ជ្រៅ និងធ្វើការដកបទពិសោធន៍ពីសភាវៈដ៏ស្ងប់ស្ងាត់ដែលជាស្រទាប់ក្រោមបំផុតនៃផ្លូវចិត្ត ហើយវាមានសក្តានុពលពេញលេញដោយខ្លួនវា។ អនុវត្តបច្ចេកទេសនេះ ជាទៀងទាត់អាចភ្ជាប់បទពិសោធន៍នៃសក្តានុពលទាំងអស់ក្នុងខ្លួនរបស់មនុស្សម្នាក់ទៅក្នុងសកម្មភាពនៃជីវិតប្រចាំថ្ងៃរបស់គេ ហើយថែមទាំងធ្វើការអភិវឌ្ឍសក្តានុពល ដែលមិនទាន់ត្រូវបានប្រើប្រាស់របស់ប្រព័ន្ធខួរក្បាលទៀតផង។ មិនតែប៉ុណ្ណោះវាជួយពង្រីកប្រព័ន្ធខួរក្បាលឲ្យបានទូលំទូលាយជាងមុនដូចមានឯកសារវិទ្យាសាស្ត្រដែលបានបង្ហាញពីអត្ថប្រយោជន៍ជាច្រើនរបស់វា។ មានមនុស្សជាង ៦លាននាក់ គ្រប់វប្បធម៌ គ្រប់សាសនា គ្រប់អាយុ គ្រប់ប្រវត្តិវណ្ណៈ ពណ៌សម្បុរទាំងអស់បានរៀនបច្ចេកទេសនេះកាលពីជាង ៥០ឆ្នាំកន្លងមកហើយ។

## អត្ថប្រយោជន៍ " មនសិការជាមូលដ្ឋាននៃការអប់រំ " ជាច្រើនត្រូវបានផ្ទៀងផ្ទាត់ដោយការស្រាវជ្រាវដ៏ទូលំទូលាយ

Benefits of Consciousness-Based Education Verified by Extensive Research

គុណប្រយោជន៍នៃឥទ្ធិពលរបស់ " **មនសិការជាមូលដ្ឋាននៃការអប់រំ** " ដ៏ច្រើនត្រូវបានបញ្ជាក់ដោយមានការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រជាង៦០០ធ្វើឡើងនៅតាមបណ្តាសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវជាង ២៥០ នៅក្នុង ៣៣ប្រទេស។ ការស្រាវជ្រាវនេះបានបង្ហាញថា បច្ចេកទេស TM ជួយឲ្យមានភាពស៊ីសង្វាក់គ្នានៅក្នុងប្រព័ន្ធនៃរលកខួរក្បាលទាំងមូល បង្កើនគំនិតច្នៃប្រឌិត និងបញ្ញាញាណ ធ្វើឲ្យប្រសើរឡើងនូវលទ្ធផលក្នុងការសិក្សាកាត់បន្ថយភាពធុញថប់តប់ប្រមល់ និងបញ្ហាស្មុគស្មាញផ្សេងៗ ធ្វើឲ្យប្រសើរឡើងដល់សុខភាពកាត់បន្ថយការចំណាយលើសុខភាព និងធ្វើឲ្យប្រសើរដល់ការទំនាក់ទំនងផ្សេងៗ។

### អត្ថប្រយោជន៍សំរាប់សិស្ស-និស្សិត

(Benefits Relevant to Students)

- ធ្វើឲ្យប្រសើរឡើងដល់ស្នាដៃ ឬលទ្ធផលនៃការសិក្សា
- បង្កើនគំនិតច្នៃប្រឌិត
- បង្កើនប្រាជ្ញាញាណឈ្លាសវៃ (IQ)
- ជាមនុស្សមានហេតុផល និងសីលធម៌ជាងមុន
- កាត់បន្ថយការប្រើប្រាស់គ្រឿងញៀន ស្រា បារី
- កាត់បន្ថយភាពធុញថប់តប់ប្រមល់ និងជំងឺធុញថប់អារម្មណ៍
- បង្កើនការគោរពខ្លួនឯង
- ធ្វើឲ្យប្រសើរឡើងដល់សុខភាពជាទូទៅ

### អត្ថប្រយោជន៍សម្រាប់គ្រូ

(Benefits Relevant to Teachers)

- កាត់បន្ថយភាពធុញថប់តប់ប្រមល់ និងជម្ងឺធុញថប់អារម្មណ៍
- បង្កើនថាមពល និងភាពក្លៀវក្លា
- កាត់បន្ថយគ្រោះថ្នាក់នៃជំងឺ
- ធ្វើឲ្យប្រសើរឡើងដល់សុខភាពជាទូទៅ
- ធ្វើឲ្យស្រលះល្អក្នុងចិត្ត
- បង្កើនសុខុមាលភាពខួរក្បាល ឬចិត្ត
- បង្កើនប្រសិទ្ធភាព ឬភាពសក្តិសិទ្ធិ
- បង្កើនការពេញចិត្តនិងទំនុកចិត្តលើខ្លួនឯង

## ការបង្កើតភាពស៊ីសង្វាក់គ្នា នៅក្នុងមនសិការប្រមូលផ្តុំ

Creating Coherence in Collective Consciousness




អត្ថប្រយោជន៍ជាច្រើននៃមនសិការជាមូលដ្ឋានគ្រឹះនៃការអប់រំ មិនត្រឹមតែជាគុណប្រយោជន៍សំរាប់សិស្ស-និស្សិតម្នាក់ៗប៉ុណ្ណោះទេ ថែមទាំងជះឥទ្ធិពលដល់សង្គមទាំងមូលទៀតផង។ ការ

ស្រាវជ្រាវដែលបានបោះពុម្ពផ្សាយយ៉ាងទូលំទូលាយបង្ហាញថា គ្រាន់តែមានមនុស្សពី២ ឬ៣រយនាក់ទៅ ២ ឬ៣ពាន់នាក់អនុវត្តកម្មវិធី TM និងបច្ចេកទេសឈានមុខរួមមានកម្មវិធី TM-Sidhi និង យោគីគ ប្លាយីង (Yogic Flying) អាចបង្កើតឲ្យមានភាពស៊ីសង្វាក់គ្នានៅក្នុងមនសិការប្រមូលផ្ដុំបាន នេះគឺជាអ្វីដែលអ្នកវិទ្យាសាស្ត្រហៅថា **ឥទ្ធិពលរបស់មហាឫសី** ។ ឥទ្ធិពលនៃភាពស៊ីសង្វាក់គ្នានេះ កាត់បន្ថយនិន្នាការអវិជ្ជមាននានា ដូចជាបទឧក្រិដ្ឋ និងសង្គ្រាមជាដើមហើយបង្កើនភាពខ្លាំងនៃទំនោរវិជ្ជមានរបស់សង្គមនិងសេដ្ឋកិច្ចដែលនឹងសាយភាយទៅដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋទាំងអស់។ (តម្រូវការចំនួនអ្នកអនុវត្ត យោគីគ ប្លាយីង (Yogic Flying) គឺអាស្រ័យទៅតាមទំហំប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសនោះ)។

ដូច្នេះនៅពេលដែលសិស្ស និស្សិត ២ ឬ៣រយនាក់អនុវត្តនៅក្នុងសាលា វាអាចធ្វើឲ្យរស់រវើកឡើងនូវវិស័យប្រមូលផ្ដុំទាំងមូលបានតាមរយៈការអនុវត្តជារៀងរាល់ថ្ងៃរបស់គេនូវកម្មវិធី យោគីគ ប្លាយីង នោះគេមិនគ្រាន់តែបង្កើនឲ្យមានភាពស៊ីសង្វាក់គ្នានៅក្នុងការបំពេញមុខងារនៃប្រព័ន្ធខួរក្បាលទាំងមូលរបស់គេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យមានការរស់រវើកឡើង នូវវិស័យរួបរួមផងដែរ (Field of Unity) ដោយការបង្កើតឲ្យមានភាពស៊ីសង្វាក់គ្នា នៅក្នុងមនសិការប្រមូលផ្ដុំ និងលើកស្ទួយប្រទេសជាតិរបស់គេឆ្ពោះទៅរកភាពមិនចាញ់ទៀតផង។

## ការលានុវត្តភាពថ្មីមួយកំពុងចាប់មានពន្លឺឡើង សម្រាប់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់តាមរយៈមនសិការជាមូលដ្ឋានគ្រឹះនៃការអប់រំ

A New Time is Dawning for the Human Race through Consciousness-Based Education

យើងកំពុងតែជួយជំរុញរដ្ឋាភិបាល និងអ្នកដឹកនាំក្នុងការអប់រំទាំងអស់ ដើម្បីធ្វើសកម្មភាពក្នុងការបង្កើតសាលាមិនចេះចាញ់ និងដាក់បញ្ចូលកម្មវិធីសិក្សា **មនសិការជាមូលដ្ឋានគ្រឹះនៃការអប់រំ** បន្ថែមលើកម្មវិធីសិក្សាដែលមានស្រាប់នៅតាមសាលាចំណេះទូទៅ មហាវិទ្យាល័យ សាកលវិទ្យាល័យ។ សិស្ស និស្សិតទាំងឡាយ នឹងទទួលបានលក្ខណៈខ្ពស់បំផុតនៃមនសិការ

ហើយបើការរស់នៅក្នុងជីវិតមួយប្រកបដោយសេរីភាព នោះជីវិតគេនឹងដើរស្របទៅនឹងច្បាប់ធម្មជាតិដោយស្វ័យប្រវត្តិ និងសេចក្ដីសុខទៅក្នុងមនសិការនៃជាតិសាសន៍ទាំងមូល។ ដូច្នេះមនុស្សគ្រប់រូប នឹងរស់នៅក្នុងជីវិតមួយដែលចាកផុតពីកំហុសឆ្គងនានា។

សម័យនៃពិភពលោកថ្មីមួយកំពុងតែចាប់មានពន្លឺឡើងតាមរយៈមនសិការជាមូលដ្ឋានគ្រឹះនៃការអប់រំ សូមកុំបណ្ដោយឲ្យការរងទុក្ខវេទនាវាបន្តនៅក្នុងពិភពលោកយើងនេះតទៅទៀត។ សូមដាក់បញ្ចូលកម្មវិធី **មនសិការជាមូលដ្ឋានគ្រឹះនៃការអប់រំ** នៅក្នុងកម្មវិធីសិក្សាប្រទេសរបស់អ្នកនៅក្នុងពេលឥឡូវនេះ។

- **សម្រាប់ព័ត៌មានពិស្ដារ លោកអ្នកអាចបើកមើលលើគេហទំព័រខាងក្រោមៈ**

**www.tm.org**
**www.mum.org**
**www.stressfreeschools.org**
**www.doctorsontm.org**

Adolto Yrure TM Teacher
Phone : 012 929 964

# អំពីនិបាតសព្ទ និងអាយតនិបាត

## (ត)

+ មួយទៀត ត្រង់កន្លែងអា.និ នៃ, កុំ ប្រើពាក្យដល់
+ ព្រះអង្គជាម្លប់ដ៏ត្រជាក់ដល់ប្រជាពលរដ្ឋទាំងពួង, ត្រូវប្រើថា : ព្រះអង្គជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋទាំងពួង ដូច្នេះវិញជ្បិត " នៃ " ស្មើគ្នានឹង " របស់ " (ជាម្លប់របស់)...។ល។
+ **ដល់**២ (កិ.បានសម្រេច,បានទីដែលត្រូវទៅមក)
+ គេបានទៅដល់ស្រុកគេហើយ។
+ គាត់បានទៅដល់ទីណាត់មុនគេ។
+ បុរសដែលត្រូវខ្លាគំរាមបំរុងស៊ីនោះ ក៏លាភរិយាចេញចាកគ្រឹះស្ថានដើរមកតាមផ្លូវយំបណ្ដើរផងដល់ពាក់កណ្ដាលផ្លូវក៏បានជួបនឹងសុភាទន្សាយ។
+ ខំធ្វើអំពើល្អ សាងកុសលកុំបីខ្ជិល ផលទានកើតពីសីល ជួយរំកិលដល់និព្វានហោង។

**សង្កេត**- ពាក្យ " ដល់ " (អា.និ) ច្រើនស្ថិតនៅខាងមុខនាមសព្ទដែលជាមនុស្ស ឯ " ដល់ " (កិ) ច្រើននៅមុខនាមសព្ទប្រាប់ទីកន្លែង។

+ **ដ៏ហើយ** (និ.ដែលធ្វើដោយ,ដែលធ្វើអំពី,សម្រេចមកអំពី,សុទ្ធសឹងតែ)
+ ប្រាសាទដ៏ហើយដោយថ្ម (ប្រាសាទដែលធ្វើអំពីថ្ម) ។
+ ប្រាសាទអង្គរវត្តដ៏ហើយដោយថ្ម គឺប្រាសាទដែលធ្វើអំពីថ្ម គឺប្រាសាទសុទ្ធសឹងតែថ្ម។
+ **ដ៏លង់** (និ.អង្វែង,យូរ)
+ អស់កាលដ៏លង់ គឺអស់កាលដ៏យូរលង់។
+ ទឹកដីខ្មែរកើតមកអស់កាលដ៏លង់ គឺអស់កាលដ៏អង្វែងណាស់មកហើយ។
+ **ដូច** (និ.ដែលមានសណ្ឋានមានរូបត្រូវគ្នាឲ្យចាប់ច្រឡំ)
+ របស់នេះដូចគ្នា នឹងរបស់នោះដែរ។
+ ខ្មែរជឿព្រះពុទ្ធសាសនា គឺជឿការពិតដែលព្រះពុទ្ធបានសំដែងដូចពាក្យថា "ធ្វើបុណ្យបានបុណ្យធ្វើបាបបានបាប"។ល។
+ សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណាពេញពោរស្មើធារា ដូចជលសាធំទូលាយ។
+ **ដូច្នេះ (ដូច,ច្នេះ)** (និ.ដូចនេះ,យ៉ាងនេះ,ទោះបីគេសរសេរជា "ដូចនេះ" ក៏ត្រូវអានថា "ដូច្នេះដែរ")
+ ពុទ្ធសាសនិកជនខ្មែរបានចាត់ទុកព្រះសង្ឃជាគ្រូ ជាទីគោរពសក្ការៈរបស់ខ្លួន។ ដូច្នេះព្រះសង្ឃគប្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយពន្យល់ណែនាំពុទ្ធបរិស័ទឲ្យដើរតាមគន្លងធម៌។
+ ហេតុដែលព្រះពុទ្ធបង្រៀនឲ្យមនុស្សលះអកុសលទាំងបីគឺលោភៈ ទោសៈ មោហៈ ជាដើម ព្រោះវានាំឲ្យមនុស្សសាងបាបកម្ម។ ដូច្នេះយើងឃើញថាការលះលោភៈដោយការធ្វើទាន។

+ **ដូច្នោះ (ដូច.ច្នោះ)** (និ.ដូចនោះ យ៉ាងនោះ ទោះបី គេសរសេរជា "ដូចនោះ ក៏ត្រូវអានថា" ដូចឆ្នុះដែរ)

+ ពស់កេងកងឮនាងអេតប្រាប់ដូច្នោះស្មានថាឪពុកនាងទៅជួញអង្កាំមិនទាន់មកពីជួញ ក៏ទៅតាមនាងអេតដូចថ្ងៃមុនៗ។

សង្កេត "ដូច្នេះ" ច្រើនប្រើនៅឃ្លាទី២ សម្រាប់បញ្ជាក់នូវផលជាវិជ្ជមានក្នុងឃ្លាទី១។

+ **ដូចដល់** (និ.ជិតនឹងដល់ទី ច្រើនប្រើតែក្នុងកាព្យ)

+ ដូចដល់ពុំដល់ ជិតនឹងដល់ ប៉ុន្តែនៅពុំទាន់បានដល់ពិតប្រាកដនៅឡើយ (សាស្ត្រាច្បាប់ក្រម)។

+ **ដើម្បី** (អានិ. បម្រុង បម្រុងនឹង សម្រាប់ សម្រាប់នឹង ឬប្រយោជន៍នឹង)

+ ពួកមនុស្សបានជាខំរៀន ខំរក ខំប្រព្រឹត្តសុចរិតស្លូតត្រង់ខ្លាំងម្ល៉េះ តើដើម្បីអ្វី?
  - ដើម្បីសេចក្តីសុខនិងសេចក្តីចម្រើន។

+ មនុស្សយើងម្នាក់ៗស៊ីដើម្បីរស់ ឬរស់ដើម្បីស៊ី?

+ ការទស្សន៍ទាយពុំមែនជាពាក្យពិតទាំងអស់ឡើយកន្លែងខ្លះនិយាយផ្សំតម្រូវចិត្តអ្នកមកទាយ ដើម្បីលាភសក្ការៈផ្ទាល់ខ្លួនរបស់គ្រូទាយនោះតែប៉ុណ្ណោះ។

+ ព្រះធម៌របស់ព្រះពុទ្ធសាសនាប្រតិបត្តិដើម្បីលះបង់លោភៈ ទោសៈ មោហៈ អវិជ្ជាជាដើម។

+ **ដែរ** (និ. ដូចគ្នា បានដូចគ្នា ផង)

+ ដូចពាក្យថា ខ្ញុំទៅដែរ ដូច្នេះក៏បានដែរ។

+ អ្នកទៅជាមួយនឹងខ្ញុំដែរឬ?

+ ល្អគ្រាន់បើដែរ របស់នេះ។

+ ក្រុមអ្នកផ្សាយសាសនាគ្រិស្តដែលចែកអំណោយដល់ខ្មែរហើយបង្ខំឲ្យគេជឿសាសនារបស់ខ្លួនមានលក្ខណៈដូចគ្នានឹងអ្នកស្ទូចត្រីដែលបិទនុយត្រង់ងៀងសន្ទូចបញ្ឆោតឲ្យត្រីវាស៊ីនោះដែរ។

+ **ដែល១** (អានិ. ពាក្យប្រាប់ដំណើរនៃអំពើសម្រាប់និយាយភ្ជាប់នាំមុខនាមសព្ទ) =
  + ការដែលខ្ញុំធ្វើ ពាក្យដែលគេនិយាយ ដំណឹងដែលខ្ញុំឮ សាលាដែលរាជការចំណាយប្រាក់ឲ្យសង់...

+ **ដែល២** (និ. សំណល់ របស់ដែលសល់ឬដែលគេប្រើប្រាស់ហើយ)
  + វាស៊ីបាយដែលគេ វាស្លៀកពាក់ខោអាវដែលគេ វាស្លៀកសំពត់ដែលសល់ពីគេ...

*(នៅមានត)*

*លោក* **ឝិត សៀខ**

*អតីតសាស្ត្រាចារ្យទុតិយភូមិ ១៩៧២*

# ទស្សនៈយល់ដឹងពីភាពឆ្លាតខាងអារម្មណ៍របស់អ្នកធ្វើការងារអប់រំ

ភាពឆ្លាតខាងអារម្មណ៍ គឺជាបច្ច័យសំខាន់បំផុតសម្រាប់អ្នកធ្វើការងារអប់រំ។ គ្រប់យ៉ាងដែលធ្វើឲ្យអ្នកធ្វើការងារអប់រំទទួលបានជោគជ័យលើការងារគឺអាស្រ័យត្រង់ថាអ្នកធ្វើការងារអប់រំខ្លួនឯងមានភាពវៃឆ្លាតខាងអារម្មណ៍ដែរឬទេ? និងមានដោយកម្រិតណាដូចជាការផ្ដួចផ្ដើមអារម្មណ៍ ការចេះប្រើប្រាស់អារម្មណ៍ ការសម្របសម្រួលអារម្មណ៍ទៅតាមកាលៈទេសៈពេលវេលា ការចេះយល់ដឹងអារម្មណ៍ខ្លួនឯង និងអារម្មណ៍អ្នកដទៃ។ល។

## I. គោលបំណង

ទស្សនៈយល់ដឹងពីភាពឆ្លាតខាងអារម្មណ៍ទាំងឡាយខាងលើនេះមានគោលបំណងផ្ដល់ឲ្យអ្នកធ្វើការងារអប់រំយល់ដឹងអំពីលក្ខណៈសម្បត្តិបុគ្គលផ្ទាល់ខ្លួនម្នាក់ៗដូចជា៖

- ខ្លួនមានជំនាញក្នុងការគិត ពិចារណា ស្ដាប់ វិភាគ និងទំនាក់ទំនង
- ចេះយល់ដឹងបត់បែន ផ្លាស់ប្ដូរ និងមានសមត្ថភាពក្នុងការឈានទៅរកភាពប្រសើរឡើងវិញ និងឆាប់របស់ក្រោយពីបានទទួលរងនូវបញ្ហាប្រឈមមួយចំនួន
- មានការជឿជាក់លើខ្លួនឯង មានកម្លាំងចិត្តខ្ពស់ក្នុងការដោះស្រាយបញ្ហា និងស្ថាបនាបាននូវស្នាដៃ សកម្មភាពផ្សេងៗ ទង្វើលើអាជីព និងការងារបច្ចុប្បន្នរបស់ខ្លួន
- ព្រមទាំងមានសមត្ថភាពក្នុងការចេះរួបរួមគ្នា ធ្វើការងារជាពួក ជាក្រុម ជាមួយអ្នកដទៃ និងចេះរិះរកវិធីដោះស្រាយបញ្ហាបានល្អប្រសើរ។

## II. តើអ្នកធ្វើការងារអប់រំត្រូវមានភាពឆ្លាតខាងអារម្មណ៍ដែរឬទេ?

ដើម្បីយល់ដឹងបញ្ហានេះអ្នកធ្វើការងារអប់រំទាមទារឲ្យមានភាពឆ្លាតខាងអារម្មណ៍តាមគោលការណ៍គ្រឹះដូចតទៅ៖

### ១- ការមានសតិក្នុងខ្លួន

អ្នកធ្វើការងារអប់រំ ត្រូវយល់ដឹងពីអារម្មណ៍ខ្លួនឯង និងមានសមត្ថភាពក្នុងការសម្រេចចិត្តឲ្យបានត្រឹមត្រូវ និងល្អប្រសើរ និងត្រូវស្គាល់ខ្លួនឯងយ៉ាងច្បាស់ថាខ្លួនពូកែខាងអ្វី ខ្សោយខាងអ្វី និងចេះរកវិធីជួយខ្លួនឯងឲ្យបានសមរម្យ។

### ២- ការមានកម្លាំងចិត្ត

អ្នកធ្វើការងារអប់រំ ត្រូវចេះបង្កើនប្រសិទ្ធភាពការងារ ដើម្បីសម្រេចគោលដៅដែលគ្រោងទុក ចៀសវាងការមានទំនាស់ក្នុងចិត្តទៅលើរាល់ឧបសគ្គនានាដែលគ្រាន់តែជាដំណាក់កាលមួយដែលត្រូវឆ្លងកាត់តែប៉ុណ្ណោះ។ ការព្យាយាមបង្កើនគុណសម្បត្តិផ្ទាល់ខ្លួនផ្សេងៗដូចជា គំនិតផ្ដួចផ្ដើមភាពអំណត់ព្យាយាម ការសម្រេចចិត្ត គំនិត និងសកម្មភាពឲ្យកាន់តែរឹងមាំបន្ថែមទៀតជាដើម។

**៣- ចេះគ្រប់គ្រងខ្លួនឯង**

អ្នកធ្វើការងារអប់រំត្រូវមានមនសិការទទួលខុសត្រូវ យល់ដឹង និងស្គាល់នូវអ្វីដែលល្អ និងអាក្រក់ ស្គាល់ពីតម្លៃពិតនៃជីវិត និងដើម្បីឈានទៅរកភាពជោគជ័យនៃជីវិតតើត្រូវធ្វើអ្វីខ្លះ? ចេះផ្លាស់ប្ដូរអារម្មណ៍មួហ្មង និងភាពមិនប្រក្រតីរបស់ខ្លួនឲ្យបានឆាប់រហ័សរួចមកចេះរៀបចំអារម្មណ៍របស់ខ្លួនឲ្យបានល្អប្រសើរឡើងវិញ។

**៤- ការស្គាល់ និងយល់ដឹងអំពីអ្នកដទៃ**

អ្នកធ្វើការងារអប់រំ ត្រូវចេះស្វែងយល់មនុស្សនៅជុំវិញខ្លួនពី អារម្មណ៍ គោលបំណង និងតម្រូវការរបស់អ្នកដទៃ ហើយក៏ត្រូវមានសមត្ថភាពផងដែរ ទៅលើការបញ្ចុះបញ្ចូលទឹកចិត្តមនុស្សដែលមាន ប្រភេទខុសៗគ្នា ឲ្យចេះរួមរស់ និងធ្វើការងារជាមួយគ្នា។

**៥- ការយល់ដឹងអំពីសង្គម**

អ្នកធ្វើការងារអប់រំត្រូវចេះយល់ដឹងអំពីស្ថានភាពសង្គម និងនយោបាយរួមគ្នា បង្កើនសមត្ថភាពមានទំនាក់ទំនងល្អជាមួយបណ្ដាញការងារនិងសង្គម ហេតុនេះភាពឆ្លាតខាងអារម្មណ៍ និងអាចជួយបន្ថែមទៅលើជំនាញដែលយើងមានស្រាប់ដើម្បីជួយឲ្យការងារទទួលបានលទ្ធផលល្អប្រសើរជួយសង្គម និងមនុស្សដទៃទៀតដែលរស់នៅក្នុងសង្គម។

ភាពឆ្លាតខាងអារម្មណ៍មិនមែនមានន័យថាត្រូវធ្វើខ្លួនឲ្យទៅជាមនុស្សដែលគួរស្រឡាញ់ ឬជាការបង្ហាញរបស់ខ្លួនដើម្បីឲ្យអ្នកដទៃបានដឹងនោះទេ តែវាជាការហ្វឹកហាត់បញ្ចេញអារម្មណ៍ទៅតាមផ្លូវដ៏សមរម្យមួយនៅក្នុងកាលៈទេសៈណាមួយដែលអាចធ្វើឲ្យអ្នកធ្វើការងារអប់រំយល់ដឹងអំពីអ្នកដទៃក្នុងន័យសហការធ្វើការងារជាមួយគ្នាឲ្យបានល្អប្រសើរ។

III. **តើភាពឆ្លាតខាងអារម្មណ៍របស់អ្នកធ្វើការងារអប់រំខុសពីអ្នកដទៃដូចម្ដេច?**

ប្រសិនបើអ្នកធ្វើការងារអប់រំមានសមត្ថភាពខាងអារម្មណ៍កាន់តែច្រើននោះ បច្ច័យសំខាន់នៅលើការតាំងចិត្តដើម្បីសម្រេចជោគជ័យ និងមានសមត្ថភាពក្នុងការធ្វើការងារជាក្រុមដោយគួបផ្សំទៅលើបច្ច័យផ្សេងៗទៀតដូចជា៖

- **ការស្គាល់និងយល់ដឹងអំពីអ្នកដទៃ** ឬសមត្ថភាពទស្សន៍ទាយទិសដៅនាពេលអនាគតបានយ៉ាងជាក់ច្បាស់ដោយប្រើប្រាស់បណ្ដុំព័ត៌មានជាច្រើនដែលមានក្នុងបច្ចុប្បន្ន និងចំពោះមុខឬមើលឃើញអំពីស្ថានភាពសង្គមការងារ ឬអំពីទំនាក់ទំនង និងឥទ្ធិពល របស់អ្នកដទៃ ក្រុមនិងក្រុម បុគ្គលនិងបុគ្គល បុគ្គលនិងក្រុម។
- **ការមានការជឿជាក់ទៅលើសក្ដានពល** និងសមត្ថភាពក្នុងការប្រឈមមុខទប់ទល់នឹងលក្ខខណ្ឌ ជីវិតដែលគេជួបប្រទះ។

ហេតុនេះគ្រាន់តែមានការជឿជាក់លើសមត្ថភាពឆ្លាតខាងអារម្មណ៍របស់ខ្លួនតែប៉ុណ្ណោះ ក៏អាចទស្សន៍ទាយ និងសន្និដ្ឋានបានថា អ្នកធ្វើការងារអប់រំខ្លួនឯងនឹងទទួលបានភាពជោគជ័យនៅក្នុងការងារនាពេលខាងមុខ។

- **ការមានបញ្ញាញាណ**

គឺជាការដឹងដោយញាណពីអាថ៌កំបាំងដែលផ្ដើមឡើងនូវការនឹកភ្នកដឹងដោយស្វ័យប្រវត្តិហើយ

ក៏មិនមែនដោយការគិតរបស់គេចេញពីបេះដូងនោះទេ គឺដោយការប្រើអារម្មណ៍ដែលអាចធ្វើឲ្យគេមានការសម្រេចចិត្តបានយ៉ាងត្រឹមត្រូវទៀតផង។ ហេតុនេះ អ្នកធ្វើការងារអប់រំគឺជាអ្នកមានសមត្ថភាពខ្ពស់បំផុតប្រសិនបើគេមានភាពវៃឆ្លាតខាងអារម្មណ៍ មិនរឹងត្អឹង មិនងាប់ក្រឡា មានភាពស្ងប់ស្ងាត់ អត់ធ្មត់ រឹងមាំ ចេះសម្របសម្រួលទៅតាមកាលៈទេសៈ និងចុះសម្រុងជាមួយអ្នករួមការងារមិនធ្វើឲ្យមានការប្រេះស្រាំក្នុងក្រុមការងាររបស់ខ្លួន។

សរុបមកវិញ ភាពឆ្លាតខាងអារម្មណ៍ គឺជាចំណែកមួយនៃបុគ្គលិកលក្ខណៈរបស់បុគ្គលដែលធ្វើឲ្យអ្នកធ្វើការងារអប់រំអាចមានសមត្ថភាពក្នុងការបង្កើនថាមពលនឹងសមត្ថភាពក្នុងការគ្រប់គ្រងអារម្មណ៍លើខ្លួនឯងព្រមទាំងយល់ដឹងទៅលើសង្គមបានយ៉ាងល្អប្រសើរ។

ហេតុនេះ អ្នកធ្វើការងារអប់រំត្រូវយល់ដឹងថា តើខ្លួនមានភាពឆ្លាតខាងអារម្មណ៍ដែរឬទេ? និងមានសមត្ថភាពក្នុងការប្រើប្រាស់ភាពឆ្លាតខាងអារម្មណ៍របស់ខ្លួនបានកម្រិតណា បែបណានៅក្នុងអាជីពការងារប្រចាំថ្ងៃរបស់ខ្លួនទាក់ទងនឹងមនុស្សជុំវិញខ្លួន និងសង្គម៕

*លោកស្រី **អ៊ឹម សុផល្លី** អនុប្រធាននាយកដ្ឋាន យុវជន*

## ដកឃ្លា ឬ ដក ឃ្លា?

អត្ថបទកត់លើផ្ទៃក្រដាស
សរសេរផ្ដេសផ្ដាសឥតយល់ន័យ
ដកឃ្លាឃ្លាតពាក្យឆ្គងសំដី
មិនដឹងហេតុអ្វីចេះតែដក។
ជួនកាលដកឃ្លាតាមចិត្តចង់
តម្រែតម្រង់ក៏ខំដក
ឃ្លាឃ្លោងឆ្គងន័យមិនខ្វីក្អក
ទុកឲ្យគេបកស្រាយតាមចិត្ត។
តាមពិតដកឃ្លា និងអត្ថន័យ
ដូចប្រពន្ធប្ដីស្មោះស្នេហ៍ស្និទ្ធ
ដកឃ្លាខុសក្បួនដូចក្បត់ផិត
ដកឃ្លា ជាប់ជិត ខុសគ្នាជាក់។
<u>**បង ប្អូន**</u> ជាជនពីរផ្សេងគ្នា
<u>**បងប្អូន**</u> គ្មានគ្នាមានតែម្នាក់
អាចបងឬប្អូន ឬបញ្ជាក់
ថាពូ មីងម្នាក់ក៏បានដែរ។

- ពេលកើតហេតុ តើមាន<u>**វត្តមាន**</u>លោកនៅទីនោះដែរឬទេ?
- មាន<u>**វត្ត**</u> <u>**មាន**</u>លោក វាជារឿងធម្មតា តែបើមានវត្ត គ្មានលោកវិញ ទើបជារឿងចម្លែក។

បណ្ឌិត ច័ន្ទ សំណព្វ

# សិស្សរៀនខ្សោយ និងសិស្សមានចរិតទុយមុយ នឹងអាចប្រសើរឡើងបើគ្រូចេះរកវិធីជួយពួកគេ

ជាទូទៅនៅក្នុងថ្នាក់រៀននីមួយៗរមែងមានសិស្សដែលទទួលការសិក្សាដោយពុំបានចំណេះដឹងស្មើៗគ្នាទាំងអស់នោះទេ។ គេសង្កេតឃើញមានសិស្សរៀនខ្សោយ និងមានចរិតទុយមុយពុំសូវនិយាយស្ដីនោះខ្លះពុំខាន។ សិស្សទាំងនោះវាចង់បានជាសិស្សខ្សោយ ឬចង់ធ្វើចរិតទុយមុយដូចនេះ ឬយ៉ាងណា? គឺពុំចង់បានដូចនេះឡើយ។

បញ្ហាសិស្សរៀនខ្សោយ គឺមានដើមហេតុរបស់វាដែលបណ្ដាលមកពីកត្ដាផ្សេងៗ តើមកពីកត្ដាសាលា? គ្រូ? ឬកត្ដាខ្លួនឯង? នៅពេលដែលឡើងថ្នាក់ជាមួយគ្រូថ្មី នោះគ្រូថ្មីត្រូវរកមូលហេតុនោះឲ្យឃើញតាមការសាកសួរពីសិស្សគ្នាវា ឬសួរគ្រូប្រចាំថ្នាក់ឆ្នាំចាស់។ល។ បើពួកគេខ្សោយទៅហើយគ្រូថ្នាក់ថ្មីទុកចោលទៀតធ្វើឲ្យគេងកោពុំខាន រហូតឈានទៅដល់ការបោះបង់ការសិក្សាផងក៏មាន។ ដូចនេះគប្បីអាចរកវិធីជួយពួកគេតាមវិធីផ្សេងៗ ដូចជាឲ្យអង្គុយតុមុខជិតអ្នកពូកែ គ្រូឧស្សាហ៍ហៅសួរសំណួរងាយៗ ចំៗឈ្មោះ ឬលើកទឹកចិត្តដោយសរសើរជារឿយៗ ឲ្យសិស្សពូកែឧស្សាហ៍ទាក់ទង ឬធ្វើការងារជាដៃគូជាដើម។ បើសិស្សរៀនខ្សោយភាសាខ្មែរ ផ្នែកអំណានគប្បីរកវិធីជួយឲ្យគេអានពាក្យស្រាលៗ រាក់ៗ ងាយចាំ និងបានសរសេរពាក្យនោះ។ បើគ្រូមានឆន្ទៈល្អ មានមនសិការវិជ្ជាជីវៈខ្ពស់ ស្រឡាញ់អាណិតសិស្សគ្រូត្រូវជួយគេឲ្យបានទាន់ពេល។ មិនតែប៉ុណ្ណោះគ្រូគប្បីដាក់កិច្ចការស្រាលៗងាយៗជាងសិស្សឯទៀត។ ចំពោះសិស្សមានចរិតទុយមុយពុំសូវនិយាយស្ដី ឬពុំមានសកម្មភាពនោះគ្រូគួររកវិធីជួយដោយឧស្សាហ៍និយាយសួរនាំទៅសិស្សនោះក៏ដូចជាឲ្យអង្គុយជិតកុមារដែលមានវោហារការនិយាយ។ល។ ពេលគ្រូសួរចំណុចខ្លឹមសារមេរៀនណាមួយដែលគេហ៊ានឆ្លើយទោះខុសឬត្រូវ គ្រូត្រូវតែសរសើរ និងលួងលោមលើកទឹកចិត្តគេឲ្យក្លាហានថែមទៀត។ និយាយរួមចរិតលក្ខណៈសិស្សបឋមសិក្សា គឺជាចរិតជោរ ឬបញ្ឆោរដើម្បីឲ្យគេមានភាពក្លាហាន បំបាត់ភាពតក់ម៉ក់ទុយមុយ។

ដោយការជួយរបស់គ្រូគ្រប់រូបភាពដូចខាងលើ យើងឃើញថា សិស្សរៀនខ្សោយ និងសិស្សតក់ម៉ក់ទុយមុយមួយចំនួនអាចឈានទៅរកភាពចម្រើនជឿនលឿនក្នុងការសិក្សាហើយថែមទាំងមានទំនុកចិត្តលើខ្លួនឯងដោយមានលោកគ្រូអ្នកគ្រូជាទីប្រឹក្សាដ៏កក់ក្ដៅសម្រាប់ពួកគេទាំងនោះ៕

*លោក **ធីវ សុផល** នាយកសាលា*

*បឋមសិក្សាដំរីយកទឹក ស្រុកសំរោង ខេត្តតាកែវ*

# ការអានសារអ៊ីមែល និងឆ្លើយតបអ៊ីមែល

ដោយ អ៊ុក ច័ន្ទរដ្ឋា អ៊ុក សម្ផស្ស និង កែល ភារុណ កែសម្រួលដោយ សុក ថា នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

នៅក្នុងលេខមុន យើងខ្ញុំបានចុះផ្សាយពីរបៀបបង្កើតអ៊ីមែលថ្មី និងការផ្ញើអ៊ីមែលដោយប្រើប្រាស់ Gmail នៅក្នុងលេខនេះយើងខ្ញុំសូមបង្ហាញលោកអ្នកអំពីរបៀបអានសារអ៊ីមែល និងឆ្លើយតបសារអ៊ីមែលទៅកាន់អ្នកដែលបានផ្ញើអ៊ីមែលមកយើង ។

## ១. ការស្វែងយល់ពីផ្ទាំងការងាររបស់ Gmail

សូមលោកអ្នកចូលទៅក្នុងGmail ដែលអ្នកបានបង្កើតរួចមកហើយដោយអនុវត្តតាមលំនាំដូចខាងក្រោម ៖




*រូបទី១៖ វាយអាសយដ្ឋាន Gmail ចូល ។*

- បើកកម្មវិធីរុករកអ៊ីនធឺណិត ( Browser )
- វាយ gmail.com នៅលើរបាអាសយដ្ឋាន
- បំពេញអាសយដ្ឋានអ៊ីមែល (រូបទី១)
- បន្ទាប់មកចុចលើពាក្យ Next
- បំពេញលេខសម្ងាត់ចូល (រូបទី២)
- ចុច Next




*រូបទី២៖ វាយលេខសម្ងាត់ចូល ។*

បន្ទាប់មកវានឹងលេចចេញនូវផ្ទាំងដូចខាងក្រោម ៖(រូបទី៣)

១. Compose: សម្រាប់ធ្វើការផ្ញើអ៊ីមែលទៅអ្នកដទៃ ។

២. Inbox: រក្សាទុករាល់អ៊ីមែលដែលគេបានផ្ញើមកយើង

៣. កន្លែងផ្ទុករាល់អ៊ីមែលដែលយើងបានផ្ញើទៅគេ

៤. Drafts: សម្រាប់រក្សាទុកបណ្ដោះអាសន្ននូវអ៊ីមែលដែលយើងបង្កើតតែមិនទាន់ផ្ញើទៅអ្នកដទៃ




*រូបទី៣៖ ទិដ្ឋភាពទូទៅនៅក្នុង Gmail ។*

## ២. របៀបអានសារនៅក្នុង Gmail

ដើម្បីអានសារដែលគេផ្ញើមកសូមអនុវត្តតាមការណែនាំដូចខាងក្រោម ៖

១. ចុចលើ Inbox




*រូបទី៤៖ ចុចលើសារដែលអ្នកចង់អាន ។*

២. ចុចលើ សារអ៊ីមែលណាមួយដែលអ្នកចង់អាន (រូបទី៤)

៣. បន្ទាប់មកវានឹងចេញផ្ទាំងដូចខាងក្រោម ៖ (រូបទី៥)




## ៣. របៀបឆ្លើយតបសារអ៊ីមែល

ដើម្បីជាការគួរសមនៅពេលដែលអ្នកបានទទួលអ៊ីមែលដែលគេបានផ្ញើមក អ្នកត្រូវឆ្លើយតបទៅអ្នកផ្ញើវិញ ដើម្បីបញ្ជាក់ប្រាប់គេថាយើងបានទទួលអ៊ីមែលដែលគេផ្ញើមក ។ ដើម្បីឆ្លើយតបសារសូមអនុវត្តដូចខាងក្រោម ៖

១. ចុចលើពាក្យ Reply ដែលនៅខាងក្រោមសារដែលយើងបានចុចអាន(រូបទី៦)




*រូបទី៦៖ ចុចលើពាក្យ Reply*

២. សរសេរខ្លឹមសារអ៊ីមែលដែលអ្នកចង់ផ្ញើទៅគេ (រូបទី៧)

៣. រួចចុចលើពាក្យ Send ជាការបញ្ចប់ (រូបទី៧)




*រូបទី៧៖ សរសេរអត្ថន័យអ៊ីមែល និងចុចលើពាក្យ Send ដើម្បីឆ្លើយតប ។*




## ទំនួញមេស្វា ត្រូវព្រានប្រមាញ់

(បទពាក្យប្រាំពីរ)

១- មេស្វាមួយត្រូវគ្រាប់កាំភ្លើង
ស្រវាឱបកូនយ៉ាងថ្នមថ្នាក់
មួយគ្រាប់ចំជើងឈាមសស្រាក់
បីបមលើកដាក់ បំពេថា។

២- ឱ!កូននឹមនួនស្ងួនសម្លាញ់
ឈឺណាស់កូនអើយ ចុកពើតផ្សា
មនុស្សព្រានវាបាញ់ម្ដាយហើយណា
ម្ដាយនឹងមរណាគ្រាតឡូវ។

៣- ឱបម្ដាយមកកូន ឱបឲ្យខ្លាំង
មុខកូនទ្រូងម្ដាយ ជិតជាប់នៅ
ភ្នែកម្ដាយស្រវាំង ណាស់ណាពៅ
ទឹកភ្នែកស្ងួនពៅ យំអាល័យ។

៤- មើលមុខម្ដាយមក មើលមកកូន
ម្ដាយប្រឹងតោងមែកដើមព្រឹក្សព្រៃ
ឈប់យំទៅស្ងួន នួនថ្លើមថ្លៃ
ខ្លាចភ្លាត់ធ្លាក់ដី ចំណីព្រាន។

៥- ដៃម្ខាងខំខ្ទប់មុខរបួស
ល្ហិតល្ហៃដៃជើង ញ័រសព្វប្រាណ
តែឈាមហូរហួស មិនស្រាកស្រាន្ដ
ចាប់អ្វីមិនបាន បានភ័យភិត។

៦- ម្ដាយខំរត់គេច មិនរួចឡើយ
អស់សង្ឃឹមហើយ ហួសបើគិត
ព្រានបានឃើញហើយតាមជាប់ស្អិត
ដង្ហើមរួតរឹត ថប់ឱរា។

៧- អាសូរតែកូននៅក្មេងខ្ចី
ឬមួយត្រូវរស់រងឯកា
តើកូនពិសី នឹងយ៉ាងណា?
ឬមួយមរណាដោយដៃព្រាន។

៨- ឱ!កូនសម្លាញ់ ឱនសំពះ
សុំក្ដីមេត្តា បានរស់រាន
ប្រញាប់រួតរះ អង្វរព្រាន
ឱ!លោកអ្នកព្រាន សន្ដោសផង។

៩- ឯកូនក្នុងផ្ទៃនឹងក្ស័យហើយ
សូមព្រានករុណា កុំប៉ុនប៉ង
នៅកូនកៀកកើយ ជាក់ច្បាស់ច្បង
ឲ្យបានរស់ផង ដោយស្មោះស្ម័គ្រ។

១០- ខ្ញុំនេះរស់នៅតែក្នុងព្រៃ មិនដែលស្រមៃរាតត្បាតអ្នក
ចំណីមួយពោះ មិនទុកដាក់ រស់បរិសុទ្ធជាក់ មិនលោភលន់។
១១- ម្ដេចឡើយខ្លួនខ្ញុំពុំគួរសោះ បែរទទួលគ្រោះ ធ្ងន់ពេកពន់
ជាចំណីព្រាន ព្រានទុរជន ធ្វើទុក្ខទារុណចងពាធា។
១២- គ្រោះកាចចង្រៃ កុំជួបទៀត ចូរអស់ផៅញាតិ រួចវេរា
បានកើតជាមនុស្សសមសោភា សាងបុណ្យស្មារលា នូវបាបកម្ម។
១៣- ជាតិមុន ជាតិនេះ ជ្រុលថ្លោះធ្លោយ បានដល់ជាតិក្រោយ អង្វែងឆ្នាំ
ព្រានអើយខ្ញុំសូមសច្ចាផ្ដាំ អហោសិកម្ម ត្រឹមនេះចុះ៕

..............................

**មេស្វា** : បើអ្នកជាខ្ញុំតើយ៉ាងណា? !!!..........កូនអើយ!...ម៉ែ...លា...!!!!...

**កូនស្វា** : ម៉ែ !!!!.......

**ព្រាន** : ពុទ្ធោ !!!...

**សាធុជន** : បើជាអ្នកវិញតើយ៉ាងណា?

ស្លាប់មេ ស្លាប់បា កូនកំព្រា
ទូញទុក្ខសង្វេគរស់វេទនា
មនុស្សគ្រប់គ្នា រស់សុំសុខ។

ឱ! លោកអ្នកព្រានទាំងឡាយ !!!...

សាច់ស្វា ឈាមស្វា និងរាងស្វា
ប្លែកគ្នាយ៉ាងណានឹងមនុស្សយើង
កុំបីស្រេកឃ្លានតាមទំនើង
ចចេសចចើង ជាប្រេតហើយ។

យើងជាមនុស្សប្រសើរលើសសព្វសត្វ មានប្រាជ្ញា មានវិចារណញ្ញាណខ្ពង់ខ្ពស់ មិនត្រូវឲ្យសត្វអប់រំណែនាំយើង ពិសេសការប្រព្រឹត្តចៀសពីអំពើបាប។ បើពុំដូច្នោះទេ យើងនឹងអន់ទន់ទាបសារជាតិមនុស្សអាចជាមនុស្សល្ងង់ខ្លៅឃោរឃៅជាងសត្វ...។

មួយវិញទៀត ប្រសិនបើទទួលទានខួរស្វា នាំមកនូវប្រាជ្ញាឈ្លាសវៃម្ល៉េះសម ៖

- ខួរក្បាលយើងអន់ជាងស្វា ច្បាស់ណាស់ថា យើងល្ងង់ជាងស្វា។
- ពុំអាចបៀតបៀនស្វាបានឡើយ។
- ស្វានឹងគ្រប់គ្រងយើងហើយ។
- នឹងថាស្វាមិនរស់នៅក្នុងព្រៃបែបនេះសោះឡើយ៕

*លោក* **ផេង កែន**

*ប្រធានការិ.រដ្ឋបាលមន្ទីរអប់រំ យុវជននិងកីឡា ខេត្តកំពង់ឆ្នាំង*

# សេដ្ឋីទិញដូង

(បទពាក្យប្រាំពីរ)

១- ថ្ងៃមួយលោកចង់ហូបដូងខ្ចី លោកមហាសេដ្ឋីដើររកទិញ
ទៅដល់ទីផ្សារលក់នោះមិញ លោកពោលពាក្យពេញទៅម្ចាស់ថា។
២- នែ អ្នកលក់ដូងមួយប៉ុន្មាន ប្រាប់ខ្ញុំឲ្យបានដឹងផងណា
ប្របាទប្រាំកាក់ទេលោកមហា សូមលោកមេត្តាទិញផងចុះ។
៣- យី ម្ដេចក៏ថ្លៃអ្វីម្ល៉េះហ្ន៎ ខ្ញុំមិនហ៊ានតព្រោះខ្លាចខុស
ស្ដាយប្រាក់ព្រោះថ្លៃមិនព្រមចុះ ចិត្តមិនស្រួលស្រុះដើររកទៀត។
៤- អ្នកលក់ឆ្លើយថាបើចង់ថោក មិនពិបាករកគួរលោកឆ្លៀត
ដើរមួយគីឡូទៅនាយទៀត នោះមានផៅញាតិលក់ថោកណាស់។
៥- ឮហើយសេដ្ឋីចេញដំណើរ ទាំងឬកគ្រាន់បើខាងប្រាក់កាស
សន្សំមួយកាក់ប្រាក់កើនច្បាស់ តាមក្បួនចាស់ៗបានប្រដៅ។
៦- ក៏ដើរទៅដល់ទីលក់មួយ អ្នកលក់រង្វើយបង្កួកហៅ
គួរទិញដូងខ្ញុំបេះក្ដៅៗ តម្លៃសោតនូវមួយបួនកាក់។
៧- សេដ្ឋីយកដៃរីតដើមទ្រូង ម្ដេចក៏លក់ដូងថ្លៃដល់ថ្នាក់
ខ្ញុំហ៊ានទិញនោះលុះតែអ្នក ចុះត្រឹមបីកាក់សមរម្យហើយ។
៨- អូយមិនបានទេលោកសេដ្ឋី សូមលោកប្រណីកុំកន្ដើយ
ចុះដល់បីកាក់មិនបានឡើយ ឯនាយលោកអើយក្រែងបានថោក។
៩- លោកគួរអញ្ជើញតាមផ្លូវថ្មី មួយគីឡូដីមានគរគោក
គេលក់ធូរថ្លៃសមចិត្តលោក ទិញថោកសន្សំបានមួយកាក់។
១០- សេដ្ឋីឮហើយស្ញើយចិត្តខ្លាំង ខ្ញុំមានកម្លាំងមិនបណ្ដាក់
នឹងស្រួតដំណើរមិនស្ទើរស្ទាក់ នឹងចំណេញប្រាក់មួយកាក់ទៀត។
១១- គិតហើយសេដ្ឋីមនុស្សកំណាញ់ រួតរះត្របាញ់មិនចោលស្មៀត
ប្រឹងដើរបន្តតាមមារយាទ ជាមនុស្សត្បិតត្បៀតអ្នកមៅស្និត។
១២- បែកញើសជាបខ្នងក៏មិនខ្វល់ ទោះហត់រចល់ក៏មិនគិត
មួយកាក់ជាប្រាក់កម្រពិត រិះតាមគំនិតទើបប្រសើរ។
១៣- ទៅដល់ទីថ្មីហត់គឃូរ សេដ្ឋីប្រឹងស៊ូទឹកមុខស្មើ
អឺយ៉ាដូចល្អថោកហើយតើ អ្នកថាមកមើលថ្លៃដូចម្ដេច។
១៤- អ្នកលក់ត្រេកអរឆ្លើយទៅវឹង ដូងខ្ញុំមួយហ្នឹងឆ្ងាញ់ល្អលេច
តម្លៃបីកាក់មិនមានភ្លេច ចិតស្អាតជាស្រេចជូនលោកធី។

១៥- ស្រែកទាំងដង្ហក់ដោយហត់ពេក
ចេះតែចង់កោរខ្ញុំសេដ្ឋី
តម្លៃខ្ពស់មេឃមិនថោកអ្វី
គួរតែចុះថ្លៃពីរកាក់ទៅ។

១៦- អូយចុះមិនបានទេលោកម្ចាស់
ចំណេញតិចតួចចិញ្ចឹមចៅ
បីកាក់ថោកណាស់កុំហ្មងសៅ
សូមលោកទិញទៅមិនខុសទេ។

១៧- ដូងខ្ញុំទឹកផ្អែមសាច់ក៏ខ្ចី
ទិញដូងនេះទៅកុំភារេ
បេះមកថ្មីៗធំជាងគេ
ប្រយ័ត្នមានគេទិញកាត់មុខ។

១៨- សេដ្ឋីគ្រញែងខ្លួនតបផ្ដាច់
ខ្ញុំមិនទិញសោះនាំកើតទុក្ខ
អ្នកអើយមិនបាច់ក្លែមទំនុក
ឆ្លងស្រុកទៅរកក្រែងចំណេញ។

១៩- ថាហើយសេដ្ឋីចេញដំណើរ
សំដៅឯនាយឆ្ងាយម្ដេចមិញ
ខំប្រឹងរត់ដើរដូចគេដេញ
ក៏ចិត្តទន្ទេញរិះរកប្រាក់។

(*នៅមានត*)

*លោក **ឈា ឈឿន***
*អគ្គនាយករងគ.ប.ច.អ.យ.ក*

## បានប្រាក់ខែ តែជីវិតត្រូវអស់៣០ថ្ងៃ

មានមនុស្សច្រើនអ្នកណាស់ ដែលធ្វើការមានប្រាក់ខែហើយតែងតែទន្ទឹងរង់ចាំដាច់ខែ ដើម្បីនឹងបានប្រាក់ខែ។ នៅក្នុងសេចក្ដីនេះ គេមិនបានគិតដល់ជីវិត ដែលត្រូវបាត់បង់ទៅអស់ ៣០ថ្ងៃនោះឡើយ។ ជីវិតកាន់តែខិតជិតទៅរកសេចក្ដីស្លាប់ ឬសេចក្ដីស្លាប់កាន់តែខិតចូលមកជិត។ បានប្រាក់មកមែនតែជីវិតរបេះខាត។

ជីវិតថ្លៃពេកពន់ មហាសេដ្ឋី មហាមូលធន ក៏គ្មានអ្វីធានាជីវិតខ្លួនបានដែរ ដល់ពេលស្លាប់គឺស្លាប់ហើយ ប្រសិនបើធានាបានដោយទ្រព្យ អ្នកមានទ្រព្យមិនព្រមស្លាប់ឡើយ ដូច្នេះជីវិត ៣០ថ្ងៃ មិនមែនមានតម្លៃស្មើនឹងប្រាក់ខែនោះទេ អ្នកមានបញ្ញាគប្បីសន្សំនូវប្រយោជន៍ទុកដាក់ក្នុងចិត្តសន្ដាន ទើបបានមិនខាតនូវជីវិតមានតម្លៃនេះ។

ស្រង់ពីសៀវភៅមេរៀនជីវិត



## ពុទ្ធសាសនានៅកម្ពុជា (ត)



ព្រះពុទ្ធរូបប្រក់នាគ នៅកំពង់ស្វាយ កំពង់ធំ ចុងសតវត្សទី១២-ដើមសតវត្សទី១៣ ដំកល់នៅប៉ារីស

### ពុទ្ធសាសនាសម័យមហានគរ

ព.ស.១៣៤៥-១៩៧៥ (គ.ស.៨០២-១៤៣២)

ព្រះបាទជ័យវរ្ម័នទី២ ឡើងសោយរាជ្យក្នុង ព.ស១៣៤៥ទ្រង់តាំងរាជធានីនៅលើមហេន្រ្ទបពិត គឺភ្នំគូលែន ទ្រង់ជាព្រះមហាក្សត្រមួយអង្គប្រសើរក្រៃលែង ទ្រង់បានរួបរួមប្រទេសដែលបែកបាក់គ្នាជាពីរ គឺចេនឡាដីគោក និងចេនឡាដែនទឹកឲ្យទៅជាប្រទេសមានឯកភាពតែមួយឡើងក្នុងពង្សាវតារខ្មែរ។ ព្រះរាជាអង្គនេះមិនកាន់ពុទ្ធសាសនាទេ គឺទ្រង់កាន់សាសនាព្រាហ្មណ៍ ប៉ុន្តែពុទ្ធសាសនាថេរវាទ និងមហាយានក៏នៅជាមួយគ្នាដូចដើម។

ព្រះបាទឥន្ទ្រវរ្ម័នទី១ ឡើងសោយរាជ្យក្នុងព.ស.១៤២០ (គ.ស.៨៧៧) ទ្រង់តាំងរាជធានីនៅតំបន់រលួស ស្រុកស្ទូទ្រនិគម ខេត្តសៀមរាប ប្រាសាទបាគងជាឋានព្រះហរិហរៈ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ តែទ្រង់ប្រោសប្រណីពុទ្ធសាសនាដែរ។ ក្នុងរជ្ជកាលព្រះអង្គ គេសង្កេតឃើញពាក្យប្លែកថា "កម្ពុជៈ" នៅក្នុងសិលាចារឹកប្រាសាទព្រះគោកាល ពី គ.ស ៨៧៩ ដែលពីអតីតកាល មិនដែលឃើញពាក្យ "កម្ពុជៈ" ឬ "កម្ពុជទេស" នោះទេ។ មានសិលាចារឹកមួយពីគ.ស.៨៨៦ និយាយពីមន្ត្រីម្នាក់ឈ្មោះសោមាទិត្យៈ បានកសាងព្រះពុទ្ធរូបមួយអង្គ ហើយថ្វាយព្រះនាមថា "ត្រៃលោក្យនាថ"។

ព្រះបាទយសោវរ្ម័នទី១ ជាព្រះរាជបុត្រនៃព្រះបាទឥន្ទ្រវរ្ម័នទី១ ទ្រង់ឡើងសោយរាជ្យក្នុង គ.ស.៨៨៩ ហើយទ្រង់លើករាជធានីទៅនៅទីក្រុងឈ្មោះ "យសោធរបុរៈ" គឺអង្គរធំសព្វថ្ងៃនេះ។ ព្រះរាជាអង្គដំផ្តើម ទ្រង់បានទទួលស្គាល់ពុទ្ធសាសនាមហាយានជាផ្លូវការ មុនដំបូងបង្អស់ ក្នុងប្រវត្តិសាស្ត្រខ្មែរ តែទ្រង់ក៏ប្រោសប្រាណរាប់អានសាសនាព្រាហ្មណ៍ដូចពុទ្ធសាសនាដែរ។ ក្នុងកាលនោះ ពុទ្ធសាសនានិងសាសនាព្រាហ្មណ៍មិនមានការបៀតបៀនគ្នាទេ។ សាសនាទាំងអស់មានសិទ្ធិ និងបុព្វសិទ្ធិដូចៗគ្នា។ រជ្ជកាលតមក ព្រះរាជាច្រើនអង្គកាន់សាសនាព្រាហ្មណ៍។

ព្រះបាទរាជេន្ទ្រវរ្ម័ន (ឥន្ទ្រវរ្ម័នទី២?) ឡើងសោយរាជ្យក្នុងគ.ស.៩៤៤ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះឥសូរតែទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ព្រោះមានវត្តខាងពុទ្ធសាសនាកាន់តែច្រើនឡើងៗនៅជិតព្រះរាជធានី។ គ្រានោះ មានមន្ត្រីម្នាក់ជាមហាពុទ្ធសាសនិក បានកសាងវិហារ ៣កន្លែង មួយថ្វាយព្រះសម្មាសម្ពុទ្ធ មួយថ្វាយព្រះវជ្របាណិ មួយទៀតថ្វាយព្រះនាងប្រាជ្ញាបារមិតា។ ក្នុងរជ្ជកាលនោះ សេរីភាពក្នុងការកាន់សាសនាទូលាយណាស់ ហើយនាំសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាឲ្យរលាយចូលគ្នាផង។

ព្រះបាទជយវរ្ម័នទី៥ ជារាជបុត្រព្រះបាទរាជេន្ទ្រវរ្ម័ន ឡើងសោយរាជ្យក្នុងគ.ស.៩៦៨ ទ្រង់កាន់សាសនាព្រាហ្មណ៍ដូចព្រះបិតាដែរ តែរាជត្រកូល និងមន្ត្រីជាន់ខ្ពស់កាន់ពុទ្ធសាសនា ទ្រង់តែងតាំងកិរ្តិបណ្ឌិតជាប្រធានរដ្ឋមន្ត្រី។ សិលាចារឹកនៅវត្តស្រីសន្ធរចែងថា កិរ្តិបណ្ឌិតជាពុទ្ធសាសនិកដ៏មោះមុត។ សិលាចារឹកមួយនៅភូមិបន្ទាយនាង និយាយពីការកសាងបដិមាប្រាជ្ញាបារ-មិតាពីគ.ស.៩៨១ កសាងដោយមន្ត្រីឈ្មោះ ត្រិភុវនវជ្រៈ។ មន្ត្រីម្នាក់ទៀតឈ្មោះ សោមវជ្រៈ ត្រូវជាបងថ្លៃមន្ត្រីត្រិភុវនវជ្រៈ បានថ្វាយបដិមាលោកេស្វរៈក្នុងគ.ស.៩៨២។ សិលាចារឹកនៅប្រាសាទប្រដាកចែងពីព្រះរត្នត្រ័យ គឺព្រះពុទ្ធ ព្រះធម៌និងសង្ឃ។

ព្រះបាទសូរ្យវរ្ម័នទី១ ឡើងសោយរាជ្យក្នុងគ.ស.១០០២ ទ្រង់ជាបឋមក្សត្រពុទ្ធសាសនិកដែលបានទទួលស្គាល់ព្រះពុទ្ធសាសនាជាផ្លូវការក្នុងសម័យមហានគរ ហើយថែមទាំងជួយទំនុកបម្រុងពុទ្ធសាសនាទៀតផង ប៉ុន្តែមន្ត្រីរបស់ព្រះអង្គឈ្មោះ សង្គ្របណ្ឌិតកាន់សាសនាព្រាហ្មណ៍គោរពព្រះឥសូរ។ លោក ប្រិគ (L.Briggs) សរសេរក្នុងសៀវភៅ The ancient Empire ថាព្រះបាទសូរ្យវរ្ម័នទី១នេះទំនងជាព្រះរាជវង្សខាងព្រះវរបិតាមានការទាក់ទងមកពីព្រះរាជានៅក្រុង តាំព្រ-លិង្គៈ នៅជ្រោយម៉ាឡាយូ ដែលកាលនោះនៅក្នុងអំណាចអាណាចក្រ ស្រីវិជ័យ កោះស៊ូមាត្រា ខាងព្រះវរមាតាជាប់ទាក់ទងមកពីព្រះរាជវង្សសប្តទេវកុលគឺ ព្រះនាងប្រាណាជាអគ្គមហេសីនៃព្រះបាទរាជេន្ទ្រវរ្ម័នទី២ និងជានាយកនៃការិយាល័យរបស់ព្រះជយវរ្ម័នទី៥ ផង។ ក្នុងរជ្ជកាលនេះលទ្ធិមហាយានបានផ្សាយឥទ្ធិពលយ៉ាងខ្លាំងចូលមកប្រទេសកម្ពុជា។ គម្ពីរដីកាក្តី គ្រូបាអាចារ្យក្តីសុទ្ធតែចេញមកពីតាំព្រលិង្គៈ ដែលជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនា ដែលមានឈ្មោះថា "ស្រីធម៌រាជនគរ" គឺនគរស្រីធម្មរាជប៉ែកខាងក្រោមប្រទេសសៀមបច្ចុប្បន្ននេះ។ ក្នុងរជ្ជកាលព្រះអង្គរាជអាណាចក្រខ្មែរធំទូលាយណាស់ ព្រោះបានរួមទាំងលពបុរីដែលជាអាណាចក្រមនសម័យទ្វារវតី ដែលរាប់តាំងពីថាទុង (Thaton) ប៉េគូ ទន្លេមេណាមនិងទន្លេឥរាវតី ដែលបានកសាងជា

រាមញ្ញប្រទេសឡើង។ ព្រះបាទសូរ្យវរ្ម័ន ជាព្រះរាជាមានប្រាជ្ញាវៃឆ្លាតណាស់ ទ្រង់ជាពុទ្ធសាសនិក លទ្ធិមហាយាន ប្រកបដោយខន្តីយ៉ាងខ្ពង់ខ្ពស់ ហើយចេះរក្សាប្រោសប្រាណពុទ្ធសាសនាថេរវាទ ព្រមទាំងសាសនាព្រាហ្មណ៍ឲ្យនៅជាសុខឥតមានសៅហ្មងនឹងគ្នាឡើយ។ សិលាចារឹកខ្មែរនៅលពបុរី គ.ស.១០២២-១០២៥ ថ្លែងថា ភិក្ខុមហាយានក្ដី ភិក្ខុថេរវាទក្ដីនៅជាមួយគ្នាសុខក្សេមក្សាន្ត ឯពួកតាបសឥសីក៏ប្រតិបត្តិលទ្ធិព្រាហ្មណ៍បានដោយសេរីឥតមានការសង្កត់សង្កិនគ្នាឡើយ។ មានពុទ្ធរូបប្រក់នាគដែលពីដើមមិនធ្លាប់មាន។

ព្រះបាទធរណិន្ទ្រវរ្ម័នទី២ឡើងសោយរាជ្យក្នុងគ.ស.១១០៧-១១១៣ មានព្រះនាងស្រីជយ-រាជចូឌាមណីជាអគ្គមហេសីមានព្រះរាជបុត្រមួយអង្គប្រកបដោយគុណសម្បត្តិគ្រប់ប្រការ ជាមកុដរាជកុមារទៅអនាគត គឺព្រះបាទជយវរ្ម័នទី៧។ ព្រះបាទធរណិន្ទ្រវរ្ម័នកាន់ពុទ្ធសាសនាមុតមាំណាស់ ដូចមានសិលាចារឹកនៅប្រាសាទតាព្រហ្មជាភ័ស្តុតាង។

ព្រះបាទសូរ្យវរ្ម័នទី២ឡើងសោយរាជ្យក្នុងគ.ស.១១១៣ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះវិស្ណុ ហើយប្រហែលចូលទិវង្គតក្នុងគ.ស.១១៥០។

ព្រះបាទជយវរ្ម័នទី៧ ឡើងសោយរាជ្យក្នុងព.ស.១៧២៤ (គ.ស.១១៨១)ទ្រង់ជាព្រះរាជាមានព្រះកិត្តិនាមល្បីល្បាញបំផុតក្នុងពង្សាវតារខ្មែរទ្រង់ជាពុទ្ធសាសនិកដ៏ឆ្នើមគោរពព្រះពោធិសត្វអវ-លោកិតេស្វរៈ និងព្រះប្រាជ្ញាបារមិតា តាមក្រសែព្រះវរបិតា។ ព្រះអង្គសព្វព្រះរាជហឫទ័យចំពោះសាសនាព្រះចន្ទគឺព្រះសាក្យមុនី។ សម័យនោះ ពុទ្ធចក្រក្តី អាណាចក្រក្តីចម្រើនលូតលាស់អស្ចារ្យណាស់។ ក្សត្រមួយអង្គៗ គេលើកតម្កើងថាជាទេពតាទាំងអស់ទោះជាចូលទិវង្គតទៅហើយក្តី មានព្រះជន្មនៅក្តីគឺសុទ្ធតែជាអង្គពោធិសត្វអវលោកិតេស្វរៈ ឬជាព្រះប្រាជ្ញាបារមិតាដែលប្រកបដោយព្រហ្មវិហារធម៌។ ពិតមែនតែទ្រង់កាន់ព្រះពុទ្ធសាសនាមុតមាំ តែទ្រង់រាប់អានប្រោសប្រាណសាសនាព្រាហ្មណ៍ផងដែរ។ ទ្រង់បានតែងតាំងព្រាហ្មណ៍ជាបុរោហិតរបស់ព្រះអង្គ។ សិលាចារឹកនៅអង្គរធំចែងថា "នៅកម្ពុជប្រទេស មានអ្នកប្រាជ្ញចេះដឹងត្រៃវេទច្រើនណាស់។ មានបដិមា ២ គេជឿថាជាបដិមាព្រះបាទជយវរ្ម័នទី៧ គឺព្រះអង្គមានព្រះកាយធំសក្តិសម ព្រះកេសបួង។ បដិមាមួយនៅប្រាសាទអង្គរធំ មួយទៀតនៅប្រាសាទពិមាយ (ប្រទេសសៀម) ដែលគេយកតម្កល់នៅក្នុងពិពិធភណ្ឌស្ថានក្រុងបាងកក"។

(នៅមានត)

*ដោយលោក **ជ័យ សយ្យនា** ដកស្រង់ពី*

*សៀវភៅ "ពន្លឺពុទ្ធសាសនា" រៀបរៀងដោយលោក **សោម ខន***

# សេចក្តីសង្កេតចំពោះច្បាប់ផ្សេងៗ

ច្បាប់ដំបូន្មានដែលអ្នកប្រាជ្ញបុរាណចងក្រងទុកមកសម្រាប់ប្រៀនប្រដៅ ពត់ហាត់កាយ វាចា ចិត្ត របស់កុលបុត្រកុលធីតា មានច្រើនច្បាប់ណាស់ ដែលគេប្រមូលផ្តុំគ្នាមកឲ្យឈ្មោះសរុបមួយថា "ច្បាប់ផ្សេងៗ"។ ដើម្បីយល់ពីផលប្រយោជន៍ និងទ្រង់ទ្រាយច្បាប់ទាំងនេះឲ្យច្បាស់លាស់ គប្បីធ្វើការសង្កេតដូចតទៅនេះ៖

1. **ប្រភពដើម**

អត្ថបទច្បាប់ទាំងនេះ សុទ្ធតែគ្មានចុះកាលបរិច្ឆេទឲ្យយើងដឹងច្បាស់ថា កើតនៅក្នុងឆ្នាំណាប្រាកដប្រជានោះទេតែអ្នកសិក្សាអាចសម្គាល់បានថា ជាអត្ថបទកើតនៅក្នុងសម័យឧដុង្គ គឺរវាងសតវត្សទី១៧ ១៨ និង១៩ ប៉ុណ្ណោះដោយសារគេប្រមាណតាមគោលគំនិតពាក្យសម្តី និងទំនៀមទម្លាប់ ដែលមានចែងក្នុងអត្ថបទទាំងនោះ។

ក្នុងច្បាប់ផ្សេងៗគេរកឃើញកំណើតដើមនៃគំនិតតែងតែដកស្រង់បានពីប្រភព ៣គឺ៖

**ក**-មួយភាគធំ អ្នកនិពន្ធដកស្រង់គំនិតអំពីដំបូន្មានរបស់ព្រះពុទ្ធ (ពុទ្ធឱវាទ) ព្រោះអ្នកនិពន្ធច្រើនជាអ្នករៀនសូត្រជ្រៅជ្រះខាងពុទ្ធសាសនាដែលជាវិជ្ជាជាន់ខ្ពស់ក្នុងកិច្ចសិក្សារបស់ខ្មែរយើងសម័យនោះ។

**ខ**-អ្នកនិពន្ធស្រង់គំនិត និងពាក្យសម្តីដែលជាទំនឹមទំនៀមបុរាណដែលអ្នកស្រុកចាំមាត់តៗគ្នាមកអធិប្បាយ។

**គ**-អ្នកនិពន្ធដកស្រង់ការពិសោធផ្ទាល់ដែលគេបានជួបប្រទះក្នុងជីវភាពរាល់ថ្ងៃតែងមានដំណើរត្រូវខ្លះខុសខ្លះ ដែលអ្នកនិពន្ធនិយមធ្វើការសង្កេត ហើយចងចាំទុកយកមកប្រៀនប្រដៅកូនចៅតៗមកទៀត។

អាស្រ័យដោយប្រភពទាំងបីនេះ ទើបន័យក្នុងច្បាប់ផ្សេងៗមានលាយការហួសសម័យនិយមខ្លះ ខាងផ្នែកទំនៀមរស់នៅ ប៉ុន្តែត្រូវជានិច្ច ខាងគោលការណ៍អប់រំ និងគោលសីលធម៌។

2. **ន័យខ្លឹមសារ**

ច្បាប់ផ្សេងៗ ពត់ហាត់មនុស្សឲ្យមានចរិយាល្អដើម្បីរស់នៅសុខសាន្តក្នុងសង្គមដែលច្បាប់ទាំងនេះមាន អប់រំតាមន័យផ្សេងគ្នាដូចជា៖

**ក**-អប់រំឲ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវ តាមគន្លងប្រពៃណីជាតិដែលជាកេរអរិយធម៌យូរអង្វែងហើយ។

**ខ**-ដឹកនាំឲ្យមានប្រាជ្ញាវាងវៃ កាលបើឮ ឬបើឃើញបញ្ហាអ្វីមួយកើតឡើងភ្លាម ក៏អាចយកប្រាជ្ញានោះទៅដោះស្រាយបានភ្លាមៗគ្រប់ពេលដែលគេជួបប្រទះក្នុងមុខរបរក្នុងការងារប្រចាំថ្ងៃ។

**គ**-បង្កើតសណ្តាប់ធ្នាប់ល្អ ក្នុងរបបរស់នៅតាមគន្លងច្បាប់គ្រប់គ្រងប្រទេស ព្រមទាំងជាតិដាស់តឿនក្រើនរំលឹកដល់អ្នកក្រោយៗទៀតផង។

រួមសេចក្តីទៅ ច្បាប់ផ្សេងៗជាកម្រងចំណេះប្រាជ្ញាមនុស្ស ក្នុងសម័យនីមួយៗដែលជាមធ្យោបាយជួយដោះស្រាយបញ្ហារាយរងក្នុងសង្គម និងរៀបចំគ្រួសារឬសង្គមជាតិឲ្យសុខសាន្តល្អ។

3. **កាលបរិច្ឆេទ និងអ្នកនិពន្ធ**

ច្បាប់ផ្សេងៗទាំងអស់ មិនសូវមានចុះកាលបរិច្ឆេទឲ្យយើងដឹងច្បាស់ទេ ឯអ្នកនិពន្ធក៏មិនសូវបានស្គាល់នាមដែរ ខ្លះគ្រាន់តែដាក់ប្រាប់ងារ ឬប្រាប់មុខរបរដូចជាថា "អរិយសត្ថា" ឬជា "សេដ្ឋី" ជាអ្នកផ្តើមសរសេរឡើង។ មានតែច្បាប់ប្រុស ច្បាប់ស្រីទេ ដែលអ្នកនិពន្ធប្រាប់នាមថា "ម៉ឺនមៃ" ជាអ្នកតែង តែគ្មានបញ្ជាក់ថា លោកជាមន្ត្រីអ្វី? តែងពីឆ្នាំណាឡើយ។

ច្បាប់ត្រីនេតិ ច្បាប់កូនចៅ និងច្បាប់វិធូរបណ្ឌិតពិតជាកើតពីអ្នកប្រាជ្ញធំជុំណាស់ ព្រោះមានខ្លឹមសារពិសេស ប្រកបដោយអត្ថន័យជ្រាលជ្រៅទូលំទូលាយ។ ច្បាប់អរិយសត្ថា ច្បាប់ក្រម កើតពីព្រះសង្ឃឧបជ្ឈាយាចារ្យ ដែលប្រៀនប្រដៅសិស្ស ច្បាប់ពាក្យចាស់ ច្បាប់ហៃមហាជនកើតពីចាស់ៗព្រឹទ្ធព្រេងប្រដៅក្មេងៗតាមតម្រាយបុរាណ ច្បាប់កេរកាល កើតពីអ្នកមានម្នាក់ប្រដៅកូន។ ឯច្បាប់ព្រះរាជសម្ភារ គឺព្រះរាជសម្ភារខ្លួនឯង ជាអ្នកតែងហើយទោះជាលោកដាក់ឈ្មោះ ច្បាប់នេះថា រាជនេតិ តែអ្នកស្រុកនៅតែហៅ ច្បាប់ព្រះរាជសម្ភារដដែល។

សរុបសេចក្តីទៅគឺជាវិធីអប់រំរបស់ចាស់បុរាណលោកតែងតែប្រើតាមមធ្យោបាយអក្សរសិល្ប៍ គឺសរសេរជាពាក្យកាព្យឲ្យទន្ទេញចាំមាត់ រួចហើយស្រង់យកន័យដែលចាំមាត់នោះ រំលឹកទូន្មានខ្លួនឯងតែម្តងទៅ។ អ្នកសិក្សាសព្វថ្ងៃនៅតែដកស្រង់យកន័យល្អៗពីក្នុងនោះ មកប្រតិបត្តិអាចត្រូវបានជាដរាបដែរ បានជាគេចាត់ទុកច្បាប់ផ្សេងៗជាអក្សរសិល្ប៍សាមញ្ញមួយខាងការអប់រំមនុស្ស។

ច្បាប់ដែលមានក្នុងសៀវភៅ ច្បាប់ផ្សេងៗនេះមាន៖

-ច្បាប់ក្រម
-ច្បាប់អរិយសត្ថា
-ច្បាប់ប្រុស
-ច្បាប់កូនចៅ
-ច្បាប់បណ្តាំបិតា
-ច្បាប់វិធូរបណ្ឌិត
-ច្បាប់ព្រះរាជសម្ភារ
-ច្បាប់កេរកាល
-ច្បាប់ស្រី
-ច្បាប់ទូន្មានខ្លួន
-ច្បាប់ពាក្យចាស់
-ច្បាប់កូនចៅល្បើក
-ច្បាប់ត្រីនេតិ

*សមាគមសម្តេច ជួន ណាត*




## បច្ចុប្បន្នភាពស្ថិតិសមាជិក សមាជិកា ស.ប.ស.ខ. តាម រាជធានី-ខេត្តប្រចាំឆ្នាំ២០១៥

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ចំនួនសមាជិកសរុប | | ចំនួនសមាជិកកំពុងបំពេញការងារ | | ចំនួនសមាជិកចូលនិវត្តន៍ | | ចំនួនសពសរុប (ទូទាត់ក្នុងឆ្នាំ២០១៥) | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សមាជិក | គូស្រករ |
| ១ | ភ្នំពេញ | 12,365 | 6,779 | 10,619 | 5,921 | 1,746 | 858 | 71 | 37 |
| ២ | កំពង់ចាម | 8,744 | 5,367 | 6,912 | 4,884 | 1,832 | 483 | 74 | 47 |
| ៣ | កណ្ដាល | 10,050 | 4,699 | 7,992 | 4,157 | 2,058 | 542 | 60 | 28 |
| ៤ | បាត់ដំបង | 9,685 | 4,379 | 8,273 | 4,041 | 1,412 | 338 | 49 | 29 |
| ៥ | ព្រៃវែង | 8,939 | 2,758 | 6,990 | 2,548 | 1,949 | 210 | 60 | 29 |
| ៦ | តាកែវ | 8,469 | 2,266 | 6,768 | 2,131 | 1,701 | 135 | 42 | 24 |
| ៧ | កំពត | 6,551 | 2,497 | 5,437 | 2,306 | 1,114 | 191 | 31 | 22 |
| ៨ | កំពង់ធំ | 6,037 | 2,548 | 4,948 | 2,350 | 1,089 | 198 | 40 | 22 |
| ៩ | បន្ទាយមានជ័យ | 6,057 | 2,386 | 5,285 | 2,263 | 772 | 117 | 42 | 29 |
| ១០ | សៀមរាប | 6,425 | 2,995 | 5,601 | 2,791 | 824 | 204 | 29 | 13 |
| ១១ | ពោធិ៍សាត់ | 4,279 | 1,593 | 3,750 | 1,482 | 529 | 111 | 11 | 11 |
| ១២ | ស្វាយរៀង | 4,368 | 1,107 | 3,397 | 1,001 | 971 | 106 | 35 | 18 |
| ១៣ | កំពង់ស្ពឺ | 4,928 | 1,594 | 3,999 | 1,473 | 929 | 121 | 35 | 7 |
| ១៤ | កំពង់ឆ្នាំង | 4,257 | 1,654 | 3,685 | 1,512 | 572 | 142 | 30 | 15 |
| ១៥ | ក្រចេះ | 3,080 | 1,419 | 2,473 | 1,282 | 607 | 137 | 18 | 9 |
| ១៦ | ព្រះសីហនុ | 2,018 | 726 | 1,855 | 699 | 163 | 27 | 2 | 1 |
| ១៧ | ព្រះវិហារ | 1,388 | 502 | 1,332 | 487 | 56 | 15 | 7 | 4 |
| ១៨ | ឧត្ដរមានជ័យ | 976 | 129 | 867 | 123 | 109 | 6 | 2 | 6 |
| ១៩ | ស្ទឹងត្រែង | 906 | 375 | 799 | 357 | 107 | 18 | 5 | 5 |
| ២០ | ប៉ៃលិន | 700 | 281 | 684 | 281 | 16 | 0 | 1 | 0 |
| ២១ | កោះកុង | 857 | 292 | 806 | 285 | 51 | 7 | 2 | 1 |
| ២២ | រតនគិរី | 889 | 313 | 847 | 311 | 42 | 2 | 2 | 2 |
| ២៣ | កែប | 417 | 121 | 387 | 121 | 30 | 0 | 0 | 0 |
| ២៤ | មណ្ឌលគិរី | 765 | 275 | 745 | 269 | 20 | 7 | 0 | 0 |
| ២៥ | ត្បូងឃ្មុំ | 4,481 | 1,746 | 3,598 | 1,632 | 883 | 114 | 20 | 8 |
| ២៦ | ថ្នាក់កណ្ដាល | 3,467 | 1,040 | 2,579 | 746 | 888 | 294 | 42 | 16 |
| សរុប | | **121,098** | **49,841** | **100,628** | **45,453** | **20,470** | **4,383** | **710** | **383** |

ប្រភព៖ សៀវភៅបេឡាគុមរណបុត្តម្ភ និងសៀវភៅបេឡាសាងសង់ឆ្នាំ២០១៥
(ចំនួនស្រីមានខ្លះជាស្ថិតិឆ្នាំមុន និង២០១៥ ស្រង់តាមស្ថិតិបង់ប្រាក់ឆ្នាំ២០១៥ ខែធ្នូ)

ភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦
អ្នកធ្វើតារាង

**គុយ ផល្លា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្ដាល
លេខ: ៤៨ /១៦គ.ក

**សេចក្ដីជូនដំណឹងមរណៈភាពប្រចាំខែតុលា ឆ្នាំ២០១៦**
**តាងនាមសមាគមបុគ្គលិកសិក្សាខ្មែរទាំងមូលគណៈកម្មាធិការកណ្ដាលនៃ ស.ប.ស.ខ.**
**សូមសម្ដែងក្ដីសោកស្ដាយជាទីបំផុតចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ**
**ហើយសូមចូលរួមរំលែកទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ**

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបម្រើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខបណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណៈភាពសមាជិក | | | | |
| 1 | សុខ សៅយឹម | 48 | ស | បឋម | បឋម ល្បើក រង្សី ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង | 03.07.16 | របេងឆ្អឹង | 2208កឆ | 11394 |
| 2 | អ៊ុម ពិសុទ្ធ | 60 | ប | បឋម | បឋម បឹងខ្នារ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង | 11.07.16 | ទឹកនោមផ្អែម | 0690កឆ | 11395 |
| 3 | កែវ ភន | 64 | ប | ម.កំ១ | និវត្តជន វិ.សម្ដេចនរោត្តមសីហមុនី-កំពង់ត្រឡាច-កំពង់ឆ្នាំង | 04.07.16 | ទឹកនោមផ្អែម | 0798កឆ | 11396 |
| 4 | ម៉ារ៉េត ភួង | 71 | ប | បឋម | និវត្តជន បឋមវត្ត គ្រង ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | 25.07.16 | គ្រោះថ្នាក់ចរាចរ | 0975កឆ | 11397 |
| 5 | តូ ទិត្យ ស៊ីដា | 48 | ស | បឋម | បឋម ទ័ពស្រូវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | 20.07.16 | ជរាពាធ | 2920កឆ | 11398 |
| 6 | សាយ ឆវី | 47 | ស | ម.កំ១ | ការិ.អ.យ.ក ស្រុកអង្គរជ័យ ខេត្តកំពត | 29.06.16 | ជរាពាធ | 1557កព | 11399 |
| 7 | ហែម ហ៊ន | 67 | ប | បឋម | និវត្តជន បឋមស្វាយផ្អែម កំពង់ត្រាច ខេត្តកំពត | 06.07.16 | ជរាពាធ | 650កព | 11400 |
| 8 | គឹម សូវន | 58 | ប | បឋម | បឋមអង្គពន្លឺ ស្រុកអង្គរជ័យ ខេត្តកំពត | 22.07.16 | ទឹកនោមផ្អែម | 1710កព | 11401 |
| 9 | ម៉ម ធីម | 61 | ប | បឋម | និវត្តជន បឋមអង្គធាយ ស្រុកបន្ទាយមាស ខេត្តកំពត | 10.08.16 | ជំងឺក្រពះ | 3364កព | 11402 |
| 10 | គង់ ចិន | 48 | ប | ម.កំ១ | អនុវិទ្យាល័យ ហ.ស អង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត | 20.07.16 | ដុះសាច់ខួរក្បាល | 1542កព | 11403 |
| 11 | ឯល កាម៉ិច | 69 | ស | បឋម | និវត្តជន បឋមទួលសូភី អូរាំងឪ ខេត្តត្បូងឃ្មុំ | 12.07.16 | ជរាពាធ | 1785តឃ | 11404 |
| 12 | អ៊ូ ហេន | 74 | ប | បឋម | និវត្តជន បឋមហ.ស អំពុក ពញាក្រែក ខេត្តត្បូងឃ្មុំ | 14.02.16 | ជរាពាធ | 2966តឃ | 11405 |
| 13 | ជា យុត | 77 | ប | បឋម | និវត្តជន បឋមអង្គរក្រៅ ពញាក្រែក ខេត្តត្បូងឃ្មុំ | 20.06.16 | ជរាពាធ | 2608តឃ | 11406 |
| 14 | យក់ ស៊ឹម | 83 | ប | បឋម | និវត្តជន បឋមប៊ុនរ៉ានី ហ.ស ខ្សាក ពញាក្រែក ខេត្តត្បូងឃ្មុំ | 20.02.16 | ជរាពាធ | 3100តឃ | 11407 |
| 15 | នូ សារិន | 69 | ប | បឋម | និវត្តជន បឋមតាប៉ាវចំរើនក្រូចឆ្មារ ខេត្តត្បូងឃ្មុំ | 16.07.16 | លើសឈាម | 2479តឃ | 11408 |
| 16 | ភេន សឿន | 72 | ប | បឋម | និវត្តជន បឋមទឹកជ្រៅ កំរៃវ ខេត្តត្បូងឃ្មុំ | 04.08.16 | ជរាពាធ | 3410តឃ | 11409 |
| 17 | ធន់ វ៉ាន់ស៊ី | 65 | ស | ម.កំ២ | និវត្តជន វិទ្យាល័យព្រែកអញ្ចាញ ស្រុកមុខកំពូល កណ្ដាល | 15.07.16 | កាំងបេះដូង | 820កណ | 11410 |
| 18 | កែវ សារ៉ុម | 69 | ប | ម.កំ១ | និវត្តជន អនុវិ.កោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល កណ្ដាល | 03.08.16 | ជរាពាធ | 7961កណ | 11411 |
| 19 | សួន ស៊ុម | 67 | ប | បឋម | និវត្តជន បឋមវត្តវន្ត ស្រុកកោះធំ ខេត្តកណ្ដាល | 04.08.16 | មហារីកបំពង់ក | 355កណ | 11412 |
| 20 | សេង សៀម | 63 | ប | បឋម | និវត្តជន បឋម វត្តត្នោត ស្រុកអង្គស្នួល ខេត្តកណ្ដាល | 21.08.16 | មហារីក្រពះ | 4891កណ | 11413 |
| 21 | គង់ សម្បុក | 48 | ប | បឋម | បឋម ផ្លូវត្រី ស្រុកល្វាឯម ខេត្តកណ្ដាល | 09.08.16 | លើសឈាម | 2828កណ | 11414 |
| 22 | ហួត យឹម | 69 | ប | ម.កំ១ | និវត្តជន វិទ្យាល័យ ហ.ស ថ្នល់ទទឹង -អង្គស្នួល កណ្ដាល | 22.08.16 | លើសឈាម | 5255កណ | 11415 |
| 23 | យ៉ូវ ឡឿន | 88 | ប | គ្រូបឋម | និវត្តជន បឋមសិក្សាកែវជ័យ ស្រុកកណ្ដៀង ខេត្តពោធិសាត់ | 24.07.16 | លើសឈាម | 2596ពស | 11416 |
| 24 | យឹម តាំងអោ | 43 | ប | គ្រូបឋម | និវត្តជន បឋមកោះជុំ ស្រុកកណ្ដៀង ខេត្តពោធិសាត់ | 15.05.16 | រលាកសួត | 588ពស | 11417 |
| 25 | ឯម ចន្ថា | 61 | ប | គ្រូបឋម | និវត្តជន បឋមសិក្សាខ្នាទទឹង ស្រុកបាកាន ខេត្តពោធិសាត់ | 21.08.16 | របេងសួត | 2083ពស | 11418 |
| 26 | កេត យ៉ាន់ | 73 | ប | បឋម | និវត្តជន បឋមថ្មគ្រែ ក្រុងក្រចេះ ខេត្តក្រចេះ | 04.09.16 | ជរាពាធ | 1340ក្រច | 11419 |
| 27 | គួន កាន | 71 | ប | បឋម | និវត្តជន បឋមព្រីងកោង ក្រុងសិរីសោភ័ណ្ឌ ខេត្តប.មានជ័យ | 04.09.16 | ជរាពាធ | 304បជ | 11420 |
| 28 | ព្រូ សុជាតិ | 31 | ប | បឋម | បឋមសិក្សា ឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ | 04.09.16 | គ្រោះថ្នាក់ចរាចរ | 6177បជ | 11421 |
| 29 | គួច ថនសាវី | 71 | ស | បឋម | និវត្តជន បឋមឫស្សីកែវ រាជធានីភ្នំពេញ | 28.07.16 | មហារីកសួត | 3661ភព | 11422 |
| 30 | នាង សុវណ្ណ | 77 | ប | បឋម | និវត្តជន បឋមសិក្សា កុលាបទី១ រាជធានីភ្នំពេញ | 17.08.16 | គាំងបេះដូង | 3147ភព | 11423 |
| 31 | ឡុង សិរីវុឌ្ឍ | 71 | ស | មទភ | និវត្តជន វិទ្យាល័យសន្ធរម៉ុក រាជធានីភ្នំពេញ | 26.08.16 | សរសៃប្រសាទ | 5936ភព | 11424 |
| 32 | សាន់ ខាយ | 74 | ស | បឋម | និវត្តជន បឋម បេងឈូក ប្រជុំវង្ស រាជធានីភ្នំពេញ | 03.09.16 | ទឹកនោមផ្អែម | 1198ភព | 11425 |
| 33 | ឥន្ទ ពៅ | 70 | ប | បឋម | និវត្តជន បឋម ជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ | 21.10.15 | លើសឈាម | 689ពហ | 11426 |
| 34 | ស៊ី ទិត | 43 | ប | បឋម | បឋមសិក្សា ពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ | 13.11.15 | គ្រោះថ្នាក់ចរាចរ | 1026ពហ | 11427 |
| 35 | ព្រំ វ៉ាន់ | 67 | ប | បឋម | និវត្តជនបឋមទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ | 28.04.16 | ជរាពាធ | 105ពហ | 11428 |
| 36 | សៅ អឿន | 43 | ប | បឋម | បឋមពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ | 21.02.16 | លង់ទឹក | 195ពហ | 11429 |
| 37 | ពេជ សាអុំ | 78 | ប | ម.កំ២ | និវត្តជន មន្ទីរអ.យ.ក ខេត្តព្រះវិហារ | 09.04.16 | ជំងឺក្រពះ | 001ពហ | 11430 |
| 38 | ជា សាម៉ន | 72 | ប | បឋម | និវត្តជនបឋម.បាបោង ស្រុក ពាមរក៍ ខេត្តព្រៃវែង | 25.07.16 | ជរាពាធ | 4976ពវ | 11431 |
| 39 | សុំ បុប្ផាមត្តេយ្យ | 26 | ស | ឧត្តម | វិ.បាភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង | 03.08.16 | សរសៃប្រសាទ | 10978ពវ | 11432 |
| 40 | ព្រាប លាង | 76 | ប | បឋម | និវត្តជន ប.រតនៈ ស្រុកព្រះស្ដេច ខេត្តព្រៃវែង | 03.08.16 | ជរាពាធ | 1141ពវ | 11433 |
| 41 | ជួប ស្រស់ | 48 | ប | បឋម | ប.ថ្មីង ស្រុក កំពង់ត្របែក ខេត្តព្រៃវែង | 02.08.16 | ឈាមកកខួរក្បាល | 6912ពវ | 11434 |
| 42 | ញឹម រុន | 53 | ប | មូលដ្ឋាន | វិ.ប្រជាតុ កំពង់ត្របែក ខេត្តព្រៃវែង | 20.08.16 | ជរាពាធ | 1664ពវ | 11435 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 43 | បាន សុខា | 71 | ប | គ្រូបឋម | និវត្តជន បឋមអណ្ដូងតាអុង ស្រុកកងមាស ខេត្តកំពង់ចាម | 09.05.16 | ជរាពាធ | 8350កច | 11436 |
| 44 | យីន ម៉ុល | 44 | ប | គ្រូបឋម | គ្រូបឋមសិក្សាស្ដៅ ស្រុកកងមាស ខេត្តកំពង់ចាម | 29.05.16 | រោគាពាធ | 8124កច | 11437 |
| 45 | ប្រាក់ ឆន | 80 | ប | គ្រូបឋម | និវត្តជន បឋមសិក្សាមហាលាភ ស្រុកកោះសូទិន -កំពង់ចាម | 21.06.16 | រោគាពាធ | 1913កច | 11438 |
| 46 | អ៊ុំ សំណាង | 44 | ប | គ្រូបឋម | គ្រូបឋមសិក្សាកុមារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម | 21.06.16 | ខ្យល់គ | 2457កច | 11439 |
| 47 | គិន ធឿន | 43 | ប | គ្រូបឋម | គ្រូបឋមសិក្សាទំពរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម | 23.06.16 | ជម្ងឺរ៉ាំរ៉ៃ | 2601កច | 11440 |
| 48 | ឈីន ច័ន្ទថន | 49 | ប | គ្រូឧត្ដម | គ្រូវិទ្យាល័យ ដំដុះ ក្រុងកំពង់ចាម ខេត្តកំពង់ចាម | 25.06.16 | រោគាពាធ | 3725កច | 11441 |
| 49 | ប៉ាន់ ផាន់ណារ៉ា | 47 | ស | មូលដ្ឋាន | គ្រូបឋមកោះរកាក្រៅ ស្រុកកំពង់សៀម ខេត្តកំពង់ចាម | 30.07.16 | ទឹកនោមផ្អែម | 3952កច | 11442 |
| 50 | សុខ សុវណ្ណ | 62 | ប | បឋម | និវត្តជន បឋមសិក្សាគោកទ្រា ស្រុកព្រៃឈរ ខេត្តកំពង់ចាម | 19.07.16 | បេះដូងរីក | 3000កច | 11443 |
| 51 | ព្រំ សារ៉ាត | 60 | ប | បឋម | និវត្តជន បឋមសិក្សាស្ដី ស្រុកចំការលើ ខេត្តកំពង់ចាម | 09.08.16 | រោគាពាធ | 6019កច | 11444 |
| 52 | ទុំ ទីន | 42 | ប | បឋម | គ្រូបឋមសិក្សាហសផ្ដៅជុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម | 04.08.16 | រោគាពាធ | 2218កច | 11445 |
| 53 | ហេង ផេន | 42 | ប | បឋម | គ្រូបឋមសិក្សាតាំងបឹង ស្រុកបាធាយ ខេត្តកំពង់ចាម | 12.08.16 | មហារីកថ្លើម | 1415កច | 11446 |
| 54 | នង សាធឿត | 43 | ប | បឋម | បឋមផ្លាស់គង់ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ | 20.09.16 | ជម្ងឺបេះដូង | 3114បជ | 11447 |
| 55 | ម៉ៅ សានឿន | 73 | ប | បឋម | និវត្តជន បឋម ពោធិរាំបុណ្យ ស្រុកភ្នំស្រួច បន្ទាយមានជ័យ | 16.09.16 | គាំងបេះដូង | 1443បជ | 11448 |
| 56 | សួន បុរី | 42 | ប | ម.កំ១ | វិទ្យាល័យអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប | 08.07.16 | ក្រិនថ្លើម | 1029សរ | 11449 |
| 57 | ដួង និមល | 45 | ប | ម.កំ១ | វិទ្យាល័យអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប | 21.08.16 | ក្រិនថ្លើម | 1016សរ | 11450 |
| 58 | យូ យាន | 76 | ប | បឋម | និវត្តជន បឋមស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប | 04.09.16 | លើសឈាម | 2422សរ | 11451 |
| 59 | លួន ភួន | 63 | ប | បឋម | និវត្តជន បឋមស្ទឹងត្រែង ក្រុង-ខេត្តស្ទឹងត្រែង | 11.07.16 | ខ្យល់គរ | 099សត | 11452 |
| 60 | ហ៊ិន សឿង | 77 | ប | ម.កំ១ | និវត្តជនម.អ.យ.ក ខេត្តស្ទឹងត្រែង | 18.08.16 | រលាកសួត | 014សត | 11453 |
| 61 | កុយ ឆែម | 78 | ប | គ្រូបឋម | និ.វ សាលាបឋមចំការស្បូវ អូរាំងឪ ត្បូងឃ្មុំ | 11.08.16 | រោគាពាធ | 1957តឃ | 11454 |
| 62 | ជន ស្រេង | 61 | ស | គ្រូបឋម | និ.វ.សាលាបឋម ថ្នល់កែង អូរាំងឪ ត្បូងឃ្មុំ | 13.08.16 | ដុំសាច់ក្នុងថ្លើម | 2032តឃ | 11455 |
| 63 | ហាស់ កុសល | 75 | ប | គ្រូបឋម | និ.វ.សាលាបឋម ស្រែសោមថ្មី មេមត់ ត្បូងឃ្មុំ | 30.07.16 | រោគពាធ | 459តឃ | 11456 |
| 64 | ម៉ែន ញឹម | 87 | ប | បឋម | និ.វ បឋមផ្សារដើមថ្កូវ ការគ្រប់គ្រងគណៈកម្មាធិការកណ្ដាល | 16.09.16 | រោគពាធ | 1119គក | 11457 |
| 65 | ទិត្យ គីរី | 56 | ប | បឋម | សាលាបឋមសិក្សាអំពិលស្រុក ស្ទោង ខេត្តកំពង់ធំ | 20.02.16 | រោគាពាធ | 2164កធ | 11458 |
| 66 | គីម កុលាប | 43 | ស | ទុតិយភូមិ | វិទ្យាល័យ ហ៊ុនសែនតាំងគោក ស្រុកបារាយណ៍ ខេត្តកំពង់ធំ | 15.02.16 | រោគាពាធ | 4072កធ | 11459 |
| 67 | ជឹម ប៊ុនរិទ្ធី | 38 | ប | ទុតិយភូមិ | វិទ្យាល័យ រស្មីសោភ័ណ ស្រុកស្ទោង ខេត្តកំពង់ធំ | 04.02.16 | គ្រោះថ្នាក់ចរាចរ | 1684កធ | 11460 |
| 68 | ដើក ណេ | 67 | ប | បឋម | និវត្តជន បឋមព្រៃតាលី ស្រុកស្វាយទាប ខេត្តស្វាយរៀង | 17.08.16 | លើសឈាម | 1937ស្វរ | 11461 |
| 69 | រាម វ៉ូន | 42 | ប | បឋម | បឋម ជម្ពូព្រឹក្សា ក្រុងស្វាយរៀង ខេត្តស្វាយរៀង | 25.07.16 | រលាកស្រោមខួរ | 3610ស្វរ | 11462 |
| 70 | គង់ ថៃ | 64 | ប | បឋម | និវត្តជន បឋមថ្លុកព្រីង ស្រុបស្វាយទាប ខេត្តស្វាយរៀង | 25.07.16 | លើសឈាម | 2182ស្វរ | 11463 |
| ខ.មរណៈភាពសពគូស្រករ | | | | | | | | | |
| 1 | ណេត ស៊ីណាត | 66 | ប | កសិករ | ប្ដីអ.សអ៊ឹម ប៊ុណ្ណា វិទ្យាល័យរលាប្អៀរ រលាប្អៀរ-កំពង់ឆ្នាំង | 05.08.16 | ជម្ងឺរ៉ាំរ៉ៃ | 2340កឆ | 6517 |
| 2 | សុខ សៅយឹម | 48 | ស | បឋម | ប្រពន្ធលោកជា សុផាត បឋមល្បើករង្សី-បរិបូណ៌ -កំពង់ឆ្នាំង | 03.07.16 | របេងឆ្អឹង | 330កឆ | 6518 |
| 3 | សួង លាប់ | 60 | ស | កសិករ | ប្រពន្ធល.សាន់ ឡុន អនុ.ខ្លាគ្រហឹម កំពង់ត្រឡាច កំពង់ឆ្នាំង | 03.07.16 | របេងសួត | 788កឆ | 6519 |
| 4 | គង់ ចិន | 48 | ប | ម.កំ១ | ប្ដីអ.ស អ៊ឹង លីវន អនុ. ហ.សអង្គរជ័យ ស្រុកអង្គរជ័យ-កំពត | 20.07.16 | ដុះសាច់ខួរក្បាល | 1522កព | 6520 |
| 5 | ស៊ុយ ធី | 51 | ស | មេផ្ទះ | ប្រពន្ធល.អ៊ិត សុផល បឋមគីរីអម្ពរវ័ន ស្រុកអង្គរជ័យ .កំពត | 29.07.166 | លើសឈាម | 1919កព | 6521 |
| 6 | ស៊ុន ហ្គេកហៀក | 54 | ស | មេផ្ទះ | ប្រពន្ធល. ស៊ោង ស្រឿង បឋមរកាពប្រាំ ស្រុកខេត្តត្បូងឃ្មុំ | 18.07.16 | រោគាពាធ | 461តឃ | 6522 |
| 7 | ល្អម វ៉ាន់ឌី | 54 | ប | កសិករ | ប្ដីអ.ស អ៊ិន សាម៉េត បឋមសិក្សាសុខារាម ក្រុងពោធិសាត់ | 23.05.16 | ក្រិនថ្លើម | 548ពស | 6523 |
| 8 | សោម សែ | 68 | ប | មន្ត្រី | ប្ដីអ្នកគ្រូ ពៅ វណ្ណេត បឋមសិក្សាព្រៃញី ក្រុង-ខេត្តពោធិសាត់ | 20.06.16 | កើតពិស | 425ពស | 6524 |
| 9 | នូ គឹមឈាន | 52 | ប | កម្មករ | ប្ដីអ្នកគ្រូ សំ គីម មត្តេយ្យ ស្រុកកណ្ដៀង ខេត្តពោធិសាត់ | 13.06.16 | មហារីកតម្រងនោម | 1122ពស | 6525 |
| 10 | ហេង ចាន់រ៉ា | 31 | ប | កម្មករ | ប្ដីអ្នកគ្រូ សេង ឡាទី បឋមក្បាន ស្រុកកណ្ដៀង ពោធិសាត់ | 21.08.16 | ខ្យល់គរ | 3639ពស | 6526 |
| 11 | អេម ង៉ែត | 73 | ស | កសិករ | ប្រពន្ធល.ម៉ែន មាន និវត្តជនបឋម.បាកាន ខេត្តពោធិសាត់ | 22.08.16 | លើសឈាម | 1943ពស | 6527 |
| 12 | សុខ សុគន្ធ | 75 | ស | មេផ្ទះ | ប្រពន្ធល.ពេជ្រ សុវណ្ណ និវត្តប.តាខ្មៅ ក្រុងតាខ្មៅ កណ្ដាល | 20.08.14 | រោគាពាធ | 3748កណ | 6528 |
| 13 | សេក សុទុម | 66 | ស | មេផ្ទះ | ប្រពន្ធល.ម៉ៅ មួន និ.បឋមពុកឬស្សី-ខ្សាច់កណ្ដាល កណ្ដាល | 11.08.16 | ដុះសាច់ខួរក្បាល | 335កណ | 6529 |
| 14 | ស សុភាព | 66 | ស | មេផ្ទះ | ប្រពន្ធលោក គង់ ពូន និវត្តជន អនុ.សិត្បូ ស្រុកស្អាង -កណ្ដាល | 13.08.16 | រោគាពាធ | 5639កណ | 6530 |
| 15 | ហួត យឹម | 69 | ស | មេផ្ទះ | ប្រពន្ធល.សុខ សាន្ត និវត្ត.វិ.ថ្នល់ទទឹង អង្គស្នួល កណ្ដាល | 22.08.16 | លើសឈាម | 5235កណ | 6531 |
| 16 | ឡុង សុង | 46 | ប | កសិករ | ប្ដីអ.សឈិត ស្រីធួក អនុ.ខ្វាស់ ស្រុកសូទ្រនិគម សៀមរាប | 11.08.16 | ខ្យល់គរ | 4591សរ | 6532 |
| 17 | អ៊ុយ ទ្រី | 66 | ស | មេផ្ទះ | ប្រពន្ធល.កៅ គី និវត្តជនបឋមពងទឹក ដំណាក់ចង្អើរ-កែប | 24.06.16 | រោគាពាធ | 0722កែ | 6533 |
| 18 | ព្រួ សុជាតិ | 31 | ប | បឋម | ប្ដីអ.សជាត សុផាណាបឋមឫស្សីក្រោក-មង្គលបូរី-ប.មានជ័យ | 04.09.16 | គ្រោះថ្នាក់ចរាចរ | 6176បជ | 6534 |
| 19 | អ៊ូ ភីរុណ | 49 | ប | នគរបាល | ស្វាមីអ្នកគ្រូ នូ សំអាន វិទ្យាល័យពងទឹក រាជធានីភ្នំពេញ | 30.07.16 | ទឹកនោមផ្អែម | 3634ភព | 6535 |
| 20 | អៀត អូន | 69 | ស | មេផ្ទះ | ប្រពន្ធ លោកគ្រូ ម៉ែន ម៉ន បឋមសិក្សា ច្បារអំពៅ២ ភ្នំពេញ | 15.08.16 | លើសឈាម | 1169ភព | 6536 |
| 21 | លី សែន | 58 | ប | អាកាសចរស៊ីវិល | ស្វាមីអ្នកគ្រូ អ៊ឹង ច័ន្ទណារី មត្តេយ្យ វត្តកោះ រាជធានីភ្នំពេញ | 09.08.16 | ជម្ងឺថ្លើម | 3461ភព | 6537 |
| 22 | ប៊ិន សុខ | 60 | ស | មេផ្ទះ | ប្រពន្ធលោកគ្រូ ប៉ាង សុវណ្ណ បឋម.ពញាពន់ រាជធានីភ្នំពេញ | 29.08.16 | ជម្ងឺថ្លើម | 13183ភព | 6538 |
| 23 | ឈឹម ហូ | 58 | ស | កសិករ | ប្រពន្ធលោកគ្រូ គង់ អេង និវត្តជន ស្រុករវៀង ខេត្តព្រះវិហារ | 08.08.15 | រោគាពាធ | 428ពហ | 6539 |
| 24 | ចាន់ អួន | 66 | ស | មេផ្ទះ | ប្រពន្ធលោកភោគ ហួន និវត្តជន ស្រុករវៀង ខេត្តព្រះវិហារ | 19.06.16 | រោគាពាធ | 458ពហ | 6540 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 25 | នឿន លីន | 54 | ប | កសិករ | ប្ដីអ្នកគ្រូ ស៊ើន ស្រីរឹងប.ហ.សទូលព្រៃឆ្កៀវ គូលែន -ព្រះវិហារ | 26.12.15 | គ្រោះថ្នាក់ចរាចរ | 1726ពហ | 6541 |
| 26 | ហ៊ឹង ឡៃ | 30 | ស | កសិករ | ភរិយា ល.ឃិន វាសនា វិ.ព្រែកក្របៅ ស្រុកពាមជរ | 23.07.16 | ជាគាពាធ | 10229 | 6542 |
| 27 | ញ៉ឹក ស៊ី | 56 | ស | កសិករ | ភរិយា ល.គង់ គឹមសាន និវត្ត មន្ទីរ.អយក.ក្រុងព្រៃវែង | 19.08.16 | ជម្ងឺមហារីក | 052 | 6543 |
| 28 | ឈុំ ឆន | 43 | ប | កសិករ | ស្វាមី ល.ស.សួន សារី ប.គ្រួស ស្រុកកញ្ជៀងច | 19.08.16 | ជម្ងឺ | 875 | 6544 |
| 29 | សោម សុខជឿន | 46 | ប | កសិករ | ប្ដីអ្នកគ្រូ ស្រេង ថារី បឋមសិក្សាស្ពៅ កងមាស កំពង់ចាម | 09.04.16 | ហើមសួត | 8102កច | 6545 |
| 30 | ឈីន ច័ន្ទថន | 49 | ប | គ្រូកំរិតឧត្តម | ប្ដីអ្នកគ្រូ សំរិទ្ធិ សារិ វិ.ដីដុះ ក្រុងកំពង់ចាម ខេត្តកំពង់ចាម | 25.06.16 | ជាគាពាធ | 3702កច | 6546 |
